CRC30 YEARS
CONVENTION ON THE RIGHTS OF THE CHILD

# កូនសោអនាគត

## កម្ពុជា



## សិទ្ធិកុមារ

ជាគន្លឹះសម្រាប់កំណើន
សេដ្ឋកិច្ច និងការអភិវឌ្ឍ
ប្រទេសកម្ពុជា
នាពេលអនាគត

សិទ្ធិកុមារបច្ចុប្បន្ន!
កម្ពុជា
២០១៩

ChildFund Alliance | PLAN INTERNATIONAL | Save the Children | SOS CHILDREN'S VILLAGES CAMBODIA | Terre des Hommes International Federation | World Vision



© World Vision

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះគឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាង អង្គការសង្គមស៊ីវិលអន្តរជាតិដែលធ្វើការងារផ្តោតលើកុមារចំនួន ៦ អង្គការ ដែលចង់ប្រើប្រាស់ខួបលើកទី ៣០ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដើម្បីពិនិត្យវាយតម្លៃលើវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវសិទ្ធិ របស់កុមារ ហើយឆ្លើយតបទៅនឹងរបៀបវារៈដែលមិនទាន់បានបញ្ចប់ឲ្យសព្វគ្រប់នៅឡើយ។ គម្រោងនេះ ចាប់កំណើតចេញពី កិច្ចពិភាក្សារួមគ្នាមួយកាលពីឆ្នាំ ២០១៧ ដែលគាំទ្រដោយមូលនិធិ Rockefeller Foundation ដែលនាំឲ្យកើតមាននូវកិច្ចសហប្រតិបត្តិការមួយ ក្រោមគម្រោង "រួមកម្លាំងគ្នា" (Joining Forcesរវាងសម្ព័ន្ធអង្គការឆាលហ្វាន (ChildFund Alliance) អង្គការ ផ្លែនអន្តរជាតិ (Plan International) អង្គការSave the Children អង្គការ SOS Children's Village International អង្គការ Terre des Hommes International Federation និងអង្គការទស្សនៈពិភពលោកអន្តរជាតិ (World Vision International)។ បច្ចុប្បន្ននេះ គម្រោង "រួមកម្លាំងគ្នា" ។ ទីមួយគឺសិទ្ធិកុមារ បច្ចុប្បន្ន! ដោយរបាយការណ៍នេះក៏ជាផ្នែកមួយនៃការងារទីមួយនោះដែរ និងការងារ ទីពីរ គឺបញ្ចប់អំពើហិង្សាលើកុមារ។

របាយការណ៍នេះគឺកើតចេញពីការងារដែលធ្វើឡើងដោយក្រុមពហុវិស័យ ដឹកនាំដោយលោក Mathieu Andre អ្នកស្រីសាំង រ៉ានី និង លោក ហ៊ុយ យី។ របាយការណ៍នេះក៏មានការជួយរួមចំណែកពីលោក Steve Cooke (ទីប្រឹក្សា) ក្នុងការព្រាង និងត្រួតពិនិត្យ។ លោក Prashant Verma, លោក Robert Gillen, អ្នកស្រី ជា លីដា អ្នកស្រី សាវតា ច័ន្ទគ្រីស្នា, លោក Jose Moriano, លោក អេង ហុក; លោក ឈឹម ផាន់ណា; លោក សួរ ចាន់កុសុម; លោក Sian Platt, អ្នកស្រី Elizabeth Pearce, អ្នកស្រី Gloria Doñate, លោក កាន់ កាល់ និង កញ្ញា Claire O'Donnell បានផ្តល់ការគាំទ្រ និងដំបូន្មានយ៉ាងជិតដល់សម្រាប់ក្រុមការងារ។

ក្រុមការងារសូមថ្លែងអំណរគុណសម្រាប់ការរួមចំណែកយ៉ាងសកម្មពីក្រុមបច្ចេកទេសរបស់ សម្ព័ន្ធអង្គការឆាលហ្វាន អង្គការផ្លែនអន្តរជាតិ អង្គការ Save the Children អង្គការ SOS Children's Village International អង្គការ Terre des Hommes International Federation និងអង្គការទស្សនៈពិភពលោកអន្តរជាតិ (World Vision International)។

របាយការណ៍នេះ ក៏ដូចជាឯកសារពាក់ព័ន្ធត្រូវបានចងក្រង ដោយបុគ្គលិករបស់ សម្ព័ន្ធអង្គការឆាលហ្វាន អង្គការ ផ្លែនអន្តរជាតិ អង្គការ Save the Children អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា អង្គការ Terre des Hommes International Federation និងអង្គការទស្សនៈពិភពលោកអន្តរជាតិ។ រាល់លទ្ធផល ការបកស្រាយ និងសេចក្តីសន្និដ្ឋានផ្សេងៗ ដែលបានបញ្ជាក់នៅក្នុងឯកសារនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការទាំង ៦ ឡើយ។ អង្គការទាំង ៦ នេះ មិនធានាលើសុក្រឹតភាពរបស់ទិន្នន័យដែលមានបញ្ចូលនៅក្នុងរបាយការណ៍នេះឡើយ។

## ការយកធ្វើជាឯកសារយោង

សូមដកស្រង់របាយការណ៍នេះ ដោយចាត់ ទុកជា ឯកសារយោងថា៖ សិទ្ធិកុមារបច្ចុប្បន្ន ២០១៩។ កូនសោអនាគតកម្ពុជា។ សិទ្ធិកុមារជាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត។ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

## សិទ្ធិ និងការអនុញ្ញាត

អង្គការទាំង ៦ ជំរុញឲ្យមានការផ្សព្វផ្សាយរបាយការណ៍នេះ ក៏ដូចជាឯកសារសង្ខេបគោលនយោបាយដែលពាក់ព័ន្ធ។ ប៉ុន្តែ ខ្លឹមសារនៅក្នុងឯកសារនេះមានការរក្សាសិទ្ធិ ហើយត្រូវសុំការ អនុញ្ញាតមុនពេលថតចម្លង និង/ឬ ផ្សព្វផ្សាយផ្នែកណាមួយ ឬរបាយការណ៍ទាំងស្រុង។

សម្រាប់សំណួរផ្សេងៗទាក់ទងនឹងរបាយការណ៍នេះ សូមអានព័ត៌មានទំនាក់ទំនងដែលមានភ្ជាប់នៅខាងចុងឯកសារនេះ។

# មាតិកា


- សេចក្ដីថ្លែងអំណរគុណ
- អក្សរកាត់ / ១
- សេចក្ដីសង្ខេប / ២
- ៣០ ឆ្នាំនៃវឌ្ឍនភាពដ៏សម្បើមក្នុងប្រទេសកម្ពុជា / ៤
- ផ្លូវឆ្ពោះទៅរកឆ្នាំ ២០៣០ / ៧
- កត្តាកែប្រែសម្រាប់ជាកូនសោរអនាគតកម្ពុជា / ១០

  ១ កែលម្អលទ្ធភាពទទួលបានសេវាអប់រំកុមារតូច ដែលមានគុណភាព / ១១
  ២ កែលម្អលទ្ធភាពទទួលបានការអប់រំមូលដ្ឋាន ដែលមានគុណភាព / ១២
  ៣ ដោះស្រាយអត្រាប្រេវ៉ាឡង់ខ្ពស់នៃបញ្ហាកិច្ចការពារកុមារ /១៩
  ៤ កាត់បន្ថយឲ្យបាន ច្រើនបំផុតនូវអត្រាកុមារខ្វះអាហារូបត្ថម្ភ / ២៣
  ៥ កែលម្អលទ្ធភាពទទួលបានសេវាទឹកផឹកមូលដ្ឋាន និងអនាម័យ / ២៧
  ៦ បង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់កុមារក្នុងដំណើរការនៃការសម្រេចចិត្ត / ៣១

- តើ សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! នៅក្នុងប្រទេសកម្ពុជា ជាអ្វី? / ៣៤
- អង្គការសមាជិក / ៣៤

# អក្សរកាត់

| | |
|---|---|
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ |
| CDHS | អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ECCD | ការគាំពារនិងអភិវឌ្ឍន៍កុមារតូច |
| ECE | ការអប់រំកុមារតូច |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GNI | ចំណូលជាតិសរុប |
| ILO | អង្គការពលកម្មអន្តរជាតិ |
| ISAF | ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម |
| LGBTIQ | អ្នកស្រលាញ់ភេទដូចគ្នា |
| MDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| OECD | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UNCRC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| UNICEF | មូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ |
| VHSG | ក្រុមគាំទ្រសុខភាពភូមិ |

# សេចក្តីសង្ខេប

កាលពី ៣០ ឆ្នាំមុន ថ្នាក់ដឹកនាំពិភពលោកបានធ្វើការប្តេជ្ញាចិត្តជាប្រវត្តិសាស្ត្រចំពោះគ្រប់កុមារក្នុងពិភពលោក តាមរយៈការអនុម័តលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC)។ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញានេះក្នុងឆ្នាំ ១៩៩២ ជាមួយនឹងការប្តេជ្ញាចិត្តធានាឲ្យមានសិទ្ធិទាំងអស់នេះសម្រាប់កុមារគ្រប់រូបនៅទូទាំងប្រទេស។ ទិន្នន័យដែលអាចរកបានស្តីពីវឌ្ឍនភាពរបស់ប្រទេសកម្ពុជាទាក់ទងនឹងសិទ្ធិកុមារក្នុងរយៈកាល ៣០ ឆ្នាំមកនេះ បានបង្ហាញថា មានភាពប្រសើរឡើងយ៉ាងខ្លាំង។ បើពិនិត្យលើផ្នែកសំខាន់ៗទាក់ទងនឹងសិទ្ធិកុមារ កម្ពុជាសម្រេចបានដោយប្រើពេលត្រឹមតែពីរ បីទសវត្ស ធៀបនឹងបណ្តាប្រទេសជាច្រើនដែលត្រូវប្រើពេលរហូតដល់ទៅមួយសតវត្សឯណោះដើម្បីសម្រេចបាន។ ជាលទ្ធផល ជីវិតរបស់កុមាររាប់ពាន់ រាប់ម៉ឺននាក់ បានទទួលការជួយសង្គ្រោះ ហើយសុខុមាលភាពរបស់កុមាររាប់លាននាក់ត្រូវបានកែលម្អយ៉ាងខ្លាំង ដែលទាំងអស់នេះជួយកំណត់និយមន័យសារជាថ្មីអំពីការរីកធំធាត់របស់កុមារនៅក្នុងប្រទេសកម្ពុជា។

## សិទ្ធកុមារ និងកំណើនសេដ្ឋកិច្ច

ច្បាស់ណាស់ វឌ្ឍនភាពរបស់ប្រទេសកម្ពុជាទាក់ទងនឹងសិទ្ធិកុមារក្នុងរយៈកាល ៣០ ឆ្នាំមកនេះ កើតចេញពីកំណើនសេដ្ឋកិច្ចដ៏គួរឲ្យស្ញប់ស្ញែងរបស់ខ្លួនក្នុងរយៈកាលដូចគ្នានេះដែរ។ ចន្លោះពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ២០១៧ កម្ពុជា ជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចលូតលាស់លឿនជាងគេបំផុតលំដាប់ទី ៦ ក្នុងពិភពលោក ហើយភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨% មកនៅត្រឹម ១៣,៥% [1]។ ជាលទ្ធផល ក្រុមគ្រួសារ សហគមន៍ និងរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពក្នុងការវិនិយោគលើសុខុមាលភាពរបស់កុមារកម្ពុជា ដែលជាលទ្ធផលបានទទួលនូវអាហារូបត្ថម្ភប្រសើរជាងមុន សេវាសុខាភិបាលល្អជាងមុន និង កំណើនការចូលរៀនផងដែរ។

ទោះជាយ៉ាងនេះក្តី មានការទទួលស្គាល់តិចតួចប៉ុណ្ណោះ ចំពោះការពិតដែលថាការរីកចម្រើននូវសុខុមាលភាពរបស់កុមារ ជាកម្លាំងចលករឲ្យមានកំណើនសេដ្ឋកិច្ចយ៉ាងលឿនរបស់កម្ពុជា។ ក្នុងរយៈកាល ៣០ ឆ្នាំចុងក្រោយនេះ រាល់ប្រជាជនកម្ពុជាជំនាន់ថ្មីមួយជំនាន់ៗ  បានទទួលការអប់រំប្រសើរជាងមុន មានលទ្ធភាពទទួលបានសេវាសុខាភិបាលល្អជាងមុន និងអាហារូបត្ថម្ភល្អជាងមនុស្សជំនាន់មុនរបស់ខ្លួន។ ដោយសារតែលទ្ធផលកាន់តែល្អប្រសើរនេះហើយ ទើបប្រជាជនកម្ពុជាកាន់តែមានជំនាញជាងមុន មានសុខភាព ល្អជាងមុន មានចំណេះដឹង និងមានភាពធនជាងមនុស្សជំនាន់មុនខ្លួន។ ក្នុងនាមជា អ្នកបំពេញការងារ ពួកគេបាន ផ្តល់ដល់ប្រទេសនូវកម្លាំងពលកម្មដែលមានផលិតភាពបត់បែន និងភាព ច្នៃប្រឌិតជាងមុន ធ្វើឲ្យកំណើនសេដ្ឋកិច្ចកាន់ តែរឹងមាំខ្លាំងឡើង និងស្ថិតស្ថេរថែមទៀត។ ធនាគារពិភពលោកបានហៅកម្លាំងពលកម្មដែលមានជំនាញសុខភាពល្អ និងធន់មាំនេះថាជា ធនធានមនុស្ស ហើយចាត់ទុកថា ជា “កម្លាំងចលករស្នូលនៃកំណើនប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ” [2]។

## ឧបសគ្គដែលជួបប្រទះលើផ្លូវឆ្ពោះទៅរកវិបុលភាព

ពេលនេះ ប្រទេសកម្ពុជាមានចក្ខុវិស័យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ឲ្យបានត្រឹមឆ្នាំ ២០៣០ ហើយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ក្តីប្រាថ្នានេះនឹងតម្រូវឲ្យមានការរក្សា  និងការប្រឹងប្រែងពង្រឹងកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ដូច្នេះឲ្យបាន ៣០ ឆ្នាំទៀត។ ការវិភាគទៅលើផ្លូវឆ្ពោះទៅមុខបានបង្ហាញថា ឧបសគ្គធំៗចំនួនពីរទាក់ទងនឹងសិទ្ធិកុមារដែលនឹងបង្កការលំបាកដល់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍ធនធាន មនុស្ស ដែលខ្លួនត្រូវការដើម្បីសម្រេចឲ្យបានគោលដៅខាងលើនេះ។

ឧបសគ្គទីមួយគឺទាក់ទងទៅនឹងការបែករំលែកមិនស្មើភាពនូវអត្ថប្រយោជន៍  ដែលបានមកពីវឌ្ឍនភាពដែលសម្រេចបានក្នុងរយៈកាល ៣០ ឆ្នាំកន្លងទៅ។ ទិន្នន័យដែលមានបានបង្ហាញថា ក្រុមនានា នៃកុមារកម្ពុជាមិនបានឃើញពីវឌ្ឍនភាពជាដុំកំភួនឡើយ នៅក្នុងការទទួលបានសិទ្ធិរបស់ខ្លួន ដោយសារតែបញ្ហាកើតឡើងជាបន្តបន្ទាប់ទាក់ទងនឹងការបាត់ឱកាស ការរើសអើងឬឧបសគ្គដោយសារតែភូមិសាស្ត្រ ឬប្រាក់ចំណូល។ ជាលទ្ធផល ក្រុមកុមារទាំងនេះ នឹងពិបាកសម្រេចសក្តានុពលក្នុងជីវិតរបស់ខ្លួនឲ្យបានពេញលេញ ហើយនេះជាផលវិបាកមួយបន្ថែមទៀតដែលនឹងធ្វើឲ្យប្រទេសបាត់បង់កម្លាំងពលកម្មមួយផ្នែកដែលមានភាពច្នៃប្រឌិត ប្រកបដោយថាមពល និងមានការអប់រំ ដែលមានតម្លៃដើម្បីសម្រេចបាននូវវត្ថុបំណងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជារាប់ទសវត្សតទៅមុខទៀត។ ឧបសគ្គទីពីរគឺការសម្របខ្លួនទៅតាមបញ្ហាប្រឈមថ្មី និងកំពុងលេចឡើងនៅក្នុងប្រទេសកម្ពុជា។ បរិបទដែលមានការផ្លាស់ប្តូរយ៉ាងលឿននៅក្នុងប្រទេសកម្ពុជា មានដូចជា ការចំណាកស្រុក បម្រែបម្រួលអាកាសធាតុ ទេសចរណ៍ និងបច្ចេកវិទ្យា។ បើទោះបីជាកត្តាមួយចំនួនក្នុងចំណោមកត្តាទាំងអស់នេះពិតជាផ្តល់ឱកាសសម្រាប់ប្រទេសកម្ពុជាក្តី ប៉ុន្តែកត្តាទាំងនេះក៏រួមចំណែកបង្កើនភាពងាយរងគ្រោះ និងការកេងប្រវ័ញ្ចមកលើកុមារផងដែរ។ បញ្ហាប្រឈមថ្មីៗទាំងនេះ កំពុងតែមានផលប៉ះពាល់

1 World Bank Group, 2017: កម្ពុជា - ការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំដើម្បីប្រយោជន៍ទាំងអស់គ្នា
2 Lange, Glenn-Marie; Wodon, Quentin; Carey, Kevin, 2018: ការបម្រែបម្រួលអាកាសធាតុជាតិ២០១៨៖ការកសាងអនាគត់ដែលមាននិរន្តរភាព

រួចហើយមកលើសុខុមាលភាពរបស់កុមារ ហើយប្រសិនបើពុំមានការដោះស្រាយទេនោះ បញ្ហាប្រឈមទាំងនេះនឹងបង្អាក់បន្ថែមទៀតដល់ការអភិវឌ្ឍន៍ធនធានមនុស្សដែលចាំបាច់សម្រាប់ការសម្រេចបាននូវវត្ថុបំណងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

## កត្តាកែប្រែ (Game Changers) ដែលកុមារកម្ពុជាត្រូវការ

របាយការណ៍នេះបង្ហាញពីផ្នែកអាទិភាពចំនួន ៦ សម្រាប់ការវិនិយោគទៅលើសិទ្ធិកុមារ ដែលអាចជំនះលើឧបសគ្គធំៗទាំងពីរខាងលើ ពោលគឺវិសមភាព និងបរិបទប្រែប្រួលលឿន។ ដោយត្រូវបានកំណត់ថាជា “កត្តាកែប្រែ” អាទិភាពទាំងនេះតំណាងឲ្យការផ្លាស់ប្តូរនូវរបៀបរបបក្នុងការអនុវត្តនាពេលបច្ចុប្បន្ន ដែលនឹងត្រូវការការដឹកនាំ ធនធាន និងការតាំងចិត្តដើម្បីសម្រេចឲ្យបាន។ អនុសាសន៍ដែលមានរៀបរាប់នៅក្នុងរបាយការណ៍នេះ ត្រូវបានដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! ទទួលស្គាល់ពីភាពចាំបាច់នៃវិធានការរួម និងការសម្របសម្រួលដើម្បីសម្រេចឲ្យបាននូវការអនុវត្តពេញលេញតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ តាមរយៈរបាយការណ៍នេះ និងអនុសាសន៍នានា យើងសង្ឃឹមថា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលផ្សេងទៀត អ្នកសិក្សាស្រាវជ្រាវ និងវិស័យឯកជន នឹងមើលឃើញពីក្របខ័ណ្ឌមានប្រយោជន៍សម្រាប់សម្របសម្រួលឲ្យមានកិច្ចខិតខំ ប្រឹងប្រែងដើម្បីលើកកម្ពស់សុខុមាលភាពរបស់កុមារ និងដោះសោរអនាគតកម្ពុជា។

| | |
|---|---|
| ១. កែលម្អលទ្ធភាពទទួលបានសេវាអប់រំកុមារតូច ដែលមានគុណភាព | ថ្វីដ្បិតតែសេវាអប់រំកុមារតូចដែលមានគុណភាព មានការទទួលស្គាល់ថាជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់ការសិក្សាទៅថ្ងៃអនាគត និងការអភិវឌ្ឍន៍ធនធាន មនុស្សក្តីកុមារជាច្រើននៅតែបន្តមិនមានលទ្ធភាពទទួលបានសេវាអប់រំបែបនេះ ជាពិសេសនៅតាមទីជនបទ ដាច់ស្រយាល។ |
| ២. ប្រយុទ្ធប្រឆាំងនឹងកង្វះលទ្ធភាពទទួលបានការអប់រំ ប្រកបដោយ គុណភាព | ប្រទេសកម្ពុជាបានសម្រេចបាននូវវឌ្ឍនភាពនៃការអប់រំមូលដ្ឋានក្នុងកម្រិតសឹងមិនគួរឲ្យជឿ ប៉ុន្តែ វឌ្ឍនភាពឲ្យខ្លាំងជាងនេះបន្ថែមទៀតរងការគំរាមកំហែងដោយសារឧបសគ្គជាបន្តបន្ទាប់ ដែលរាំងខ្ទប់ដល់លទ្ធភាពទទួលបានសេវាអប់រំដែលមានគុណភាព និងលទ្ធផលសិក្សារៀនសូត្រដែលមានគុណភាពទាប។ |
| ៣. ដោះស្រាយបញ្ហាកិច្ចការពារកុមារដែលមានអត្រាខ្ពស់ | កុមារប្រឈមនឹងបញ្ហាការពារកុមារជាច្រើន រួមមាន ការបែកចេញពីក្រុមគ្រួសារ ការទុកចោលមិនអើពើ និងការកេងប្រវ័ញ្ច និងអំពើហិង្សាដែលកើតមានក្នុងមជ្ឈដ្ឋានផ្សេងៗ រួមមាននៅផ្ទះ សាលារៀន និងមណ្ឌលថែទាំជាដើម។ |
| ៤. កាត់បន្ថយឲ្យបានច្រើនបំផុតនូវអត្រាកុមារខ្វះអាហារូបត្ថម្ភ | ចំនួនកុមារ ដែលខ្វះអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជាមានការកាត់បន្ថយក្នុងរយៈកាលប៉ុន្មានឆ្នាំមកនេះ ។ ទោះបីជាយ៉ាងនេះក្តី អត្រាវឌ្ឍនភាពនៅតែមានភាពយឺតយ៉ាវមិនអាចទទួលយកបាន  ហើយបន្តគំរាមកំហែងដល់ការអភិវឌ្ឍន៍ធនធានមនុស្សថែមទៀតផង។ |
| ៥. កែលម្អលទ្ធភាពទទួលបានសេវាទឹកផឹកមូលដ្ឋាន និងអនាម័យ | ប្រជាជនកម្ពុជាប្រមាណ ៩,៤ លាននាក់មិនមានលទ្ធភាពទទួលបានអនាម័យល្អប្រសើរឡើយ  ដែលជាអត្រាមួយខ្ពស់បំផុតក្នុងតំបន់អាស៊ី |
| ៦. បង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់កុមារក្នុងដំណើរការនៃការសម្រេចចិត្ត | ការចូលរួមមានកម្រិតរបស់កុមារ និងយុវជននៅក្នុងការរៀបចំគោលនយោបាយ និងការសម្រេចចិត្តផ្សេងៗដែលប៉ះពាល់មកលើជីវិតរបស់ពួកគេ បានរារាំងពួកគេមិនឲ្យដើរតួនាទីក្នុងនាមជា ពលរដ្ឋដែលអាចជួយ គាំទ្រដល់ការអភិវឌ្ឍន៍របស់កម្ពុជានាពេលអនាគត។ |

# ៣០ ឆ្នាំនៃវឌ្ឍនភាពដ៏សម្បើម ក្នុងប្រទេសកម្ពុជា

កាលពី ៣០ ឆ្នាំមុន ថ្នាក់ដឹកនាំពិភពលោកបានធ្វើការប្តេជ្ញាចិត្តជាប្រវត្តិសាស្រ្តចំពោះកុមារទូទាំងពិភពលោក តាមរយៈការអនុម័តលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) ដែលជាកិច្ចព្រមព្រៀងអន្តរជាតិមួយស្តីពីសិទ្ធិកុមារ។ ចាប់តាំង ពីពេលនោះមក វាបានក្លាយជាអនុសញ្ញាសិទ្ធិមនុស្សមួយដែលមានការធ្វើ សច្ចាប័នយ៉ាងទូលំទូលាយជាងគេបំផុតនៅក្នុងប្រវត្តិសាស្រ្ត ហើយបានជួយកែប្រែជីវិតរបស់កុមារជុំវិញពិភពលោកតាមរយៈការផ្តល់នូវគោលនយោបាយការពារកុមារមិនថាគេជានរណា ឬមកពីទីណានោះទេ។

ចាប់តាំងពីមានការព្រមព្រៀងលើ UNCRC នៅក្នុងឆ្នាំ ១៩៨៩ មក ប្រទេសកម្ពុជាបានឆ្លងកាត់ការប្រែប្រួលយ៉ាងលឿន និងយ៉ាងគំហុក។ នៅក្នុងទសវត្ស ១៩៧០ កម្ពុជាឆ្លងកាត់នូវជំលោះយ៉ាងធ្ងន់ធ្ងរ ហើយនាំឲ្យកើតមាននូវរបបខ្មែរក្រហម ដែលមានអំពើហិង្សា និងភាពកំណាចឃោរឃៅយ៉ាងខ្លាំងមកលើពលរដ្ឋ រួមទាំងកុមារផង។ ចលាចលនយោបាយបានអូសបន្លាយពេលរហូតដល់ទសវត្ស ១៩៩០ នៅពេលដែលកិច្ចព្រមព្រៀងទីក្រុងប៉ារីស (១៩៩១) និងការបោះឆ្នោតថ្នាក់ជាតិ (១៩៩៣) បាននាំមកនូវយុគសម័យថ្មីសម្រាប់ប្រទេសកម្ពុជារាប់បញ្ចូលទាំងកំណើនសេដ្ឋកិច្ចយ៉ាងលឿន ដែលនាំមកនូវអត្ថប្រយោជន៍ធំធេងសម្រាប់ប្រជាជនកម្ពុជាភាគច្រើន។

បន្ទាប់ពីបានផ្តល់ សច្ចាប័នលើ UNCRC នៅឆ្នាំ ១៩៩២ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តជាផ្លូវការលើលិខិតូបករណ៍អន្តរជាតិសំខាន់ៗមួយភាគធំ សម្រាប់សិទ្ធិកុមារ រាប់បញ្ចូលទាំង ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ទាក់ទងនឹងការលក់កុមារ ពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ ដែលត្រូវបានផ្តល់សច្ចាប័ននៅឆ្នាំ ២០០២; ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារស្តីពី ការយកកុមារចូលរួមក្នុងជម្លោះប្រដាប់អាវុធ ដែលត្រូវបានផ្តល់ សច្ចាប័ននៅឆ្នាំ ២០០៤ អនុសញ្ញា ILO ១៨២ ទាក់ទងនឹងការហាមឃាត់ និងវិធានការបន្ទាន់សម្រាប់ការលុបបំបាត់ទំរង់អាក្រក់បំផុតនៃពលកម្មកុមារ ដែលត្រូវបានផ្តល់សច្ចាប័ននៅឆ្នាំ ២០០៦។ មាត្រា ៣១ និង ៤៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាក៏ទទួលស្គាល់ពីសិទ្ធិរបស់កុមារ រាប់បញ្ចូលទាំងសិទ្ធិរស់រានមានជីវិត សិទ្ធិអប់រំ សេរីភាពរួចផុតពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬផ្លូវភេទ។ នៅក្នុងឆ្នាំ ១៩៩៥ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលគោលនយោបាយ និងកម្មវិធីនានាទាក់ទងនឹងកុមារ។ [3]

## សមិទ្ធផលជាប្រវត្តិសាស្រ្តសម្រាប់សិទ្ធិកុមារ

ចាប់តាំងពីឆ្នាំ ១៩៩០ និងពេញមួយអាយុកាលរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ [4] (MDGs) ប្រទេសកម្ពុជាបានសម្រេចបាននូវវឌ្ឍនគួរឲ្យកត់សម្គាល់លើចំនុចដៅ និងសូចនាករដែលអាចវាស់បានទាក់ទងនឹងការអភិវឌ្ឍន៍កុមារ និងសិទ្ធិកុមារ ។ រាប់ចាប់ពីលទ្ធភាពទទួលបានការអប់រំ រហូតដល់ការកាត់បន្ថយអត្រាមរណភាពកុមារបានយ៉ាងច្រើននោះ ប្រទេសកម្ពុជាបានក្លាយជាគំរូដ៏រឹងមាំមួយដើម្បីបង្ហាញឲ្យឃើញថា វឌ្ឍនភាពក្នុងល្បឿនលឿនគឺអាចសម្រេចបាន នៅពេលដែលសិទ្ធិកុមារត្រូវបាន រដ្ឋាភិបាល ម្ចាស់ជំនួយ តួអង្គសង្គមស៊ីវិល និងពលរដ្ឋខ្លួនឯងផ្តល់អាទិភាព។ រូបភាពទី ១ បង្ហាញអំពីសមិទ្ធផលសំខាន់ៗបំផុតកាលពីប៉ុន្មានទសវត្សមុន។

3 ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបានបង្កើតឡើង (រៀបចំហេដ្ឋារចនាសម្ព័ន្ធឡើងវិញនៅឆ្នាំ ២០០៩) ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការងារសម្របសម្រួលលើកិច្ចខិតខំប្រឹងប្រែងផ្សេងៗ ទាក់ទងនឹងការរស់រាន ការអភិវឌ្ឍន៍ និងការការពារកុមារ និងការចូលរួមរបស់កុមារ រាប់បញ្ចូលទាំងការពិនិត្យតាមដានលើការអនុវត្ត UNCRC និងការរៀបចំរបាយការណ៍ ដាក់ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិសម្រាប់ UNCRC ផងដែរ។

4 គោលដៅអភិវឌ្ឍន៍សហស្សវត្សគឺជាទិសដៅដែលអាចវាស់វែងបានចំនួន 8 និងបញ្ជាក់ពីឱ សានវាទច្បាស់លាស់សម្រាប់ការលើកកម្ពស់ជីវភាពរស់នៅរបស់ ប្រជាជនក្រីក្របំផុតក្នុងពិភពលោក ឲ្យទាន់ចន្លោះពីឆ្នាំ ២០០០ ដល់ ២០១៥។ ក្របខ័ណ្ឌនេះបានជួយបង្រួបបង្រួម រដ្ឋាភិបាលនានា ម្ចាស់ជំនួយ សង្គមស៊ីវិល និងប្រជាពលរដ្ឋ ដើម្បីឆ្ពោះទៅរកសមិទ្ធិផលប្រកបដោយមហិច្ឆតាក្នុងការកាត់បន្ថយភាពក្រីក្រ កាត់បន្ថយភាពអត់ឃ្លាន លើកកម្ពស់អនាម័យការអប់រំជាសកល និងការងារជាច្រើនទៀត។

## រូបភាពទី ១៖ វឌ្ឍនភាពដែលអាចវាស់វែងបានសម្រាប់សិទ្ធិកុមារ និងការអភិវឌ្ឍន៍របស់កុមារចាប់តាំងពីដើមទសវត្ស ១៩៩០

### អត្រាមរណភាពរបស់កុមារ

**១១៦ នាក់ក្នុងចំណោមទារក**
កើតរស់ ១០០០ នាក់ ក្នុងឆ្នាំ ១៩៩២

**៣០,៦ នាក់ក្នុងចំណោមទារក**
កើតរស់ ១០០០ នាក់ ក្នុងឆ្នាំ ២០១៦

### អត្រាមរណភាពមាតា

**៨៩៦ ក្នុងចំណោមទារក**
កើតរស់ ១០០.០០០ នាក់ក្នុងឆ្នាំ ១៩៩២

**១៦១ ក្នុងចំណោមទារក**
កើតរស់ ១០០.០០០ នាក់ក្នុងឆ្នាំ ២០១៥

### ក្រិសក្រិន (CDHS ២០១៤)

**៥៨,៦%**
ក្នុងឆ្នាំ ១៩៩៦

**៣២,៤%**
ក្នុងឆ្នាំ ២០១៤

### ការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា

**៨៣%**
ក្នុងឆ្នាំ ១៩៩៤

**៩៨%**
ក្នុងឆ្នាំ ២០១៦

### អត្រាភាពក្រីក្រ (ធនាគារពិភពលោក)

**៤៧,៨%**
ក្នុងឆ្នាំ ២០០៧

**១៣,៥%**
ក្នុងឆ្នាំ ២០១៤

**ចំណូលជាតិសរុប ( GNI ) ក្នុងមួយនាក់**

| | |
|---|---|
| **២៥០ USD** | **១.៣៨០ USD** |
| ក្នុងឆ្នាំ ១៩៩៥ | ក្នុងឆ្នាំ ២០១៨ |

**ប្រជាជនបន្ទោរបង់ពាសវាលពាសកាល**

| | |
|---|---|
| **៨២% នៃចំនួនប្រជាជនសរុប** | **៤០,៦% នៃចំនួនប្រជាជនសរុប** |
| ក្នុងឆ្នាំ ២០០០ | ក្នុងឆ្នាំ ២០១៥ |

**ករណីជំងឺគ្រុនចាញ់ ( WHO/UNICEF )**

| | |
|---|---|
| **៣៥,៧ ក្នុងចំណោមប្រជាជន** | **១៨,៤ ក្នុងចំណោមប្រជាជន** |
| ងាយរងគ្រោះ ១០០០ នាក់ ក្នុងឆ្នាំ ២០១០ | ងាយរងគ្រោះ ១០០០ នាក់ ក្នុងឆ្នាំ ២០១៧ |

**លទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់**

| | |
|---|---|
| **១៦,៦% នៃប្រជាជនសរុប** | **៨៩,១% នៃប្រជាជនសរុប** |
| ក្នុងឆ្នាំ ២០០០ | ក្នុងឆ្នាំ ២០០០ |

វាជាចំនុចសំខាន់ដែល ត្រូវកត់សម្គាល់ថា ក្នុងរយៈពេលមិនដល់ ៣ ទសវត្សទេ ដែលកម្ពុជាអាចសម្រេចបាននូវអ្វីដែលបណ្តាប្រទេសជាច្រើនចំណាយពេលរហូតដល់ទៅមួយសតវត្ស ដើម្បីសម្រេចបាន។ ឧទាហរណ៍ ប្រទេសហ្វាំងឡង់ ចំណាយពេល ១០០ ឆ្នាំ ( ១៨៥០ ដល់ ១៩៥០ ) [5] ដើម្បីសម្រេចបាននូវការកាត់បន្ថយអត្រាមរណភាពមាតាក្នុងកម្រិតដូចគ្នានឹងប្រទេសកម្ពុជាដែលបានធ្វើកិច្ចការនេះតាំងពីដើមទសវត្ស ១៩៩០។ ស្រដៀងគ្នានេះដែរ ប្រទេសចិនចំណាយពេល៣៤ឆ្នាំ ហើយប្រទេសឥណ្ឌូនេស៊ីចំណាយពេល ៣៣ឆ្នាំដើម្បីសម្រេចឲ្យបាននូវការកាត់បន្ថយ អត្រាមរណភាពកុមារ ក្នុងកម្រិតដែលកម្ពុជាអាចសម្រេចបានត្រឹមតែ២០ឆ្នាំប៉ុណ្ណោះ ពោលគឺធ្លាក់ចុះពី ១២% មកនៅត្រឹមក្រោម ៣% [6]។

5 Claudia Hanson. ទិន្នន័យស្តីពីអត្រាមរណភាពមាតា ព័ត៌មានប្រវត្តិសាស្ត្រចងក្រងសម្រាប់១៤ ប្រទេស (រហូតដល់ទៅ ២០០ឆ្នាំ, Gapminder, ២០១០

6 WHO, UNICEF, UNFPA, World Bank Group, and the United Nations Population Division. និន្នាការនៃអត្រាមរណភាពមាតា៖ ១៩៩០ ដល់ ២០១៥. ទីក្រុងហ្សឺណែវ អង្គការសុខភាពពិភពលោក, ២០១៥ និង Claudia Hanson, ២០១០, ទិន្នន័យស្តីពីអត្រាមរណភាពមាតា ព័ត៌មានប្រវត្តិសាស្ត្រចងក្រងសម្រាប់ ១៤ ប្រទេស (រហូតដល់ទៅ ២០០ ឆ្នាំ, Gapminder, ២០១០

## ការវិនិយោគលើសិទ្ធិកុមារ និងកំណើនសេដ្ឋកិច្ច

ច្បាស់ណាស់ វឌ្ឍនភាពនេះមួយចំណែកធំគឺដោយសារតែសមិទ្ធផលផ្នែកសេដ្ឋកិច្ចដ៏គួរឲ្យស្ញប់ស្ញែងរបស់កម្ពុជា ក្នុងរយៈកាល ២០ ឆ្នាំមកនេះ។ ចាប់តាំងពីឆ្នាំ ១៩៩៥ ដល់ ២០១៧ កម្ពុជាសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំក្នុងកម្រិត ៧,៧% ដែលជាកំណើនសេដ្ឋកិច្ចក្នុងល្បឿនលឿនបំផុតលំដាប់ទី ៦ ក្នុងពិភពលោក។ ជាលទ្ធផល អត្រានៃភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨% នៅឆ្នាំ ២០០៧ មកនៅត្រឹម ១៣,៥% ក្នុងឆ្នាំ ២០១៤ [7] ហើយប្រទេសកម្ពុជាបានសម្រេចជាផ្លូវការនូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ ២០១៥ [8]។ ក្នុងរយៈពេលនោះដែរ ប្រទេសកម្ពុជាបានមើលឃើញ នូវវឌ្ឍនភាពយ៉ាងខ្លាំងក្លាសម្រាប់សូចនាករជាច្រើនទាក់ទងនឹងការអភិវឌ្ឍន៍កុមារ និងមនុស្ស។

ខណៈដែលក្រុមគ្រួសារជាច្រើន ជំនះលើភាពក្រីក្រ ពួកគេក៏មានលទ្ធភាពបន្ថែមក្នុងការវិនិយោគលើសុខុមាលភាព កូនៗរបស់ពួកគេ តាមរយៈការបង្កើនអាហារូបត្ថម្ភ លទ្ធភាពទទួលបានសេវាសុខាភិបាល ហើយបញ្ជូនកូនទៅសាលារៀន ជាជាងបញ្ជូនពួកគេទៅធ្វើការ។ រាជរដ្ឋាភិបាលកម្ពុជា ក៏មានលទ្ធភាពក្នុងការប្រមូលពន្ធច្រើនជាងមុន គៀងគរធនធានបានច្រើនជាងមុន និងវិនិយោគកាន់តែមានប្រសិទ្ធផលលើផ្នែកសុខាភិបាល អាហារូបត្ថម្ភ អប់រំ និងការការពារកុមារ។

ទោះបីជាយ៉ាងនេះក្តី មានការទទួលស្គាល់តិចតួចប៉ុណ្ណោះចំពោះកាពិតមួយ គឺថា វឌ្ឍនភាពនៃសិទ្ធិរបស់កុមារ ជាកម្លាំងចលករឲ្យមានកំណើនសេដ្ឋកិច្ចយ៉ាងលឿនរបស់កម្ពុជា។ ក្នុងរយៈកាល ៣០ ឆ្នាំចុងក្រោយនេះ រាល់ប្រជាជនកម្ពុជាជំនាន់ថ្មីមួយជំនាន់ៗ បានទទួលការអប់រំប្រសើរជាងមុន មានលទ្ធភាពទទួលបានសេវាសុខាភិបាលល្អជាងមុន និងអាហារូបត្ថម្ភល្អជាងមនុស្សជំនាន់មុនរបស់ខ្លួន។

ដោយហេតុនេះហើយ ទើបប្រជាជនកម្ពុជាកាន់តែមានជំនាញជាងមុន មានសុខភាពល្អជាងមុន មានចំណេះដឹងនិងមានភាពជន់ជាងមនុស្សជំនាន់មុនខ្លួន។ ជាលទ្ធផលក្នុងនាមជាអ្នកបំពេញការងារ ពួកគេបានផ្តល់ដល់ប្រទេសកម្ពុជានូវកម្លាំងពលកម្ម ដែលកាន់តែមានផលិតភាព មានភាពបត់បែន និងភាពច្នៃប្រឌិតជាងមុន ធ្វើឲ្យកំណើនសេដ្ឋកិច្ចកាន់តែរឹងមាំខ្លាំងឡើង និងស្ថិតស្ថេរថែមទៀត។

ធនាគារពិភពលោកបានហៅកម្លាំងពលកម្មដែលមានជំនាញ សុខភាពល្អ និងជន់មាំនេះថាជា ធនធានមនុស្ស ហើយចាត់ទុកថា ជា “កម្លាំងចលករស្នូលនៃកំណើនប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ” [9]។ កុមារបច្ចុប្បន្នគឺជាម៉ូទ័រនៃសេដ្ឋកិច្ចថ្ងៃស្អែក ដូច្នេះការបន្ថែមការវិនិយោគ លើសិទ្ធិកុមារគឺមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការអភិវឌ្ឍន៍ធនធានមនុស្ស និងកំណើនសេដ្ឋកិច្ចដើម្បីបន្តអភិវឌ្ឍន៍ប្រទេស។

# ផ្លូវឆ្ពោះទៅរកឆ្នាំ ២០៣០

## ចក្ខុវិស័យត្រឹមត្រូវ

កម្ពុជាមានចក្ខុវិស័យ ក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់ឲ្យបាននៅឆ្នាំ ២០៥០។ ដំណាក់កាលបន្ទាប់សម្រាប់កម្ពុជា គឺឆ្នាំ ២០៣០ ជាពេលដែលកម្ពុជាប្រឹងប្រែងដើម្បីក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ក៏ដូចជាសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍ ប្រកបដោយចីរភាពកម្ពុជា (CSDGs)។ ការអនុម័តលើ CSDGs ក្នុងឆ្នាំ ២០១៨ គឺជាជំហានដ៏សំខាន់ឆ្ពោះទៅរកការសម្រេចឲ្យបាននូវចក្ខុវិស័យនេះ ដែលមិនត្រឹមតែជួយរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏បន្តពង្រឹងធនធានមនុស្សដែលចាំបាច់ដើម្បីសម្រេចឲ្យបាននូវ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពផងដែរ។

CSDGs ត្រូវ បា នស្រង់ចេញពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ដែលជា “ការអំពាវនាវឲ្យមានវិធានការ” ជាសកល ដើម្បី “កាត់បន្ថយភាពក្រីក្រ ការពារភពផែនដី និងធានាថាមនុស្សគ្រប់គ្នាទទួលបានសន្តិភាព និងវិបុលភាព”។

SDGs ទាំង ១៧ មានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយតម្រូវឲ្យមាន “ភាពជាដៃគូ និងភាពប្រាកដនិយម ដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវនាពេលនេះ ដើម្បីលើកកម្ពស់ជីវិតរស់នៅសម្រាប់មនុស្សជំនាន់ក្រោយប្រកបដោយនិរន្តរភាព” [10]

7 World Bank Group, ២០១៧: កម្ពុជា - ការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំដើម្បីប្រយោជន៍ទាំងអស់គ្នា

8 តំណែងជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបធ្វើបានសម្រេច នៅពេលដែល ប្រាក់ចំណូលជាតិសរុប (GNI) ក្នុងមួយនាក់បានឈានដល់ ១.២៣០ ដុល្លារអាមេរិក; យោងតាម World Bank Group, ២០១៧: កម្ពុជា - ការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំដើម្បីប្រយោជន៍ទាំងអស់គ្នា

9 Lange, Glenn-Marie; Wodon, Quentin; Carey, Kevin, 2018: ការប្រែប្រួលធនធានរបស់ប្រទេសនានា ២០១៨: កសាងនូវអនាគតមួយប្រកបដោយចីរភាព។

10 UNDP Cambodia, ២០១៩. http://www.kh.undp.org/content/cambodia/en/home/sustainable-development-goals.html

CSDGs មានចំណុចដៅចំនួន ៨៨ ដែលនឹងជួយពង្រឹងដល់ស្ថាប័នរដ្ឋ (ស្របតាមទស្សនទានស្តីពីអភិបាលកិច្ចល្អ និងនីតិរដ្ឋ) និងគាំទ្រដល់ការងារកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងចីរភាព។

**ក្នុងនោះ ចំនុចដៅទាំងនេះ ស្របគ្នាយ៉ាងល្អ ជាមួយនឹង** UNCRC៖

- ចំណុចដៅ ២.២ ស្តីពីការបំបាត់រាល់ទម្រង់ទាំងអស់នៃកង្វះអាហារូបត្ថម្ភ
- ចំណុចដៅ ៤.១ និង ៤.២ ស្តីពីការផ្តល់ការអប់រំមូលដ្ឋាន និងមត្តេយ្យសិក្សាដល់គ្រប់កុមារទាំងអស់(រាប់បញ្ចូលទាំង ចំណុចដៅ ៤.ក. ស្តីពីការកសាងទីកន្លែងអប់រំដែលមានសុវត្ថិភាព និងបរិយាប័ន្នសម្រាប់ទាំងអស់គ្នា)
- ចំណុចដៅ ៦.១ និង ៦.២ ស្តីពីការទទួលបានជាសកលនូវទឹកស្អាតសម្រាប់ទទួលទាន និងអនាម័យគ្រប់គ្រាន់សម្រាប់ទាំងអស់គ្នា។

ភាពស៊ីសង្វាក់គ្នានេះធ្វើឲ្យ CSDGs ក្លាយជាក្របខ័ណ្ឌដ៏ត្រឹមត្រូវដើម្បីសម្រេចឲ្យបាននូវវឌ្ឍនភាពខ្លាំងក្លាឆ្ពោះទៅរកការអនុវត្ត UNCRC ហើយកសាងធនធានមនុស្ស ដែលកម្ពុជាត្រូវការដើម្បីសម្រេចឲ្យបាននូវវត្ថុបំណងផ្នែកសេដ្ឋកិច្ច និងផ្នែកអភិវឌ្ឍន៍របស់ខ្លួនសម្រាប់ឆ្នាំ ២០៣០ និង ២០៥០។

## ឧបសគ្គតាមផ្លូវឆ្ពោះទៅឆ្នាំ ២០៣០

ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យរបស់ខ្លួនសម្រាប់ឆ្នាំ ២០៣០ និង ២០៥០ ព្រមទាំងចំនុចដៅ CSDGs ប្រទេសកម្ពុជាចាំបាច់ត្រូវរក្សាឲ្យស្ថិតស្ថេរ និងពង្រឹងបន្ថែមនូវកំណើនសេដ្ឋកិច្ច ដែលមានម្រិតខ្ពស់នាពេលបច្ចុប្បន្ន ឲ្យបានក្នុងរយៈពេល ៣០ ឆ្នាំតទៅមុខទៀត។ ដូច្នេះ តម្រូវឲ្យប្រទេសកម្ពុជាត្រូវធានាថាកុមារជំនាន់ក្រោយៗ សម្រេចបាននូវសក្តានុពលរបស់ខ្លួនឲ្យបានពេញលេញ ហើយក្លាយជាកម្លាំងពលកម្មដែលមានជំនាញ ខ្ពស់ មានសុខភាពល្អ និងមានការអប់រំ ដែលអាចជួយអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសឲ្យឡើងមួយកម្រិតបន្ថែមទៀត។ បើក្រឡេកមើលកាលពី ៣០ ឆ្នាំកន្លងទៅ និងវឌ្ឍនភាពដ៏ខ្លាំងក្លាដែលកម្ពុជាបានសម្រេចបានក្នុងរយៈកាលកន្លងមកនេះ វាជាមូលហេតុដែលយើងមានក្តីសុទិដ្ឋិនិយម។ ទោះបីជាយ៉ាងនេះក្តី ការវិភាគចំពោះផ្លូវឆ្ពោះទៅមុខ ហាក់ចង្អុលបង្ហាញថា ប្រសិនបើពុំមានការកែប្រែគួរឲ្យកត់សម្គាល់ ចំពោះវិធីសាស្ត្រក្នុងការលើកកម្ពស់សុខុមាលភាពរបស់កុមារទេនោះ នោះកម្ពុជានឹងមិនអាចសម្រេចបាននូវវឌ្ឍនភាពផ្នែកសិទ្ធិកុមារ និងធនធានមនុស្សក្នុងកម្រិតដូចគ្នាកាលពីមុនឡើយ។ អ្នកសង្កេតការណ៍[11] ភាគច្រើនសុទ្ធតែយល់ស្របថា នៅក្នុងប្រទេសកម្ពុជា ឧបសគ្គធំៗចំនួនពីរទាក់ទងនឹងសិទ្ធិ និងសុខុមាលភាពកុមារកំពុងតែបង្កការរាំងស្ទះនៅតាមផ្លូវឆ្ពោះទៅរកការសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន។

### ១. វិសមធម៌នៃការបែងចែកផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច

ឧបសគ្គទីមួយគឺជាប់ទាក់ទងនឹងវិសមធម៌នៃការបែងចែកផលប្រយោជន៍ ពីវឌ្ឍនភាពដែលកើតមានក្នុងរយៈកាល ៣០ ឆ្នាំ មកនេះ។ ទិន្នន័យដែលមានបានបង្ហាញថា ក្រុមនានានៃកុមារកម្ពុជាមិនបានឃើញថាមានវឌ្ឍនភាពជាដុំកំភួនឡើយ នៅក្នុងការ ទទួលបានសិទ្ធិរបស់ខ្លួន ដោយសារតែបញ្ហាកើតឡើងជាបន្តបន្ទាប់ទាក់ទងនឹងការបាត់ឱកាសការរើសអើង ឬឧបសគ្គផ្សេងៗអាស្រ័យតាម ភូមិសាស្ត្រ។ របាយការណ៍នេះរកឃើញថា កុមារដែលរស់នៅទីជនបទ និងជនបទដាច់ស្រយាល កុមារដែលមកពីគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប កុមារជនជាតិដើមភាគតិច និងកុមារពិការ ជាដើម ពិបាកក្នុងការទទួលបានសិទ្ធិជាមូលដ្ឋានរបស់ខ្លួន។ ឧទាហរណ៍ [12]៖

- កុមាររស់នៅក្នុងទីក្រុងមានឱកាសបានចូលសិក្សាក្នុងកម្មវិធីអប់រំកុមារតូច ច្រើនជាងកុមាររស់នៅទីជនបទ (១១%)[13] រហូតដល់ទៅ ៣៦% ហើយកុមារអាយុ ៥ ឆ្នាំដែលស្ថិតនៅក្នុងក្រុមគ្រួសារក្រីក្របំផុត ងាយនឹងបោះបង់ចោលការសិក្សាជាងកុមារដែលមកពីក្រុមគ្រួសារអ្នកមាន រហូតដល់ទៅមួយដងកន្លះ ។[14]
- ៤% នៃក្មេងជំទង់ពិការបានរៀនចប់ថ្នាក់អនុវិទ្យាល័យ ធៀបនឹងក្មេងជំទង់មិនពិការ ដែលមានអត្រារៀនចប់អនុវិទ្យាល័យចំនួន ៤១% [15]
- ក្មេងស្រី បោះបង់ចោលការសិក្សា ញឹកញាប់ជាងក្មេងប្រុសដើម្បីជួយដល់ក្រុមគ្រួសាររបស់ពួកគេ ហើយក្មេងស្រីដែលមានការអប់រំតិចតួច ជាទូទៅរឹតតែងាយប្រឈមនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានដូចជាអំពើជួញដូរមនុស្សជាដើម [16]
- អាពាហ៍ពិពាហ៍នៅវ័យកុមារគឺជារឿងកើតមានច្រើននៅតាមទីជនបទ ខណៈដែល ភាពមានគភ៌នៅវ័យជំទង់ កំពុងមានការកើនឡើងនៅតាមតំបន់មួយចំនួននៃប្រទេសកម្ពុជាជាពិសេសនៅតាមទីជនបទដាច់ស្រយាល ។[17]

11 សូមមើល World Bank Group, ២០១៧: កម្ពុជា - ការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំដើម្បីប្រយោជន៍ទាំងអស់គ្នា
12 កត្តាកែប្រែ (Game Changer) នីមួយៗ ផ្តល់នូវការវិភាគកាន់តែលម្អិតទៅលើក្រុមកុមារផ្សេងៗ ដែលមិនបានទទួលអត្ថប្រយោជន៍ពេញលេញពីសិទ្ធិដែលបានធានានៅក្នុង UNCRC។
13 វិទ្យាស្ថានជាតិស្ថិតិ (NIS), អគ្គនាយកដ្ឋានសុខាភិបាល និង ICF International, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខាភិបាលកម្ពុជា ២០១៤, ទំព័រ ១៦៥.
14 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦: របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអណត្តិ ក្នុងឆ្នាំ ២០១៦ លើផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ និងការព្យាករណ៍រហូតដល់ឆ្នាំ ២០២០, ទំព័រ ១៨.
15 UNESCO, ២០១៨: ការអប់រំ និងពិការភាព៖ ការវិភាគលើទិន្នន័យពី ៤៩ ប្រទេស. ទំព័រ ២០ និងទំព័រ ២៣.
16 SOS Children’s Villages Cambodia, ២០១៥: ការវិភាគស្ថានភាពសិទ្ធិកុមារ៖ កុមារងាយរងគ្រោះក្នុងការបាត់បង់ការថែទាំពីឪពុកម្តាយ និងកុមារបាត់បង់ការថែទាំពីឪពុកម្តាយ និង Sonyka, Va 19 មីនា ២០១៥៖ “សិស្សនារីនៅថ្នាក់វិទ្យាល័យកាន់តែច្រើនឡើងបោះបង់ចោលការសិក្សា” កាសែត Khmer Times
17 ឧទាហរណ៍ ខេត្តមណ្ឌលគិរី និងរតនគិរី មានអត្រាខ្ពស់បំផុត ក្នុងប្រទេសកម្ពុជា សម្រាប់ការរៀបការនៅវ័យកុមារ និងភាពមានគភ៌នៅវ័យជំទង់។ អាយុជាមធ្យមសម្រាប់ការរៀបអាពាហ៍ពិពាហ៍នៅក្នុងខេត្តមណ្ឌលគិរី គឺ ១៥ ឆ្នាំ ហើយ ៣៤% នៃក្មេងស្រីជំទង់ ដែលមានអាយុចន្លោះពី ១៥ – ១៩ ឆ្នាំ ក្នុងខេត្តនេះ គឺមានកូនមួយ ខណៈដែលអត្រានៅថ្នាក់ជាតិជាមធ្យមគឺមានចំនួនត្រឹម ១២% ប៉ុណ្ណោះ (Partnering to Save Lives, ២០១៨: ឯកសារសិក្សា៖ ភាពមានគភ៌នៅវ័យជំទង់នៅភាគឥសាន្តប្រទេសកម្ពុជា, ជំនួយអូស្ត្រាលី, ក្រសួងសុខាភិបាល, អង្គការសង្គ្រោះកុមារ អង្គការ ឃែរ អន្តរជាតិ អង្គការ Marie Stopes International)

- ភាពក្រិសក្រិន គឺជារឿងកើតមានច្រើននៅតាមទីជនបទ (៣៤%) ជាងនៅទីក្រុង (២៤%) ហើយមិនសូវកើតមានឡើងក្នុងចំណោមកុមារ ដែលមានម្តាយដែលមានការអប់រំឡើយ។
- ថ្វីដ្បិតតែ សឹងតែ ៩៩% នៃក្រុមគ្រួសារនៅក្នុងរាជធានីភ្នំពេញមានបង្គន់ចុចទឹក ភ្ជាប់ជាមួយនឹងប្រព័ន្ធទឹកស្អុយក្តី ប៉ុន្តែ អត្រានេះមានចំនួនត្រឹមតែ ៧០,៩% ប៉ុណ្ណោះនៅទីជនបទ ដែលការបន្ទោរបង់ពាសវាលពាសកាល និងលទ្ធភាពទទួលបានទឹកដែលមានសុវត្ថិភាពប្រើប្រាស់នៅតែជាបញ្ហាធំ
- ទិន្នន័យដែលមានហាក់បង្ហាញថា និន្នាការនេះកំពុងស្ទុះឡើង ដែលជំរុញដោយវិសមភាពនៃប្រាក់ចំណូល [18] ដែលវិសមភាពនេះកំពុងកើនឡើងយ៉ាងលឿន និងភាពយឺតយ៉ាវ នូវវឌ្ឍនភាព [19] នៃការការចំណាយសាធារណៈ និងគោលនយោបាយពន្ធដារ [20]។

ជាលទ្ធផល កុមារទាំងនេះនឹងមានការពិបាកក្នុងការសម្រេចឲ្យបានពេញលេញនូវសក្តានុពលក្នុងជីវិតរបស់ខ្លួន ហើយជាផលវិបាក ពួកគេនឹងមិនអាចរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជាឲ្យបានច្រើនឡើយ ដែល តាមពិតពួកគេអាចរួមចំណែកបាន ប្រសិនបើពួកគេអាចសម្រេចបាននូវសិទ្ធិពេញលេញរបស់ខ្លួន។ ដូច្នេះ វានឹងធ្វើឲ្យប្រទេសកម្ពុជាបាត់បង់កម្លាំងពលកម្មមួយផ្នែកដែលមាននភាពច្នៃប្រឌិត ប្រកបដោយថាមពល និងមានការអប់រំ ដែលមានតម្លៃដើម្បីសម្រេចបាននូវវត្ថុបំណងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសរាប់ទសវត្សតទៅមុខទៀត [21]។

## ២. ការសម្របខ្លួនទៅតាមបញ្ហាប្រឈមថ្មីៗ និងទើបលេចឡើង

នៅទសវត្សខាងមុខ ប្រទេសកម្ពុជានឹងជួបបញ្ហាប្រឈមថ្មីៗ ដែលខុសគ្នាឆ្ងាយនឹងអ្វីដែលបានប្រឈមនាពេលសព្វថ្ងៃ និងកាលពីអតីតកាល ដូច្នេះ រូបមន្ត និងយុទ្ធសាស្ត្រ ដែលធ្លាប់តែទទួលបានជោគជ័យតាំងពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១៩ មិនទំនងថា នឹងជួយឲ្យសម្រេចបាននូវវឌ្ឍនភាពដូចមុនឡើយ សម្រាប់ពីឆ្នាំ ២០២០ ដល់ ២០៣០។ ឧទាហរណ៍៖

- ការកើនឡើងនូវលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា បានសម្រួលឲ្យមាននភាពច្នៃប្រឌិត និងការរីកលូតលាស់ ក៏ប៉ុន្តែ ក៏បានបង្កើតឲ្យមាននូវមូលដ្ឋានថ្មីៗសម្រាប់ការកេងប្រវ័ញ្ចលើកុមារផងដែរ។
- ថ្វីដ្បិតតែ វិស័យទេសចរណ៍ បានក្លាយជាវិស័យដ៏សំខាន់បំផុតមួយនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្តី ប៉ុន្តែ វាក៏បានរួមចំណែកធ្វើឲ្យកើនឡើងនូវការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមវិធីសម្ងាត់ផងដែរ [22]។
- ក្រុមគ្រួសារប្រជាជនកំពុងតែធ្វើចំណាកស្រុកទាំងក្នុងប្រទេស និងទៅក្រៅប្រទេស កាន់តែច្រើនឡើង ដើម្បីស្វែងរកឱកាសការងារដែលល្អប្រសើរ ដែលក្នុងនោះ កុមារកាន់តែច្រើនឡើងៗត្រូវបានទុកចោល ឬត្រូវធ្វើចំណាកស្រុកជាមួយនឹងក្រុមគ្រួសាររបស់ខ្លួន ធ្វើឲ្យប្រឈមនឹងការបោះបង់ចោលសាលារៀន និងការរំលោភបំពាន។
- បម្រែបម្រួលអាកាសធាតុ តាមរយៈការកើនឡើងរាប់សិបដងនូវហេតុការណ៍អាកាសធាតុអាក្រក់ៗ ទំនងនឹងបង្កផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើសន្តិសុខស្បៀង ការអប់រំ និងលទ្ធភាពទទួលបានទឹក និងអនាម័យ។

- ជាមួយនឹងស្ថានភាព ថ្មីក្នុងនាមជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប កម្ពុជា នឹងទទួលបានជំនួយអភិវឌ្ឍន៍តិចទៅៗពីម្ចាស់ជំនួយអន្តរជាតិ ដែលធ្លាប់តែជួយគាំទ្រដល់សេវាសំខាន់ៗ សម្រាប់កុមារ និងសហគមន៍របស់ខ្លួន តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ឬដៃគូអភិវឌ្ឍន៍ ។


@ Childfund cambodia

បញ្ហាប្រឈមថ្មីៗទាំងនេះមិនមែនឆ្លុះបញ្ចាំងពីបរាជ័យ ឬកង្វះវឌ្ឍនភាពឡើយ ប៉ុន្តែឆ្លុះបញ្ចាំងពីបញ្ហាប្រឈមជាបន្តបន្ទាប់ដែលប្រទេសជាតិទាំងអស់ជួបប្រទះ ក្នុងកិច្ចខិតខំប្រឹងប្រែងសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព នៅក្នុងបរិបទដែលមានការផ្លាស់ប្តូរយ៉ាងលឿន។

18 យោងតាមអង្គការ UNDP, ក្រោមកម្មវិធី “ប្រកបកិច្ចការដូចប្រក្រតី” អ្នកមានទ្រព្យសម្បត្តិកំពូលលើសកលលោកដែលមានមួយភាគរយ នឹងកើនឡើងដល់ ៣៩% នៅឆ្នាំ ២០៥០ ។ អាចអាននៅត្រង់នេះ https://www.kh.undp.org/content/cambodia/en/home/sustainable-development-goals/goal-10-reduced-inequalities.html

19 វាជារឿងសំខាន់ដែលត្រូវកត់ចំណាំថា ក្នុងរយៈកាលប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះ ការចំណាយសាធារណៈ មានការកើនឡើង ហើយគោលនយោបាយពន្ធដារក៏ត្រូវបានកែលម្អ ។ ទោះជាយ៉ាងណា ទិន្នន័យដែលមានបង្ហាញថា វឌ្ឍនភាពនេះមានភាពយឺតខ្លាំងពេក ដើម្បីឲ្យទាន់ជាមួយនឹងការកើនឡើងយ៉ាងលឿននូវវិសមភាពផ្នែកប្រាក់ចំណូល។

20 Oxfam, ការប្តេជ្ញាចិត្តក្នុងការកាត់បន្ថយសន្ទស្សន៍វិសមភាព ២០១៨, ២០១៨

21 គម្រោងទុនមនុស្សរបស់ធនាគារពិភពលោក ផ្តល់នូវចំណាត់ថ្នាក់ និងពិន្ទុសម្រាប់ទុនមនុស្ស ដោយក្នុងនោះប្រទេសកម្ពុជាមានពិន្ទុ ០,៤៩ ដែលទាបជាងពិន្ទុមធ្យមរបស់ពិភពលោក ដែលមានកម្រិត ០,៥៧ ហើយកាន់តែទាបទៅទៀត បើធៀបនឹងពិន្ទុមធ្យមសម្រាប់តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលមានកម្រិត ០,៦១ (អាចរកបាននៅត្រង់នេះ៖ https://www.worldbank.org/en/publication/human-capital).

22 ដ្បិតតែស្ថិតិស្តីពីចំណុចនេះពិបាកនឹងរកក្តី ប៉ុន្តែ ការស្រាវជ្រាវបានបង្ហាញថា ក្នុងចំណោមប្រជាជន ១០០.០០០ នាក់ ដែលទទួលរងការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេសកម្ពុជា មាន ៣០-៣៥% គឺជាកុមារ ទាំងក្មេងប្រុស និងក្មេងស្រី (Davy, D, ២០១៧: ការពិនិត្យថ្នាក់តំបន់៖ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅអាស៊ីអាគ្នេយ៍, ECPAT International, ទំព័រ ៤៧).

# កត្តាកែប្រែសម្រាប់ជាកូនសោអនាគតកម្ពុជា

ប្រវត្តិកម្ពុជាក្នុងរយៈកាល ៣០ ឆ្នាំកន្លងមកនេះ បង្ហាញថា កម្ពុជាអាចសម្រេចបាននូវ វឌ្ឍនភាពក្នុងល្បឿនលឿន និងជាដុំកំភួនបាន។ ទោះបីជាយ៉ាងនេះក្តី ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យរបស់ខ្លួនសម្រាប់ឆ្នាំ ២០៣០ និង ២០៥០ កម្ពុជានឹងត្រូវធ្វើការដោះស្រាយបញ្ហាវិសមធម៌ និងសម្របខ្លួនឲ្យបានទៅតាមបរិបទដែលមានការផ្លាស់ប្តូរលឿនៗ ហើយនឹងតម្រូវឲ្យដើរលើសពី "ការងារធម្មតា" ទាក់ទងនឹងសិទ្ធិកុមារ និងសុខុមាលភាពកុមារ។

របាយការណ៍នេះបង្ហាញពីផ្នែកអាទិភាពចំនួន ៦ សម្រាប់កា រវិនិយោគទៅលើសិទ្ធិកុមារ ដែលអាចជំនះលើឧបសគ្គធំៗទាំងពីរខាងលើ ពោលគឺវិសមភាព និងបរិបទប្រែប្រួលលឿន។ ដោយត្រូវបានកំណត់ថាជា "កត្តាកែប្រែ" អាទិភាពទាំងនេះតំណាងឲ្យការផ្លាស់ប្តូរនូវរបៀបរបបក្នុងការអនុវត្តនាពេលបច្ចុប្បន្ន ដែលនឹងត្រូវការការដឹកនាំ ធនធាន និងការតាំងចិត្តដើម្បីសម្រេចឲ្យបាន។ ការផ្តល់អាទិភាពលើ កត្តាកែប្រែ ទាំងនេះនឹងនាំឲ្យមានការផ្លាស់ប្តូរសម្រាប់អនាគតរបស់កុមារ និងកម្ពុជាទាំងមូល រាប់បញ្ចូលទាំងមហិច្ឆិតារបស់កម្ពុជាដែលចង់ក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងរយៈពេល ១០ ឆ្នាំខាងមុខនេះ។

ចក្ខុវិស័យរបស់សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! គឺថា កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍បន្តកើតមានទៅថ្ងៃអនាគត ស្របតាម SDGs និងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី ទាំងអស់នេះតម្រូវឲ្យមានការវិនិយោគថ្មីៗទៅលើផ្នែកសំខាន់ៗទាំង ៦ ខាងក្រោមនេះ ដែលនឹងកំណត់ថាតើ កម្ពុជានឹងអាចសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆិតារបស់ខ្លួនដែរឬអត់។

១ កែលម្អលទ្ធភាពទទួលបានសេវាអប់រំកុមារតូច ដែលមានគុណភាព

២ ប្រយុទ្ធប្រឆាំងនឹងកង្វះលទ្ធភាពទទួលបានការអប់រំដែលមានគុណភាព

៣ ដោះស្រាយអត្រាប្រេវ៉ាឡង់ខ្ពស់នៃបញ្ហាកិច្ចការពារកុមារ

៤ កាត់បន្ថយឲ្យបានច្រើនបំផុតនូវអត្រាកុមារខ្វះអាហារូបត្ថម្ភ

៥ កែលម្អលទ្ធភាពទទួលបានសេវាទឹកផឹកមូលដ្ឋាន និងអនាម័យ

៦ បង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់កុមារក្នុងដំណើរការនៃការសម្រេចចិត្ត

អនុសាសន៍ដែលមានរៀបរាប់នៅក្នុងរបាយការណ៍នេះ ត្រូវបានដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! ទទួលស្គាល់ពីភាពចាំបាច់នៃវិធានការរួម និងការសម្របសម្រួលដើម្បីសម្រេចឲ្យបាននូវការអនុវត្តពេញលេញតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ សម្រាប់របាយការណ៍នេះ និងអនុសាសន៍នានា យើងសង្ឃឹមថា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលផ្សេងទៀត អ្នកសិក្សាស្រាវជ្រាវ និងវិស័យឯកជន នឹងមើលឃើញពីក្របខ័ណ្ឌមានប្រយោជន៍សម្រាប់សម្របសម្រួលឲ្យមានកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សុខុមាលភាពរបស់កុមារ និងដោះសោរអនាគតរបស់កម្ពុជា។

# កែលម្អលទ្ធភាពទទួលបានសេវាអប់រំកុមារតូចដែលមានគុណភាព

QUALITY EDUCATION

## កត្តាកែប្រែទី ១

ថ្វីដ្បិតតែសេវាអប់រំកុមារតូចដែលមានគុណភាព មានការទទួលស្គាល់ថាជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់ការសិក្សាទៅថ្ងៃអនាគត និងការអភិវឌ្ឍន៍ក្តី ប៉ុន្តែ កុមារជាច្រើននៅតែមិនមានលទ្ធភាពទទួលបានសេវាអប់រំបែបនេះ ជាពិសេសនៅតាមទីជនបទដាច់ស្រយាល។

### តើមានអ្វីកំពុងកើតឡើង ?

អត្រាចុះឈ្មោះចូលរៀនកម្មវិធីអប់រំកុមារតូច មានកម្រិតទាបខ្លាំងណាស់បើធៀបនឹងការអប់រំថ្នាក់បឋមសិក្សា។ នៅឆ្នាំសិក្សា ២០១៨ – ២០១៩ កុមារអាយុ ៣ ឆ្នាំចំនួនតែ ១៨,៥% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច ហើយកុមារអាយុ ៤ ឆ្នាំ មានចំនួន ៣៩,៤% ហើយកុមារអាយុ ៥ ឆ្នាំមានចំនួន ៦៣,១%។ [23]

កុមាររស់នៅតាមទីជនបទ និងទីដាច់ស្រយ៉ាល កុមារជនជាតិដើមភាគតិច កុមារដែលមានសាវតារសេដ្ឋកិច្ចសង្គមទាប និងកុមារពិការ ជួបឧបសគ្គ ជាងក្រុមកុមារផ្សេងទៀត កាន់តែខ្លាំងក្នុងការទទួលបានឱកាសអប់រំកុមារតូច។ កុមាររស់នៅក្នុងទីក្រុង និងទីប្រជុំជន អាចចូលរួមនៅក្នុងកម្មវិធីអប់រំកុមារតូច ច្រើនជាងកុមាររស់នៅទី ជនបទ (១១%) [24] រហូតដល់ទៅ ៣៦% ហើយកុមារអាយុ ៥ ឆ្នាំនៅដែលស្ថិតនៅក្នុងក្រុមគ្រួសារក្រីក្របំផុត ងាយនឹងបោះបង់ចោលការសិក្សាជាងកុមារដែលមកពីក្រុមគ្រួសារអ្នកមាន រហូតដល់ទៅមួយដងកន្លះ ។ [25]

### ព័ត៌មានសង្ខេប

▶ **មាត្រា UNCRC ដែលពាក់ព័ន្ធបំផុត៖**

១, ២, ៣, ៤, ១៧c, ២៣, ២៨, ២៩, ៣០ និង ៣១

▶ **ចំណុចដៅ SDG៖**

៤.២៖ ត្រឹមឆ្នាំ ២០៣០ ធានាថា គ្រប់ក្មេងស្រី និងក្មេងប្រុសទទួលបានការអភិវឌ្ឍន៍កុមារតូចប្រកបដោយគុណភាព ការថែទាំ និងការអប់រំមុនចូលបឋមសិក្សា ដើម្បីឲ្យពួកគេត្រៀមលក្ខណៈសម្រាប់ការអប់រំថ្នាក់បឋមសិក្សា

▶ **កុមារដែលបាត់ឱកាសបំផុត៖**

កុមាររស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល កុមារដែលមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប កុមារជនជាតិដើម កុមារពិការ។

23 ក្រសួងអប់រំយុវជន និងកីឡា, សន្និបាតអប់រំ, ២០១៩៖ បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា នៅឆ្នាំសិក្សា – ២០១៧ – ២០១៨ និងគោលដៅសម្រាប់ឆ្នាំសិក្សា ២០១៨ – ២០១៩ ទំព័រ ៤៥
24 វិទ្យាស្ថានជាតិស្ថិតិ (NIS), អគ្គនាយកដ្ឋានសុខាភិបាល និង ICF International, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខាភិបាលកម្ពុជា ២០១៤, ទំព័រ ១៦៥.
25 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦: របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអណត្តិ ក្នុងឆ្នាំ ២០១៦ លើផែនការយុទ្ធសាស្ត្រអប់រំ -២០១៤-២០១៨ និងការព្យាករណ៍រហូតដល់ឆ្នាំ ២០២០ទំព័រ ១៨.

បញ្ហាប្រឈមសម្រាប់កុមារជនជាតិដើមភាគតិចរឹតតែខ្លាំងថែមទៀត ដោយសារតែសេវាអប់រំពហុភាសាមានផ្តល់ជូនតែនៅមត្តេយ្យសិក្សារដ្ឋចំនួន ៣ និងមត្តេយ្យសហគន៍ចំនួន ១០៤ ប៉ុណ្ណោះ ក្នុងខេត្តទាំងប្រាំ ហើយកម្មវិធីអប់រំកុមារតូចដែលមានបរិយាប័ន្ន នៅតាមមត្តេយ្យសិក្សានៅមិនទាន់បានពង្រីកវិសាលភាពដល់កម្រិតថ្នាក់ជាតិនៅឡើយ។ [26]

សូម្បីនៅពេលដែលកុមារមានលទ្ធភាពទទួលបានសេវាអប់រំកុមារតូច ( ECE ) ក៏គុណភាព ជារឿយៗ នៅមានកម្រិតទាបនៅឡើយ។ [27] នៅក្នុងឆ្នាំ ២០១៧ សិស្សថ្នាក់មត្តេយ្យចំនួន ២៣,២% ត្រូវបានបង្រៀននៅតាមថ្នាក់រៀនក្នុងវត្តអារាម; ៧១,៥% ធ្វើប្រតិបត្តិការដោយគ្មានទឹក ហើយ ៨១,៣% ខ្វះខាតបង្គន់អនាម័យសម្រាប់កុមារប្រើប្រាស់។ [28] កង្វះទីតាំង និងបរិក្ខាបែបនេះ មានផលប៉ះពាល់អវិជ្ជមានលើវត្តមាន និងការរៀនសូត្ររបស់កុមារ ក៏ដូចជាលក្ខខណ្ឌការងាររបស់គ្រូមត្តេយ្យសិក្សា។ បច្ចុប្បន្ន សេវាអប់រំកុមារតូច ដែលកំពុងដំណើរការ មានតែ ៣២,២% ប៉ុណ្ណោះ ដែលបំពេញតាមបទដ្ឋានគុណភាព។ [29]

## ប្រសិនបើមិនដោះស្រាយ តើមានផលប៉ះពាល់អ្វីខ្លះ ?

កម្មវិធីអប់រំកុមារតូចត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជាថាជាមធ្យោបាយសំខាន់ក្នុងការជំរុញការចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា ហើយជាមធ្យោបាយសម្រាប់ការកសាងមូលដ្ឋានគ្រឹះនៃការអប់រំ ដែលនឹងជួយពង្រឹងដល់លទ្ធផលសិក្សារបស់កុមារ កាត់បន្ថយអត្រាត្រួតថ្នាក់នៅថ្នាក់ដំបូងៗ និងកាត់បន្ថយភាពងាយបោះបង់ចោលការសិក្សា [30] ។

ភស្តុតាងបង្ហាញច្បាស់ថា ការវិនិយោគលើកុមារនៅពេលដែលគេអាយុតិច មិនត្រឹមតែមានឥទ្ធិពលលើការសិក្សារបស់ពួកគេតែមួយ មុខទេ តែមានឥទ្ធិពលផ្សេងៗទៀតលើកុមារ ។ ចំណុចដែលមានឥទ្ធិពលផ្សេងៗទៀតរួមមាន៖ សមភាព និងការផ្តល់អំណាចយេនឌ័រ លទ្ធផលផ្នែកសុខភាព និងអប់រំប្រសើរជាងមុន ជំនាញ សមត្ថភាព និងផលិតភាពប្រសើរជាងមុន កាត់បន្ថយគម្លាតប្រាក់ចំណូល និងវិសមភាពផ្នែកភូមិសាស្ត្រ ផ្តល់កិច្ចអន្តរាគមន៍ទាន់ពេលវេលាសម្រាប់ជនពិការ ហើយជាយុទ្ធសាស្ត្រដែល ចំណាយតិចដើម្បីលុបបំបាត់ការចាញ់ប្រៀបគ្នា " [31]។ ទោះបីជាចំណុចដៅ ៤.២ នៃ SDG ផ្តោតជាពិសេសលើការអប់រំ និងការអភិវឌ្ឍន៍កុមារតូចយ៉ាងណាក្តី ក៏ចំណុចដៅនេះជាសមាសធាតុដ៏សំខាន់សម្រាប់ការសម្រេចឲ្យបានយ៉ាងហោចណាស់ SDGs ចំនួន ៧ ផ្សេងទៀត ស្តីពីភាពក្រីក្រ ការស្រេកឃ្លាន សុខភាព (រាប់បញ្ចូលទាំងមរណភាពកុមារផង) ការអប់រំ យេនឌ័រ ទឹក និងអនាម័យ និងវិសមភាព [32] ។

អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចរយៈពេលវែងរបស់រដ្ឋនានាដែលបានវិនិយោគលើការអប់រំកុមារតូចកំពុងត្រូវបានចងក្រងជាឯកសារយ៉ាងល្អច្រើនទៅៗ ជាពិសេសទាក់ទងនឹងធនធានមនុស្ស។

ក្រៅពីលទ្ធផលសិក្សានៅថ្នាក់បឋមសិក្សា ការរៀនសូត្រ តាំងពីនៅតូចមានឥទ្ធិពលលើការអភិវឌ្ឍន៍របស់ខួរក្បាល សុខភាព ឥរិយាបទ និងឱកាសផ្នែកសេដ្ឋកិច្ច។ [33] ប្រសិនបើកម្មវិធីអប់រំកុមារតូចមិនមានការកែលម្អទេនោះ កម្ពុជាអាចនឹងទទួលបានវឌ្ឍនភាពដែលនៅមានកម្រិតប៉ុណ្ណោះ សម្រាប់ការវាស់វែងរយៈពេលវែងលើការអភិវឌ្ឍន៍ធនធានមនុស្ស ក៏ដូចជា ការវាស់វែងលើវឌ្ឍនភាពផ្សេងទៀតរបស់ជនជាតិភាគតិច និងក្រុមកុមារងាយរងគ្រោះ។



@ Save the Children

26 ក្រសួងអប់រំយុវជន និងកីឡា សន្និបាតអប់រំ, ២០១៩៖ បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា នៅឆ្នាំសិក្សា ២០១៧ – ២០១៨ និងគោលដៅសម្រាប់ឆ្នាំសិក្សា ២០១៨ – ២០១៩ ទំព័រ ២៩.

27 Khieng, S., Madhur, S., & Chhem, R. Eds., 2015: Cambodia Education 2015 Employment and Empowerment, p.198.

28 ក្រសួងអប់រំយុវជន និងកីឡា, ២០១៧: ស្ថិតិ និងសូចនាករអប់រំសាធារណៈ ២០១៦ - ២០១៧, ទំព័រ ៣១.

29 ក្រសួងអប់រំយុវជន និងកីឡា សន្និបាតអប់រំ, ២០១៩៖ បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា នៅឆ្នាំសិក្សា ២០១៧ – ២០១៨ និងគោលដៅសម្រាប់ឆ្នាំសិក្សា ២០១៨ – ២០១៩ ទំព័រ ៣៣

30 ក្រសួងអប់រំយុវជន និងកីឡា, ២០១០: គោលនយោបាយជាតិស្តីពីការថែទាំ និងអភិវឌ្ឍន៍កុមារតូច អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅខែកុម្ភៈ ឆ្នាំ ២០១២, ទំព័រ ២

31 ក្រុមពិគ្រោះយោបល់សម្រាប់ក្រុមការងារកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូចសម្រាប់របៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥, ២០១២ ទំព័រ ១៩, លើកឡើងនៅក្នុង Woodhead, Featherson, Bolton, និង Robertson (២០១៤).

32 ជីវិតវ័យក្មេង, ២០១៦: ឯកសារសង្ខេបគោលនយោបាយ៖ ការអភិវឌ្ឍន៍កុមារតូចនៅក្នុង SDGs។ អាចរកបាននៅ៖ http://www.younglives.org.uk/sites/www.younglives.org.uk/files/YL-PB28_Early%20Childhood%20Development%20in%20the%20SDGs.pdf

33 សម្រាប់ការពិភាក្សាលម្អិតស្តីពីធនធានមនុស្ស និងការអប់រំកុមារតូច សូមមើល Harry Patrinos, ២០១៨: ហេតុផលផ្នែកសេដ្ឋកិច្ចសម្រាប់ការអប់រំកុមារតូច, World Bank Blogs. អាចរកបាននៅត្រង់នេះ៖ https://blogs.worldbank.org/education/economic-case-early-learning. សូមមើលផងដែរ UNICEF, ២០១៣: ភស្តុតាងគាំទ្រការវិនិយោគលើការអភិវឌ្ឍកុមារតូច។មាននៅ https://www.unicef.org/earlychildhood/index_69851.html.

# តើឧបសគ្គរាំងដល់វឌ្ឍនភាពមានអ្វីខ្លះ ?

កម្មវិធីអប់រំកុមារតូចគឺជាយុទ្ធសាស្ត្រដែលចំណាយតិច តែមានប្រសិទ្ធភាព ដើម្បីសម្រេចឲ្យបាននូវវត្ថុបំណងធំៗផ្នែកអប់រំ សុខភាព អាហារូបត្ថម្ភ និងកិច្ចគាំពារសង្គម ហើយរដ្ឋាភិបាលបានបង្ហាញឲ្យឃើញពីការប្តេជ្ញាចិត្តជាថ្មីក្នុងការកែលម្អសេវាកម្ម (ដូចជាគោលនយោបាយជាតិស្តីពីកិច្ចគាំពារនិងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១០ និងផែនការសកម្មភាព ឆ្នាំ ២០១៤ – ២០១៨ ក៏ដូចជា ផែនការសកម្មភាព ២០១៩ – ២០២៣ ថ្មី និងសៀវភៅណែនាំស្តីពី ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សម្រាប់គណៈ កម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ )។ ទោះបីជាផែនការរបស់រដ្ឋាភិបាលមានភាពវិជ្ជមានជាច្រើនក្តី [34] ផែនការទាំងនោះនៅតែទទួលបានមូលនិធិតិចតួច បើធៀបនឹងប្រព័ន្ធអប់រំទាំងមូល។ នៅក្នុងឆ្នាំ ២០១៧ថវិកាចរន្តរបស់ក្រសួងអប់រំយុវជន និងកីឡា តែ ០,៣% ប៉ុណ្ណោះ ដែលត្រូវបានធ្វើ វិភាជន៍សម្រាប់កម្មវិធីអប់រំកុមារតូច ដែលជាចំណែកមួយតូចបំផុតនៃថវិកាចរន្តរបស់ក្រសួងសម្រាប់កម្មវិធីអន្តរាគមន៍ ធៀបនឹងអនុវិស័យផ្សេងទៀត ដូចជាការអប់រំថ្នាក់បឋមសិក្សា (៣,៦%) ការអប់រំថ្នាក់មធ្យមសិក្សា (៤,០%) និងការអប់រំថ្នាក់ឧត្តមសិក្សា (១,៧%) ។ [35]

ការមិនសូវផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុលើវិស័យអប់រំកុមារតូចនេះ គឺរឹតតែធ្ងន់ធ្ងរថែមទៀតនៅថ្នាក់មូលដ្ឋាន ដោយសារការយល់ដឹងពីអត្ថប្រយោជន៍របស់កម្មវិធីអប់រំកុមារតូច របស់អាជ្ញាធរមូលដ្ឋាននៅមានកម្រិតនៅឡើយ ហើយដូច្នេះមិនបានផ្តល់អាទិភាពលើវិស័យនេះនៅពេលធ្វើផែនការអភិវឌ្ឍនៅថ្នាក់មូលដ្ឋានឡើយ។ ថ្វីដ្បិតតែមានការកើនឡើងនូវចំនួនកុមារចុះឈ្មោះចូលរៀននៅតាមសាលាមត្តេយ្យសាធារណៈក្តី ប៉ុន្តែផែនការវិនិយោគឃុំ ហាក់វិភាជន៍តែ ២ ទៅ ៤% នៃថវិកានៅមូលដ្ឋានសម្រាប់សេវាសង្គមផ្សេងៗ ដូចជាសាលាមត្តេយ្យជាដើម។

នៅចុងឆ្នាំ ២០១៧ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យមួយ (លេខ ២៤៥) ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សម្រាប់ផ្តល់ការគាំទ្រដល់សាលាមត្តេយ្យនៅសហគមន៍ ដែលបំពេញតាមបទដ្ឋានអប្បបរមាបាន។ ទោះជាយ៉ាងណា ការធ្វើដូច្នេះមិនបានដោះស្រាយលើបញ្ហាគុណភាព ឬបញ្ហាប្រឈមទាក់ទងនឹងចំនួនកុមារធៀបនឹងគ្រូដែលមានអនុបាតខ្ពស់ (៣៨,៩ ក្នុងគ្រូមួយនាក់ ក្នុងឆ្នាំ ២០១៦ – ២០១៧) [36] ។ បើទោះបីជាមានផែនការក្នុងការបណ្តុះបណ្តាលគ្រូមត្តេយសិក្សាថ្មីៗឲ្យបានចំនួន ៤៥០ នាក់ក្នុងមួយឆ្នាំក្តី ប៉ុន្តែជាក់ស្តែងមានគ្រូតែ ២៥០ នាក់ប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាលក្នុងឆ្នាំ ២០១៥ និង ២០០ នាក់នៅក្នុងឆ្នាំ ២០១៦ [37] ។ ការប្រើប្រាស់គ្រូជាប់កិច្ចសន្យាបានជួយបន្ធូរសម្ពាធបានខ្លះ។ ទោះជាយ៉ាងណា ការបណ្តុះបណ្តាលដែលគ្រូជាប់កិច្ចសន្យាទទួលបានមិនគ្រប់គ្រាន់ដើម្បីធានាឲ្យបាននូវការរៀនសូត្រដែលមានគុណភាពសម្រាប់កុមារគ្រប់គ្នានោះទេ ជាពិសេស កុមារដែលបាត់ឱកាស និងងាយរងគ្រោះខ្លាំងជាងគេបំផុត។ [38] ជាការពិតណាស់ បើសិនជាយើងមើលទៅលើភាពខុសគ្នារវាងលក្ខខណ្ឌនៃការជ្រើសរើស និងបណ្តុះបណ្តាលគ្រូ សម្រាប់ប្រភេទគ្រូខុសៗគ្នា គុណភាពខុសគ្នានៃការបង្រៀនគឺជារឿងមិនអាចចៀសផុតបានឡើយ - ឧទាហរណ៍ សាលាមត្តេយ្យឯកជនក្នុងទីក្រុង ធៀបនឹងសាលាមត្តេយ្យនៅទីជនបទដាច់ស្រយ៉ាល [39] ។

ចុងក្រោយ កុមារត្រូវការឲ្យមានការបង្កើនលទ្ធភាពទទួលបានសម្ភារៈអំណាន និងសម្ភារៈសម្រាប់លេងដែលសមស្របទៅតាមអាយុ។ យោងតាម អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជាឆ្នាំ២០១៤ មានកុមារអាយុក្រោម ៥ ឆ្នាំ តែ ៤% ប៉ុណ្ណោះ ដែលមានសៀវភៅកុមារយ៉ាងហោចចំនួនបីក្បាល (ចំនួននេះ មានរហូតដល់ទៅ ១១% បើយើងពិនិត្យមើលតែនៅតំបន់ទីក្រុងនិងប្រជុំជន) [40] ។ ការសិក្សាស្រាវជ្រាវ មួយទៀតក្នុងឆ្នាំ ២០១៧ នៅក្នុងតំបន់បឹងទន្លេសាប បង្ហាញថា មានក្រុមគ្រួសារ តែ ៩% ប៉ុណ្ណោះ ដែលមានសៀវភៅដែលបោះពុម្ពសម្រាប់កុមារអាយុចន្លោះពី ០-៦ ឆ្នាំ [41] ។

34 ផែនការសកម្មភាពជាតិមានបំណងបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងដល់ការការពារកុមារអាយុ ០-៦ ឆ្នាំ (ជាពិសេសកុមារមកពីក្រុមគ្រួសារក្រីក្រ ជនជាតិដើមភាគតិច និងកុមារពិការ) ហើយផ្តល់អាទិភាពលើសាលាមត្តេយ្យសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ។ ទោះបីជាយ៉ាងនេះក្តី ផែនការនេះមិនមានរៀបរាប់ឲ្យបានគ្រប់គ្រាន់អំពីការអភិវឌ្ឍន៍មនោសញ្ចេតនាសង្គម ឬការអភិវឌ្ឍន៍ប្រាជ្ញាក្តី (ឧទាហរណ៍ "ការយកកុមារភ្ញោចកុមារតាំងពីនៅតូច" "ឱកាសរៀនសូត្រនៅវ័យកុមារ") សម្រាប់កុមារអាយុក្រោម ៣ ឆ្នាំ។ឆ្នាំឡើយ។

35 UNICEF, ២០១៧: បច្ចុប្បន្នភាពការវិភាគស្ថានភាពរបស់កុមារ និងស្ត្រីនៅកម្ពុជា, ទំព័រ ៦២

36 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧: ស្ថិតិ និងសូចនាករណ៍អប់រំសាធារណៈ: ២០១៦ - ២០១៧, ទំព័រ ៣៥

37 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦: របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិ ក្នុងឆ្នាំ ២០១៦ ទៅលើផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ និងការព្យាករណ៍សម្រាប់ឆ្នាំ ២០២០, ទំព័រ ២២.

38 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦: របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិ ក្នុងឆ្នាំ ២០១៦ ទៅលើផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ និងការព្យាករណ៍សម្រាប់ឆ្នាំ ២០២០, ទំព័រ ៦.

39 គ្រូមត្តេយ្យសាលារដ្ឋត្រូវបានរំពឹងថាបានបញ្ចប់ការសិក្សាថ្នាក់ទី ១២ ហើយឆ្លងកាត់វគ្គបណ្តុះបណ្តាលពីរឆ្នាំនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមត្តេយ្យនៅរាជធានីភ្នំពេញ។ ទោះជាយ៉ាងណា នៅតាមទីជនបទដាច់ស្រស្រយាលដែលមានសហគមន៍ដែលបាត់ឱកាសខ្លាំងជាងគេបំផុតនោះ ដូចជាខេត្តមណ្ឌលគីរី និងរតនគីរីជាដើម គ្រូមត្តេយ្យត្រូវបានតម្រូវឲ្យមានសញ្ញាប័ត្រត្រឹមតែថ្នាក់ទី ៩ ប៉ុណ្ណោះ។ ថ្វីដ្បិតតែលក្ខលក្ខខណ្ឌជ្រើសរើសកាន់តែទាបសម្រាប់ការជ្រើសរើសគ្រូមត្តេយ្យសិក្សានឹងជួយបង្កើនដល់ការជ្រើសរើសគ្រូនៅតាមទីជនបទដាច់ស្រស្រយាលក្តី វាក៏មានផលប៉ះពាល់លើគុណភាពអប់រំនៅទីជនបទដាច់ស្រស្រយាលផងដែរ។ គ្រូមត្តេយ្យសហគមន៍ត្រូវបានរំពឹងថាបញ្ចប់ការអប់រំត្រឹមថ្នាក់ទី ៦ ហើយឆ្លងកាត់ការបណ្តុះបណ្តាលមុនបម្រើការងាររយៈពេល ៣៥ ថ្ងៃ ប៉ុន្តែសម្រាប់លក្ខខណ្ឌជ្រើសរើសគ្រូបង្រៀនក្នុងកម្មវិធីអប់រំតាមផ្ទះ និងសាលាមត្តេយ្យឯកជន ជាទូទៅមិនមានការគ្រប់គ្រងនោះទេ។

40 NIS, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខាភិបាលកម្ពុជា ២០១៤, ទំព័រ ១៦៨.

41 អង្គការ Save the Children , ២០១៧: កិច្ចគាំពារនិងអភិវឌ្ឍន៍កុមារតូចៈ ការអង្កេតមូលដ្ឋានលើភូមិបណ្តែតទឹកនៅទន្លេសាប, ទំព័រ ២៤.

ការអង្កេតផ្នែកទីផ្សារនៅឆ្នាំ ២០១៧ ទៅលើសៀវភៅរបស់គ្រឹស្ថានបោះពុម្ពផ្សាយចំនួន ២៦ បានបង្ហាញថា គ្មានសៀវភៅណាមួយដែលសមស្របសម្រាប់កុមារអាយុក្រោម ៣ ឆ្នាំឡើយ ហើយមានតិចតួចណាស់ដែលសមស្របសម្រាប់កុមារអាយុពី ៤ – ៦ ឆ្នាំ [42]។ ជាងនេះទៅទៀត មានគ្រឹស្ថានបោះពុម្ពផ្សាយតិចតួចណាស់ដែលបញ្ជាក់អំពីអាយុសម្រាប់អានសៀវភៅរបស់ខ្លួន ហើយប្រើប្រាស់អត្ថបទដែលស្មុគស្មាញសម្រាប់អ្នកអានវ័យក្មេង [43]។

## តើអ្វីខ្លះដែលចាំបាច់ត្រូវធ្វើ ?

ដើម្បីកែប្រែស្ថានភាពលទ្ធភាពទទួលបានការអប់រំកុមារតូចដែលមានគុណភាព" សម្ព័ន្ធ សិទ្ធកុមារបច្ចុប្បន្ន! សូមផ្តល់អនុសាសន៍ខាងក្រោមនេះដល់រាជរដ្ឋាភិបាលកម្ពុជា៖

១ បង្កើនការវិនិយោគផ្នែកហិរញ្ញវត្ថុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពង្រីកវិសាលភាពរបស់កម្មវិធីអប់រំកុមារតូច ទូទាំងប្រទេស ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើតំបន់ជនបទ និងដាច់ស្រយាល។

២ ពង្រឹង គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ បន្ថែមទៀត ដើម្បីកសាង និងគ្រប់គ្រងសាលាមត្តេយ្យសហគមន៍ តាមរយៈការបណ្តុះបណ្តាល ដើម្បីអនុវត្តតាមសៀវភៅណែនាំថ្មីស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

៣ បំពាក់សម្ភារបរិក្ខាប្រសើរជាងមុនដល់សាលាមត្តេយ្យ ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កុមារ ដែលមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប មកពីសហគមន៍ជនជាតិដើមភាគតិច និងកុមារពិការ។

៤ បង្កើនការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមត្តេយ្យ តាមរយៈការបណ្តុះបណ្តាលមុនចូលបម្រើការ ដែលធ្វើឡើងនៅឯមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមត្តេយ្យនៅថ្នាក់ខេត្ត ព្រមជាមួយនឹងកម្មវិធីសិក្សាដែលមានបទដ្ឋាន និងតាមរយៈការអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈអំឡុងពេលបម្រើការងារដែលធ្វើឡើងជាបន្តបន្ទាប់។

៥ គាំទ្រដល់ការអភិវឌ្ឍន៍ ការបោះពុម្ពផ្សាយនិងលទ្ធភាពប្រើប្រាស់ ឯកសារអំណាន និងសម្ភារៈលេងដែលសមស្របទៅតាមអាយុ សម្រាប់កុមារដែលមានអាយុពី ០ ដល់ ៦ ឆ្នាំ ជាពិសេសនៅតាមទីជនបទ និងតំបន់ដាច់ស្រយាល ហើយបង្កើតបទដ្ឋានជាតិស្តីពីការកំណត់កម្រិតសៀវភៅ ដើម្បីឲ្យគ្រឹះស្ថានបោះពុម្ពផ្សាយអនុវត្ត ។ [44]

៦ ធានាថា គោលនយោបាយ សេវា និងផែនការសកម្មភាពរបស់រដ្ឋាភិបាល បញ្ជាក់ឲ្យបានច្បាស់រវាងសេវាដែលផ្តោតលើកុមារអាយុពី 3 ទៅ 6 ឆ្នាំ និងសេវា ដែលផ្តោតលើកុមារចាប់តាំងពីការចាប់កំណើត រហូតដល់អាយុ 3 ឆ្នាំ ដែលតម្រូវឲ្យមានវិធីសាស្ត្រពហុវិស័យជាក់លាក់ជាងមុន ដើម្បីធានាឲ្យបាននូវសុខុមាលភាព។

៧ កែសម្រួលឡើងវិញលើកម្មវិធីសិក្សាការគាំពារនិងអភិវឌ្ឍកុមារតូច ដើម្បីឲ្យមាន ការកែប្រែផ្នែកយ៉េនឌ័រ និងលើកកម្ពស់ការចូលរួមរបស់បុរស នៅក្នុងការអប់រំអំពីការចិញ្ចឹមកូន និងនៅមត្តេយ្យសាលា។

៨ បង្កើន តម្រូវការរបស់ប្រជាពលរដ្ឋលើកម្មវិធីអប់រំកុមារតូច តាមរយៈការគាំទ្រយុទ្ធនាការសាធារណៈ ក្រុមសហគមន៍ និងគំនិតផ្តួចផ្តើមនានា ដែលជួយបង្កើនការយល់ដឹងពីសារៈសំខាន់នៃការអប់រំកុមារតូច។


@ World Vision

[42] World Vision, ២០១៧: ការអង្កេតផ្នែកទីផ្សារលើសម្ភារអំណានសម្រាប់អ្នកអានជាកុមារ, ទំព័រ ២.

[43] គ្រឹះស្ថានបោះពុម្ពផ្សាយភាគច្រើនកំណត់ថា សៀវភៅរបស់កុមារជាសៀវភៅ ដែលមានរូបភាពច្រើន និងអត្ថបទតិចតួច ប៉ុន្តែ ការត្រួតពិនិត្យបានរកឃើញថា បើទោះបីជាមាន “អត្ថបទតិចតួច” ក្តី ក៏វានៅតែមានភាពស្មុគស្មាញខ្លាំងសម្រាប់អ្នកអានជាកុមារ ដែលជម្មតា ប្រើប្រាស់ភាសាផ្លូវការ និងល្បះផ្សំ។

[44] គោលការណ៍ណែនាំអំពីការកំណត់កម្រិតសៀវភៅអាចធានាថា សៀវភៅដែលបោះពុម្ពសម្រាប់អ្នកអានវ័យដំបូង (អាយុពី ០ – ៣ ឆ្នាំ) និងអ្នកអានជាកុមារតូច (អាយុ ៤ ឆ្នាំដល់ថ្នាក់ទី ៣) មានភាពសមស្របបើនិយាយពីទំហំការរចនា រចនាសម្ព័ន្ធពណ៌នា គំនូសបង្ហាញ ពាក្យពេចន៍ ឃ្លោងឃ្លា ប្រយោគ ខ្លឹមសារ និងប្រធានបទ។

# កែលម្អលទ្ធភាពទទួលបានការអប់រំមូលដ្ឋានដែលមានគុណភាព

4 QUALITY EDUCATION

## កត្តាកែប្រែទី ២

ប្រទេសកម្ពុជាបានសម្រេចបាននូវវឌ្ឍនភាពដ៏គួរឲ្យភ្ញាក់ផ្អើលសម្រាប់ការអប់រំមូលដ្ឋាន ដែលក្នុងនោះ លទ្ធភាពទទួលបានការអប់រំ នៅថ្នាក់បឋមសិក្សាគឺសឹងតែទាំងស្រុង (ការចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា ២០១៨ – ២០១៩ គឺ ៩៨%) ។ ទោះជាយ៉ាងណា វឌ្ឍនភាពបន្ថែមទៅមុខទៀតរងការគំរាមកំហែងដោយសារតែការរៀនសូត្រដែលមានគុណភាពទាប និងអសង្គតភាពនៃលទ្ធភាពទទួលបានការអប់រំសម្រាប់ក្រុមមនុស្ស មួយចំនួន។

## តើមានអ្វីកំពុងកើតឡើង ?

កុមារនៅកម្ពុជាមានសិទ្ធិទទួលបានការអប់រំដោយឥតគិតថ្លៃរហូតដល់ទៅ ៩ ឆ្នាំ។ ទោះជាយ៉ាងណា ក្រុមកុមារមួយ ចំនួនមានបញ្ហាប្រឈមក្នុងការទទួលបានការអប់រំដែលមានគុណភាពនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃការអប់រំរបស់ពួកគេ។ ឧទាហរណ៍ កុមារពិការ ជាពិសេសក្មេងស្រីពិការនិងកុមារដែលពិការផ្នែកប្រាជ្ញា ងាយនឹងឈប់រៀនជាងកុមារដទៃទៀតរហូតដល់ទៅពីរដង ហើយក្មេងជំទង់ដែលពិការ មានតែ ៤% ប៉ុណ្ណោះ ដែលបានបញ្ចប់ការសិក្សានៅថ្នាក់អនុវិទ្យាល័យ បើធៀបនឹងក្មេងជំទង់ដែលមិនពិការ ដែលអត្រាបញ្ចប់អនុវិទ្យាល័យមានរហូតដល់ទៅ ៤១% ។ [45]

ជំនឿវប្បធម៌ដ៏ទូលំទូលាយ (ដូចជាពិការភាពកើតឡើងដោយសារតែកម្មពៀរ [46]) និងការយល់ដឹងទាបស្តីពីពិការភាពផ្សេងពីរាងកាយ [47] បានរួមចំណែកដល់ការរើសអើងចំពោះកុមារដែលពិការ។

ពួកគេក៏ប្រឈមនឹងឧបសគ្គជាក់ស្តែងចំពោះការទទួលបានការអប់រំ ដូចជាកង្វះមធ្យោបាយធ្វើដំណើរ លទ្ធភាពមានកម្រិតក្នុងការទទួលបានឧបករណ៍ជំនួយការរៀនសូត្រ ឬមិនមានគ្រូដែលអាចឆ្លើយតបទៅនឹងតម្រូវការរៀនសូត្ររបស់ពួកគេ។ [48]

### ព័ត៌មានសង្ខេប

**មាត្រា UNCRC ដែលពាក់ព័ន្ធបំផុត៖**

២, ៣, ៦, ១២, ១៧, ២៨, ២៩, ៣០, ៣១

**ចំណុចដៅ SDG៖**

៤.១ នៅឆ្នាំ ២០៣០, ធានាថា កុមារា និងកុមារីទាំងអស់មានសេរីភាពពេញលេញហើយការអប់រំនៅបឋមសិក្សា និងអនុវិទ្យាល័យដែលមានគុភាពនឹងនាំឲ្យលទ្ធផលសិក្សាមានប្រសិទ្ធភាព។

**កុមារដែលបាត់ឱកាសភាគច្រើនបំផុត៖**

កុមារដែលរស់នៅតំបន់ដាច់ស្រយ៉ាល ឬតំបន់ដែលងាយរងគ្រោះមហន្តរាយ ដែលនៅទីនោះសាលារៀនមានស្ថានភាពលំបាក; កុមារដែលមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប កុមារជនជាតិដើមភាគតិច កុមារពិការ កុមារដែលឈានដល់សាលាអនុវិទ្យាល័យកុមារបោះបង់ចោលការសិក្សា។

45 UNESCO, 2018: ការអប់រំ និងពិការភាព៖ ការវិភាគលើទិន្នន័យពី ៤៩ ប្រទេស។ ទំព័រ ២០ និងទំព័រ ២៣។
46 UNESCO, 2018: ការអប់រំ និងពិការភាព៖ ការវិភាគលើទិន្នន័យពី ៤៩ ប្រទេស។ ទំព័រ ២០ និងទំព័រ ២៣។
47 Halim, Hanamariya, 2017: ជំងឺសរសៃប្រសាទនៅកម្ពុជា៖ ការលើកកម្ពស់ការយល់ដឹង" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៧
48 Plan International, 2014: លទ្ធភាពបានរៀនសូត្រ និងចូលសាលារៀនរបស់កុមារដែលងាយរងគ្រោះ និងដែលបាត់ឱកាស៖ ការស្វែងយល់ពីបញ្ហាប្រឈម

បើទោះបីជាកុមារីហាក់មានអត្រាសិក្សា ការឡើងថ្នាក់ និងការបញ្ចប់ការសិក្សា ប្រសើរជាងកុមារា ពួកគេនៅតែបន្តជួបប្រទះនឹងបញ្ហាប្រឈមក្នុងការទទួលបានការអប់រំឲ្យបានពេញលេញ។ ជាញឹកញយ កុមារីបោះបង់ចោលការសិក្សាដើម្បីជួយដល់ក្រុមគ្រួសារ ហើយកុមារី ដែលទទួលបានការអប់រំតិចតួចជាទូទៅ ងាយនឹងប្រឈមការកេងប្រវ័ញ្ច និងការរំលោភបំពានដូចជាការជួញដូរមនុស្សជាដើម។ [49]

កុមារមកពីក្រុមជនជាតិដើមភាគតិច ក៏ជួបការលំបាកក្នុងការទទួលបានការអប់រំផងដែរ ដោយសារតែជាធម្មតាពួកគេរស់នៅតាមតំបន់ដែលដាច់ឆ្ងាយពីគេឯង អាចនឹងមិនចេះនិយាយភាសាខ្មែរ ប្រឈមមុខនឹងការរើសអើងពីក្មេងដទៃ ហើយទំនងជាងាយនឹងផ្លាស់ទីលំនៅ ហើយត្រូវបានបង្អាក់មិនឲ្យមកសាលារៀនដោយសារត ចម្ងាយឆ្ងាយពីផ្ទះនិងសាលារៀន។ នៅក្នុងតំបន់ខ្លះនៃប្រទេសកម្ពុជាមានតែសាលារៀនមួយចំនួនប៉ុណ្ណោះ ដែលផ្តល់ការអប់រំ ពហុភាសា ដល់កុមារដែលមកពីក្រុមជនជាតិដើមភាគតិច។ [50]

គួរឲ្យសោកស្តាយ បើទោះបីជាកុមារមិនងាយរងការរើសអើងដូច្នេះ ឬពិតជាបានចូលរៀនក្តី ក៏គុណភាពនៃការបង្រៀន និងការរៀននៅតែទាបជាងកម្រិតបទដ្ឋាន ដែលក្នុងនោះគុណភាពនៃការអប់រំ នៅថ្នាក់បឋមសិក្សារបស់ប្រទេសកម្ពុជាត្រូវបានវេទិកាសេដ្ឋកិច្ចពិភពលោក ដាក់ចំណាត់ថ្នាក់ត្រឹមលេខរៀងទី ១១០ ក្នុងចំណោមប្រទេសចំនួន ១៤០។ [51] ជាលទ្ធផល កុមារបានបង្ហាញឲ្យឃើញថា ការរៀនសូត្ររបស់គេមានលទ្ធផលទាបខ្លាំងមែនទែន។ ពិន្ទុផ្នែកអក្ខរកម្មទាបប្រហែលជាកើតឡើងមួយផ្នែកដោយសារតែកង្វះ លទ្ធភាពទទួលបានសម្ភារអំណាន ជាពិសេសនៅតាមទីជនបទ។ ការសិក្សាស្រាវជ្រាវមួយនៅឆ្នាំ ២០១៦ រកឃើញថា សាលារៀនមានតែ ២៥% ប៉ុណ្ណោះ មានសៀវភៅ និងធនធានអំណានគ្រប់គ្រាន់ ស្របតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានកំណត់នៅ ក្នុងឆ្នាំ ២០១១។ [52]

បញ្ហាដទៃទៀត ដូចជា សមាមាត្ររវាងចំនួនសិស្ស និងគ្រូមានកម្រិតខ្ពស់ ការអប់រំរបស់គ្រូបង្រៀនខ្លួនឯងនៅមានកម្រិតទាប [53] និងការបាត់បង់ម៉ោងនៃការបង្រៀនរបស់គ្រូផងនោះ [54] រួមចំណែកឲ្យមានអសង្គតភាពនៃគុណភាពអប់រំដែលផ្តល់ដល់កុមារទូទាំងប្រទេសកម្ពុជា។

## ប្រសិនបើមិនដោះស្រាយ តើមានផលប៉ះពាល់ដូចម្តេច?

ការអប់រំដែលមានគុណភាពទាប និងអសង្គតភាពនៃលទ្ធភាពទទួលបានការអប់រំសម្រាប់ក្រុមមនុស្សមួយចំនួន នៅតែជាកត្តារាំងស្ទះខ្លាំងចំពោះការទទួលបានពេញលេញនូវសិទ្ធិកុមារ ការអភិវឌ្ឍន៍ធនធានមនុស្ស និងការសម្រេចបាននូវគោលដៅផ្នែកសេដ្ឋកិច្ច និងផ្នែកអភិវឌ្ឍន៍របស់ប្រទេស។ ការពង្រឹងការអប់រំគឺជាស្នូលសំខាន់ចំពោះការអភិវឌ្ឍកម្លាំងពលកម្មជំនាញដែលអាចសម្របខ្លួនទៅតាមការប្រែប្រួលនៃឧស្សាហកម្ម (ដូចជាបច្ចេកវិទ្យាថ្មីៗជាដើម) ពង្រឹងដល់បរិយាប័ន្នផ្នែកហិរញ្ញវត្ថុក្នុងចំណោមប្រជាពលរដ្ឋ បង្កើនភាពច្នៃប្រឌិត និងការងារផ្សេងៗគ្នានៅក្នុងវិស័យឧស្សាហកម្ម និងបង្កើតឲ្យមានបុគ្គលិកដែលមានសមត្ថភាព ក្នុងការធ្វើឲ្យអាជីវកម្ម មានការប្រកួតប្រជែង [55]។ បន្ថែមលើនេះ ការវិភាគលើ SDGs បានបង្ហាញថា ការអប់រំដែលមានគុណភាពមានទំនាក់ទំនងជាមួយនឹងចំណុចដៅ SDG ចំនួន ១៥ ផ្សេងទៀត [56] ដែលនេះបង្ហាញថា ប្រសិនបើគ្មានវឌ្ឍនភាពលើផ្នែកនេះទេ នោះការសម្រេចបាននូវទិសដៅផ្សេងទៀតទាំងអស់នឹងត្រូវបានបង្អាក់ផងដែរ។

---

49 SOS Children's Villages Cambodia, ២០១៥: វិភាគស្ថានភាពសិទ្ធកុមារ៖ កុមារប្រឈមនឹងការបាត់បង់ការថែទាំពីឪពុកម្តាយ និងកុមារដែលបាត់បង់ការថែទាំពីឪពុកម្តាយ, និង Sonyka, Va, ១៩ មីនា ២០១៥: "សិស្សនារីនៅថ្នាក់វិទ្យាល័យកាន់តែច្រើនឡើងបោះបង់ចោលការសិក្សា" កាសែត Khmer Times

50 UNICEF, ២០១៥: ផែនការសកម្មភាពជាតិសម្រាប់ការអប់រំពហុភាសា ឯកសារព័ត៌មាន និងសហការណ៍ សម្រាប់ជំនួយ និងការសង្គ្រោះគ្រប់ទីកន្លែង៖ ការបញ្ជ្រាបការអប់រំសម្រាប់ជនជាតិដើមភាគតិច និងកុមារពិការ និង Mayhew, Joanna, "ការអប់រំជនជាតិដើមភាគតិចរបស់កម្ពុជា"

51 វេទិកាសេដ្ឋកិច្ចពិភពលោក, ២០១៨. របាយការណ៍ស្តីពីភាពប្រកួតប្រជែងសកល, អាចរកបាននៅទីនេះ https://www.weforum.org/reports/the-global-competitveness-report-២០១៨.

52 World Vision, ២០១៦: ស្ថានភាពបច្ចុប្បន្ន & ការប្រើប្រាស់បណ្ណាល័យបឋមសិក្សា: ព័ត៌មានសង្ខេបទូទាំង ៥ ខេត្តក្នុងប្រទេសកម្ពុជា

ការវាយតម្លៃលើគុណភាពបង្រៀនថ្នាក់កុមារតូចនៅកម្ពុជា បង្ហាញថា "បើទោះបីជាគ្រូជាច្រើនអាចឆ្លងកាត់ជាប់ការធ្វើតេស្តកម្រិតសិស្ស ហើយមានការយល់ដឹងមូលដ្ឋានលើមុខវិជ្ជាគណិតវិទ្យាសម្រាប់កម្មវិធីសិក្សាថ្នាក់ទី ១ – ៣ ក្តី ប៉ុន្តែ ជាគួរឱ្យចាប់អារម្មណ៍ដែលគ្រូបង្រៀនមួយចំនួន មិនអាចបង្ហាញឱ្យឃើញពីការយល់ដឹងឡើយសម្បីកម្រិតមូលដ្ឋាននៃខ្លឹមសារមុខវិជ្ជាដែលពួកគេបង្រៀន" (NEP, ២០១៧: ការវាយតម្លៃលើគុណភាពបង្រៀនថ្នាក់កុមារតូចនៅកម្ពុជា, ទំព័រ៣២)

54 ជាមធ្យម នៅក្នុងឆ្នាំ ២០១៣, ២៧% នៃម៉ោងបង្រៀន (៥០.៥ ថ្ងៃ) ត្រូវបានខាតបង់ដោយសារតែថ្ងៃសម្រាកពីការសិក្សាផ្លូវការបន្ថែមទៀត អវត្តមានរបស់គ្រូ និងការបង្រៀនខ្លីៗ (NEP, ២០១៥: ម៉ោងបង្រៀននៅសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា)។

55 YoBerger, H and MacDonald, M, ២០១៨: IMFblogs: ការដាក់ពិន្ទុ G-២០ សម្រាប់គោលដៅកំណើនរបស់ខ្លួន។ អាចរកបាននៅ៖ https://blogs.imf.org/2018/11/19/chart-of-the-week-grading-the-g-20-on-its-growth-goals/

56 Vladimirovaa, K & Le Blanc, D, ២០១៥:តើចំណងទំនាក់ទំនងរវាងការអប់រំ និងគោលដៅអភិវឌ្ឍន៍ចីរភាពត្រូវបានលើកយកមកបញ្ចូលបានលម្អិតប៉ុណ្ណានៅក្នុងរបាយការណ៍របស់អង្គការសហប្រជាជាតិ? វិភាគទានសម្រាប់ការសិក្សាស្រាវជ្រាវទៅលើអន្តរកម្មរបស់វិទ្យាសាស្ត្រ និងគោលនយោបាយ ដែលមាននៅលើការអប់រំនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ។ អាចរកបាននៅ៖
https://sustainabledevelopment.un.org/content/documents/2111education%20and%20sdgs.pdf.

# តើឧបសគ្គរាំងដល់វឌ្ឍនភាពមានអ្វីខ្លះ?

ទិន្នន័យដែលបានមកពីក្រុមខណ្ឌគណនេយ្យភាពសង្គមរបស់កម្ពុជា បានបង្ហាញថា ការផ្តល់សៀវភៅសិក្សា គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗ ដែលប្រជាពលរដ្ឋមើលឃើញថា ជាការបង្អាក់ដល់ការរៀនសូត្ររបស់កុមារ ដែលក្នុងនោះមានភស្តុតាងបង្ហាញថា ជាញឹកញាប់បទដ្ឋានរបស់រដ្ឋាភិបាលបំពេញមិនបានគ្រប់គ្រាន់នៅកម្រិតសាលារៀននៅឡើយ [57]។ ការអង្កេតមួយទៀត ដែលបានធ្វើឡើងកាលពីឆ្នាំ ២០១៨ បង្ហាញថា ការចំណាយបន្ថែមលើសម្ភារបង្រៀន និងរៀន ទាំងនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ គឺជាឧបសគ្គផ្នែកហិរញ្ញវត្ថុដ៏ធំចំពោះវត្តមានឲ្យបានទៀងទាត់សម្រាប់កុមារា និងកុមារី ដែលមកពីក្រុមគ្រួសារក្រីក្រ [58]។ បើទោះបីជាស្ថានភាពបែបនេះកំពុងមានភាពប្រសើរឡើងក្តី ក៏ប្រាក់បៀវត្សទាបរបស់គ្រូបង្រៀន បន្តជម្រុញ លើកទឹកចិត្ត គ្រូបង្រៀនឲ្យមានការប្រមូលប្រាក់ឈ្នួលក្រៅផ្លូវការ និងការបង្រៀន ឯកជន ដែលបង្កើតជាឧបសគ្គ រាំងដល់ការទទួលបានការអប់រំ។ ឪពុកម្តាយតែងតែមិនដឹងច្បាស់ឡើយថាតើ ការបង់ប្រាក់មួយណាដែលកំណត់ដោយរដ្ឋាភិបាល ហើយមួយណាជាការកំណត់បន្ថែមដោយគ្រូបង្រៀន ឬនាយកសាលា។ [59]

បន្ថែមលើនេះ សាលារៀនមិនមែនជាទីមានសុវត្ថិភាពសម្រាប់កុមារគ្រប់ពេលឡើយ ដែលក្នុងនោះ ជារឿងគួរឲ្យភ្ញាក់ផ្អើលដែលសិស្សចំនួន ៧៣% រាយការណ៍ថា បានទទួលរងហិង្សា នៅសាលារៀនយ៉ាងតិចក៏មួយលើក ហើយសិស្សប្រហែលពាក់កណ្តាល បានដាក់ពិន្ទុសាលារៀនរបស់ខ្លួន (ថ្នាក់រៀន និងទីធ្លាសម្រាប់លេង) ថា "គ្មានសុវត្ថិភាព" ឬ "ហាក់គ្មានសុវត្ថិភាព" [60]។ ក្មេងស្រីជាង ១ ភាគ ៤ ដែលមានអាយុចន្លោះពី ១៣ ទៅ ១៧ ឆ្នាំ ដែលធ្លាប់រងការរំលោភបំពាន បាននិយាយថា ការរងគ្រោះដំបូងដោយការរំលោភបំពានផ្លូវភេទមកលើរូបគេ បានកើតឡើងនៅសាលារៀន [61]។ ការគំរាមកំហែងចំពោះសុវត្ថិភាពបែបនេះ រាប់បញ្ចូលទាំងការដាក់ទណ្ឌកម្មលើរាងកាយ និងទណ្ឌកម្មផ្លូវចិត្ត ដែលនៅមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅឡើយ បង្កើតជាឧបសគ្គបន្ទាប់សម្រាប់ការកែលម្អការអប់រំ [62]។

ជាងចុងក្រោយ ថ្វីដ្បិតតែទិដ្ឋភាពរួមផ្នែកគោលនយោបាយនៅក្នុងវិស័យអប់រំបន្តកែលម្អជាបន្តបន្ទាប់ក្តី [63] ក៏ការអនុវត្តនៅតែជាឧបសគ្គ ដោយក្នុងនោះ គោលនយោបាយថ្មីៗចំណាយពេលយូរពេកក្នុងការជួយឲ្យមានការផ្លាស់ប្តូរនៅក្នុងលទ្ធផលសិក្សារបស់កុមារ (ដូចករណីគោលនយោបាយសាលាកុមារមេត្រី ឆ្នាំ ២០០៧ ជាដើម)។ ឧបសគ្គនេះរួមចំណែកឲ្យមានកង្វះគ្រូបង្រៀនដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដែលជាបញ្ហាកើតឡើងជាបន្តបន្ទាប់ ដោយក្នុងនោះ គ្រូបង្រៀនមានតែ ៧៣% ប៉ុណ្ណោះ ដែលគោរពតាមបទដ្ឋានគុណវុឌ្ឍិថ្នាក់ជាតិបាន [64] ហើយសមាមាត្រចំនួនសិស្ស និងគ្រូ នៅតែបន្តមានកម្រិតខ្ពស់។ នៅក្នុងឆ្នាំសិក្សា ២០១៤ – ២០១៥ សាលាបឋមសិក្សាចំនួន ៣៨% នៅក្នុងប្រទេសកម្ពុជា មានសមាមាត្រចំនួនសិស្សធៀបនឹងគ្រូគឺ ៥៣,១:១ ដែលជាកម្រិតមួយខ្ពស់ខ្លាំងធៀបនឹងកម្រិតអប្បបរមា ដែលផ្តល់អនុសាសន៍ដោយអង្គការយូណេស្កូ និងទិសដៅឆ្នាំ ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់សមមាត្រ ៤០:១ [65]។ ស្រដៀងគ្នានេះដែរ សម្ភារសម្រាប់ការអប់រំ នៅតែមានកម្រិតនៅឡើយ ដែលក្នុងនោះសាលារៀនមិនដល់ ៦០% នោះទេ ដែលមានទឹកស្អាត និងទីកន្លែងលាងដៃសម្រាប់កុមារ [66]។

ប្រសិនបើគោលនយោបាយថ្មីត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព នោះមន្ត្រីអប់រំថ្នាក់ស្រុក និងនៅសាលាតម្រូវឲ្យបង្កើនសមត្ថភាព ជាពិសេសសម្រាប់ការរៀបចំថវិកាសាលា និងផែនការអភិវឌ្ឍន៍សាលា។

57 ផែនការសកម្មភាពគណនេយ្យភាពរួមសរុបចំនួន ៨១២ របស់ឃុំចំនួន ៨១២ ឃុំ (ក្នុងខេត្តចំនួន ១៨) ត្រូវបានយកមកវិភាគដោយដៃគូអនុវត្តចំនួន ៥ រួមមាន៖ RACHA, World Vision International' អង្គការសង្គ្រោះកុមារ អង្គការឃែរ និងអង្គការស្តារកម្ពុជា។

58 អង្គការសង្គ្រោះកុមារ, et al., ២០១៨: សង្ខេបគោលនយោបាយថវិកាអប់រំ ២០១៨ – ការដោះស្រាយឧបសគ្គផ្នែកចំណាយដែលកើតមានចំពោះការចូលរៀននៅថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ សម្រាប់សិស្សមកពីក្រុមគ្រួសារក្រីក្ររស់នៅទីជនបទ និងតំបន់ដាច់ស្រយ៉ាល។

59 UNDP Cambodia, ២០១៤: ការទប់ស្កាត់ការបង្រៀនឯកជន និងប្រាក់ឈ្នួលក្រៅផ្លូវការនៅក្នុងការអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

60 មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវអំពីស្ត្រី (ICRW) & និងអង្គការ ផ្លែនអន្តរជាតិ, ២០១៤: តើសាលារៀនជាទីមានសុវត្ថិភាព និងមានសមធម៌យេនឌ័រ ឬទេ៖ ការរកឃើញពីការសិក្សាស្រាវជ្រាវជាមូលដ្ឋានស្តីពីអំពើហិង្សាដោយសារយេនឌ័រនៅសាលារៀនក្នុងប្រទេសចំនួន ៥ ក្នុងទ្វីបអាស៊ី។

61 ក្រសួងកិច្ចការនារី, អង្គការ UNICEF Cambodia, មជ្ឈមណ្ឌលសហរដ្ឋអាមេរិកសម្រាប់ការត្រួតពិនិត្យ និងបង្ការជំងឺ, ២០១៤: ការរកឃើញនៅក្នុងការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ ២០១៣។

62 ថ្វីដ្បិតមានវឌ្ឍនភាពតាមរយៈការអនុម័តលើផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ ២០១៧-២០២១ ក្តី ក៏ការដាក់ទណ្ឌកម្មលើរាងកាយ ត្រូវបានចាត់ទុកថាជាវិធីសាស្ត្រមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងកែតម្រូវចំពោះឥរិយាទរបស់កុមារដែលផ្គាំផ្គងនឹងសង្គម (អង្គការ World Vision Cambodia, ២០១៨៖ សង្ខេបគោលនយោបាយស្តីពីការការពារកុមារ៖ បញ្ចប់ការដាក់ទណ្ឌកម្មរាងកាយ និងទណ្ឌកម្មផ្លូវចិត្តនៅកម្ពុជា)។

63 គោលនយោបាយថ្មីៗពីរដ្ឋាភិបាល មានភាពរីជួមានយ៉ាងខ្លាំងដែលក្នុងនោះរួមមាន៖ គោលនយោបាយការពារកុមារនៅតាមសាលារៀន និងផែនការសកម្មភាពក្នុងឆ្នាំ ២០១៦; ផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលបានដាក់ចេញនៅឆ្នាំ ២០១៧ ដែលហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយក្នុងគ្រប់មជ្ឈដ្ឋានទាំងអស់; ការអភិវឌ្ឍកម្មវិធីអប់រំពហុភាសា និងថ្នាក់មត្តេយ្យចល័ត ដើម្បីឲ្យបានឈានដល់កុមារជនជាតិដើមភាគតិច; ការកែលម្អលើបទដ្ឋានបរិយាប័ន្នជនពិការ ឲ្យស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ។

64 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩: ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩ - ២០២៣, ទំព័រ ២៨។

65 Conochie G, Sopha A, Anderson C, ២០១៧: ការវិភាគលើការពង្រាយគ្រូបឋមសិក្សានៅក្នុងប្រទេសកម្ពុជា ឆ្នាំ ២០១០ – ២០១៥, អង្គការ NGO Education Partnership, ទំព័រ ១២

66 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩: ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩ - ២០២៣, ទំព័រ ២៧។

## តើចាំបាច់ត្រូវធ្វើអ្វីខ្លះ ?

ដើម្បីផ្លាស់ប្តូរស្ថានភាពលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន!សូមផ្តល់អនុសាសន៍ដូចខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖

១ បង្កើនសមត្ថភាពរបស់គ្រូតាមរយៈការបង្កើនការបណ្តុះបណ្តាលសម្រាប់ការបង្រៀនកុមារថ្នាក់ដំបូង ដែលការបណ្តុះបណ្តាលនេះធ្វើឡើងនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ក៏ដូចជាការកសាងសមត្ថភាពស្តីពីវិធីសាស្ត្រគរុកោសល្យដែលកែប្រែឥរិយាបទយេនឌ័រ ការអប់រំបែបបរិយាប័ន្ន និងការប្រើបច្ចេកវិទ្យាសម្រាប់ការរៀន។

២ បង្កើនការជ្រើសរើស និងការរក្សាគ្រូបង្រៀន តាមរយៈការវិនិយោគលើការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនជាពិសេសនៅតាមទីជនបទ។



@ Childfund cambodia

៣ កាត់បន្ថយការយក កម្រៃក្រៅផ្លូវការនៅតាមសាលារៀន រាប់បញ្ចូលទាំងការកាត់បន្ថយការលើកទឹកចិត្តឲ្យមានការបង្រៀនឯកជនជាកំហិត តាមរយៈការបង្កើនប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន នៅតាមទីជនបទដាច់ស្រយាល ( ដូចបានផ្តល់អនុសាសន៍ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងសន្និបាតអប់រំឆ្នាំ ២០១៩ )។

៤ បន្ត សហការ បន្ថែមជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលជំនាញ ដើម្បីបង្កើតសម្ភារសម្រាប់មុខវិជ្ជាលេខនព្វន្ត និងអក្សរសម្រាប់កុមារថ្នាក់ដំបូង និងដើម្បីពង្រីកការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការបង្រៀន។

៥ ធ្វើឲ្យសាលាកាន់តែមានសុវត្ថិភាព សម្រាប់កុមារតាមរយៈការកែលម្អលើការអនុវត្ត និងការពិនិត្យតាមដានលើគោលនយោបាយឆ្នាំ ២០១៦ ស្តីពីការការពារកុមារនៅតាមសាលារៀន រាប់បញ្ចូលទាំងការផ្តល់ធនធានឲ្យបានគ្រប់គ្រាន់សម្រាប់ផែនការប្រតិបត្តិការ ២០១៩ – ២០២៣ និងការផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការដាក់វិន័យបែបវិជ្ជមាន។

៦ គាំទ្រដល់ការពង្រីកការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម ( ISAF ) នៅតាមសាលារៀន ដើម្បីលើកកម្ពស់គណនេយ្យភាព របស់អ្នកសម្រេចចិត្តនៅមូលដ្ឋានសម្រាប់ការរៀបចំផែនការ និងកំណត់ថវិកាឲ្យមានប្រសិទ្ធភាព ដែលឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់សហគមន៍នីមួយៗ ហើយធ្វើឲ្យកំណែទម្រង់វិមជ្ឈការបែបវិជ្ជមានរបស់ប្រទេសកម្ពុជាកាន់តែស៊ីជម្រៅថែមទៀត

៧ សហការជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត និងវិស័យឯកជនដើម្បីធានាថា កុមារដែលចល័តទីលំនៅ និងកុមារដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយ អាចចូលរៀនដោយឥតគិតថ្លៃ។

៨ កែលម្អ ហេដ្ឋារចនាសម្ព័ន្ធទឹក អនាម័យ និងភាពស្អាត នៅតាមសាលារៀន ក៏ដូចជាការកែលម្អលើមជ្ឈដ្ឋានរៀនសូត្រដែលសមប្រកបសម្រាប់កុមារ។

៩ បន្ត បង្កើនវិភាជន៍ថវិកាជាតិ ដល់ប្រព័ន្ធអប់រំឲ្យបានយ៉ាងហោច ២០% នៃថវិកាចំណាយរបស់ជាតិ។

១០ បង្កើនសមត្ថភាពរបស់មន្ត្រីថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសាលារៀន ការធ្វើផែនការថវិកា និងការគ្រប់គ្រងទិន្នន័យ (រាប់បញ្ចូលទាំងឧបករណ៍ពិនិត្យតាមដានបែបឌីជីថល ) សម្រាប់ការចែកចាយ និងការថែទាំសម្ភារបង្រៀន និងរៀន។

# ដោះស្រាយអត្រាប្រេវ៉ាឡង់ខ្ពស់នៃបញ្ហាកិច្ចការពារកុមារ

## កត្តាកែប្រែទី ៣



កុមារនៅក្នុងប្រទេសកម្ពុជាកំពុងប្រឈមនឹងបញ្ហាកិច្ចការពារកុមារជាច្រើន រាប់បញ្ចូលទាំងប្រេវ៉ាឡង់កម្រិតខ្ពស់នៃអំពើហិង្សា ការបំបែកពីក្រុមគ្រួសារ ការទុកចោល និងការកេងប្រវ័ញ្ច ហើយការស្រាវជ្រាវបង្ហាញថា អំពើហិង្សាកើតឡើងនៅច្រើនកន្លែង រាប់បញ្ចូលទាំងនៅផ្ទះ សាលារៀន នៅមណ្ឌលថែទាំជាដើម។

### តើមានអ្វីកំពុងកើតឡើង ?

អំពើហិង្សាទាំងផ្លូវកាយ និងផ្លូវចិត្តបានកើតឡើងយ៉ាងច្រើននៅក្នុងប្រទេសកម្ពុជា ដែលក្នុងនោះកុមារភាគច្រើនដែលមានអាយុចន្លោះពី ១៣ ទៅ ១៧ ឆ្នាំ រាយការណ៍ថា ធ្លាប់ឆ្លងកាត់អំពើហិង្សាលើរាងកាយ (៦១,១% នៃក្មេង ស្រី និង ៥៨,២% នៃក្មេង ប្រុស) និងអំពើហិង្សាផ្លូវចិត្ត (២៤,៣% នៃក្មេង ស្រី និង ២៧,៣% នៃក្មេង ប្រុស) [67] ។ ភាគច្រើននៃកុមារដែលធ្លាប់ឆ្លងកាត់អំពើហិង្សាទាំងពីរប្រភេទ រាយការណ៍ថា វាបានកើតឡើងច្រើនលើក។ ឪពុកម្ដាយ ជាពិសេសម្ដាយ អ្នកថែទាំ និងសមាជិកក្រុមគ្រួសារដែលពេញវ័យផ្សេងទៀត គឺជាអ្នកប្រព្រឹត្តញឹកញាប់ជាងគេ សម្រាប់អំពើហិង្សាលើរាងកាយ និងផ្លូវចិត្តមកលើកុមារ [68]។ តាមពិត "ផ្ទះ" ជាទីកន្លែងដែលកុមាររងអំពើហិង្សាច្រើនជាងគេ ដែលភាគច្រើនបំផុតគឺការដាក់ទ័ណ្ឌកម្មលើរាងកាយ និងផ្លូវចិត្ត។

អំពើហិង្សាផ្លូវភេទក៏កើតឡើងច្រើនដែរ ដែលក្នុងនោះ ក្មេងស្រី ៦% និងក្មេង ប្រុស ៥% ដែលមានអាយុចន្លោះពី ១៣ ទៅ ១៧ ឆ្នាំ រាយការណ៍ថា យ៉ាងហោចណាស់ធ្លាប់ឆ្លងកាត់ការរំលោភបំពានផ្លូវភេទចំនួនមួយលើក មុនពេលឈានដល់អាយុ ១៨ ឆ្នាំ។

### ព័ត៌មានសង្ខេប

**▶ មាត្រា UNCRC ដែលពាក់ព័ន្ធបំផុត៖**

១, ២, ៣, ៥, ៦, ៧, ៨, ៩, ១០, ១១, ១៨, ១៩, ២០, ២១, ២២, ២៥, ៣០, ៣២, ៣៣, ៣៤, ៣៥, ៣៦, ៣៧, ៣៨, ៣៩ និង ៤០

**▶ ចំណុចដៅ SDG៖**

១៦.២: បញ្ឈប់ការរំលោភបំពាន កេងប្រវ័ញ្ច ការជួញដូរ និងគ្រប់ទំរង់ទាំងអស់នៃអំពើហិង្សា និងទារុណកម្មលើកុមារ។

**▶ កុមារដែលបាត់ឱកាសជាងគេបំផុត៖**

កុមារពិការ កុមារមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប កុមារជនជាតិដើម កុមាររស់នៅតំបន់ដាច់ស្រយ៉ាល ជាពិសេសក្មេងស្រី កុមារដែលគ្មានអ្នកនៅជាមួយ (ដោយសារការចំណាកស្រុក និងកត្តាផ្សេងទៀត) កុមារដែលធ្លាប់ឆ្លងកាត់អំពើហិង្សាពីមុនមក។

67 ក្រសួងកិច្ចការនារី, អង្គការ UNICEF Cambodia, មជ្ឈមណ្ឌលសហរដ្ឋអាមេរិកសម្រាប់ការត្រួតពិនិត្យ និងបង្ការជំងឺ, ២០១៤: ការរកឃើញនៅក្នុងការអង្កេតស្ដីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ ២០១៣។

68 ផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១។

សម្រាប់ក្មេងប្រុស ករណីនេះ ភាគច្រើនបំផុតកើតឡើងនៅផ្ទះ ដោយសារសមាជិកគ្រួសារ ចំណែកឯក្មេងស្រី ជារឿយៗឆ្លងកាត់អំពើហិង្សាផ្លូវភេទ ពីដៃគូស្នេហា មិត្តភក្តិ និងពីគ្រូបង្រៀន (ដោយសារសាលារៀនជាទីកន្លែង ដែលករណីហិង្សាលើផ្លូវភេទដំបូងកើតឡើង) [69]។

ក្រៅពីមជ្ឈដ្ឋានផ្ទះ គ្រូបង្រៀន (ជាពិសេសគឺគ្រូប្រុស) គឺជាអ្នកប្រព្រឹត្តអំពើហិង្សាលើរាងកាយ ញឹកញាប់ជាងគេបំផុត។ ក្មេងប្រុសស្រីជាងពាក់កណ្តាល ដែលមានអាយុចន្លោះពី ១៣ ទៅ ១៧ ឆ្នាំ បានរាយការណ៍ថា ធ្លាប់ឆ្លងកាត់អំពើហិង្សាលើរាងកាយដែលប្រព្រឹត្តដោយគ្រូប្រុស (ក្នុងនោះក្មេងស្រី ៥៨,៦% និងក្មេងប្រុស ៥១,៧%) យ៉ាងហោចមួយលើក[70] ហើយ ២៩% នៃកុមារដែលមានអាយុពី ១២ ដល់ ១៥ ឆ្នាំ មានការឆ្លងកាត់ដោយផ្ទាល់នូវការដាក់ទណ្ឌកម្មលើរាងកាយដោយគ្រូបង្រៀនក្នុងរយៈកាល ១២ ខែចុងក្រោយនេះ [71]។ ការសិក្សាស្រាវជ្រាវនានាបង្ហាញថា ការដាក់ទណ្ឌកម្មរាងកាយនៅតាមសាលារៀនគឺជាទម្រង់ដែលមានការទទួលស្គាល់ឲ្យប្រើយ៉ាងទូលំទូលាយសម្រាប់ការប្រៀនប្រដៅ និងបណ្តុះបណ្តាលកុមារ - ក្នុងនោះគ្រូបង្រៀនចំនួន ៦៣% បានរាយការណ៍ថា បានប្រើប្រាស់ទណ្ឌកម្មលើរាងកាយកុមារក្នុងរយៈកាល ១២ ខែ ចុងក្រោយនេះ [72]។ សិស្សអាយុចន្លោះពី ៦ ដល់ ១៤ ឆ្នាំ បានរាយការណ៍ថា ការវាយនឹងដៃ ឬវាយពាត់គឺជាទំរង់ញឹកញាប់ជាងគេនៃការដាក់ទណ្ឌកម្មលើរាងកាយពីសំណាក់គ្រូបង្រៀននៅសាលាបឋមសិក្សា។[73]

ទោះបីជាអាពាហ៍ពិពាហ៍នៅវ័យកុមារបានធ្លាក់ចុះក្នុងរយៈកាល ២៥ ឆ្នាំចុងក្រោយនេះក្តី ក្មេងស្រី១ នាក់ក្នុងចំណោម ៤ នាក់ និងក្មេងប្រុស១ នាក់ក្នុងចំណោម ១៥ នាក់ (ដែលមានអាយុពី ១៨ – ៤៩) រាយការណ៍ថា ពួកគេបានរៀបការមុនអាយុ ១៨ ឆ្នាំ [74] ហើយភាពមានគភ៌នៅវ័យជំទង់ នៅតែកើនឡើងនៅតាមតំបន់ខ្លះនៃប្រទេសកម្ពុជាជាពិសេសនៅតំបន់ដាច់ស្រយាល។[75]

## ប្រសិនបើមិនដោះស្រាយ តើមានផលប៉ះពាល់ដូចម្តេច?

ផលវិបាកទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសុខភាព កើតចេញពីអំពើហិង្សាលើកុមារ គឺមានកម្រិតខ្ពស់ ហើយត្រូវបានប៉ាន់ប្រមាណថា ធ្វើឲ្យប្រទេសកម្ពុជាខាតបង់ទឹកប្រាក់ប្រមាណ ១៦៨ លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ២០១៣ តែមួយឆ្នាំប៉ុណ្ណោះ ដែលស្មើនឹង ១,១០% នៃ GDP ។ [76]

អំពើហិង្សាអាចប៉ះពាល់មកលើសុខភាពរយៈពេលវែងរបស់កុមារ (ផ្លូវចិត្ត និងរាងកាយ) ក៏ដូចជា ប៉ះពាល់មកលើសមត្ថភាពក្នុងការរៀនសូត្ររបស់ពួកគេផងដែរ ដែលក្នុងនោះមាន ផលប៉ះពាល់រយៈពេលវែងសម្រាប់ប្រទេសជាតិថែមទៀតផង។ បន្ទុកលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងធនធានមនុស្ស គួរតែជាហេតុផលគ្រប់គ្រាន់សម្រាប់ការបង្កើនការវិនិយោគឲ្យបានខ្លាំងក្លាលើការបង្ការ និងសេវាឆ្លើយតបនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាអកុសល ក្រុមប្រឹក្សាឃុំ-សង្កាត់ភាគច្រើន បន្តផ្តោតការយកចិត្តទុកដាក់លើការចំណាយលើហេដ្ឋារចនាសម្ព័ន្ធជាជាងសេវាសង្គម។

ទំរង់នៃការដាក់ទណ្ឌកម្មរាងកាយ និងផ្លូវចិត្ត ជាលទ្ធផលបង្កឲ្យមានផលវិបាកផ្នែកសុខភាព និងឥរិយាបទអវិជ្ជមានជាច្រើន [77] ដែលធ្វើឲ្យកុមារមានរបួសស្នាមរាងកាយផង និងការប៉ះទង្គិចផ្លូវចិត្តផង។ បន្ថែមលើនេះ សាលារៀនដែលប្រើប្រាស់ទណ្ឌកម្មរាងកាយ ទទួលលទ្ធផលសិក្សាខ្សោយជាងគេ មានអត្រាបោះបង់ចោលការសិក្សាខ្ពស់ជាងគេ មានការនិយមបំផ្លិចបំផ្លាញសម្ភារ ការរៀនត្រួតថ្នាក់ និងអំពើហិង្សាខ្លាំងជាងគេក្នុងចំណោមសិស្ស។ [78]

---

69 ក្រសួងកិច្ចការនារី, អង្គការ UNICEF, ២០១៤: ការអង្កេតស្តីពីអំពើហិង្សាលើកុមារ នៅកម្ពុជា ២០១៣

70 ក្រសួងកិច្ចការនារី, អង្គការ UNICEF, ២០១៤: ការអង្កេតស្តីពីអំពើហិង្សាលើកុមារ នៅកម្ពុជា ២០១៣

71 Miles, G. & Thomas, N., ២០០៧:, កុំយកពងមាន់មកជល់នឹងថ្ម'—សិទ្ធិកុមារ និងអំពើហិង្សានៅក្នុងប្រវត្តិសាស្ត្រ និងវប្បធម៌កម្ពុជា", ការត្រួតពិនិត្យលើការរំលោភបំពានកុមារ ១៦, ៣៨៣-៤០០, ត្រូវបានស្រង់សម្តីនៅក្នុង UNICEF East Asia and Pacific Regional Office (២០១២), ការធ្វើបាបកុមារ៖ ប្រេវ៉ាឡង់ ករណី និងហេតុការណ៍៖ ការពិនិត្យជាប្រព័ន្ធលើការស្រាវជ្រាវ, Bangkok: UNICEF.

72 MUNICEF, ២០១៨: ការអង្កេតលើវិធីសាស្ត្រដាក់វិន័យនៅតាមសាលាបឋមសិក្សានៅកម្ពុជា របស់អង្គការ KAP

73 World Vision Cambodia, ២០១៨: ស្នាមអនាគត៖ ការសិក្សាពីការកើតមាន និងការទទួលយកអំពើហិង្សាលើកុមារនៅសាលាបឋមសិក្សា។

74 NIS, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា ២០១៤

75 ឧទាហរណ៍ ខេត្តមណ្ឌលគិរី និងរតនគិរី មានអត្រាខ្ពស់បំផុត ក្នុងប្រទេសកម្ពុជា សម្រាប់ការរៀបការនៅវ័យកុមារ និងភាពមានគភ៌នៅវ័យជំទង់។ អាយុជាមធ្យមសម្រាប់ការរៀបអាពាហ៍ពិពាហ៍នៅក្នុងខេត្តមណ្ឌលគិរី គឺ ១៥ ឆ្នាំ ហើយ ៣៤% នៃក្មេងស្រីជំទង់ ដែលមានអាយុចន្លោះពី ១៥ – ១៩ ឆ្នាំ ក្នុងខេត្តនេះ គឺមានកូនមួយ ខណៈដែលអត្រានៅថ្នាក់ជាតិជាមធ្យមគឺមានចំនួនត្រឹម ១២% ប៉ុណ្ណោះ (Partnering to Save Lives, ២០១៨: ឯកសារសិក្សា៖ ភាពមានគភ៌នៅវ័យជំទង់នៅភាគឥសាន្តប្រទេសកម្ពុជា, ជំនួយអូស្ត្រាលី, ក្រសួងសុខាភិបាល, អង្គការ Save the Children អង្គការ ឃែរ អន្តរជាតិ អង្គការ Marie Stopes International)

76 ក្រសួងកិច្ចការនារី, អង្គការ UNICEF, ២០១៤: ការអង្កេតស្តីពីអំពើហិង្សាលើកុមារ នៅកម្ពុជា ២០១៣

77 ទណ្ឌកម្មរាងកាយអាចកំណត់ដំណើរការផ្លូវចិត្ត និងប្រាជ្ញារបស់កុមារ ហើយអំពើហិង្សានេះអាចក្លាយជាគំរូ និងអាចនាំពួកគេឲ្យកើតមានឥរិយាបទបែបបំផ្លិចបំផ្លាញ ដូចជាទំនោរទៅរកអំពើហិង្សានៅពេលដល់អាយុពេញវ័យ (MacKenzie, Nicklas, Waldfogel និង Brooks-Gunn, ២០១២: ទណ្ឌកម្មរាងកាយ និងលទ្ធផលផ្នែកឥរិយាបទ និងប្រាជ្ញារបស់កុមាររហូតដល់អាយុ ៥ ឆ្នាំ: ភស្តុតាងពីការសិក្សាក្រុមទារកទើបនឹងកើតក្នុងទីក្រុងនាសហសម័យ)។
ទណ្ឌកម្មរាងកាយក៏មានជាប់ពាក់ព័ន្ធនឹងការធ្លាក់ចុះនូវទំនុកចិត្ត និងភាពក្លាហានរបស់កុមារផងដែរ និងការកើនឡើងនូវអារម្មណ៍អាម៉ាស់ ខ្វះទីពំនាក់ និងបាក់ទឹកចិត្ត។ (Gershoff Thompson Elizabeth (២០០២) ទណ្ឌកម្មរាងកាយពីសំណាក់ឪពុកម្តាយ និងឥរិយាបទ និងបទពិសោធន៍របស់កុមារដោយសារទណ្ឌកម្មនេះ៖ ការពិនិត្យលើសពីការវិភាគ និងទ្រឹស្តី។

78 គំនិតផ្តួចផ្តើមសកលដើម្បីបញ្ចប់ទណ្ឌកម្មរាងកាយលើកុមារ, ២០១៨៖ ផលប៉ះពាល់អវិជ្ជមាននៃទណ្ឌកម្មរាងកាយ

# តើឧបសគ្គរារាំងដល់វឌ្ឍនភាពមានអ្វីខ្លះ ?

គួរឲ្យសោកស្តាយ ដែលច្បាប់របស់កម្ពុជានៅមិនទាន់ហាមឃាត់ ឬទប់ស្កាត់ឲ្យបានគ្រប់ជ្រុងជ្រោយ លើអំពើហិង្សា និងការរំលោភបំពានលើកុមារ ហើយរាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើបច្ចុប្បន្នភាពលើច្បាប់នានាឲ្យបានឆាប់រហ័សទាក់ទងនឹងការប្រើប្រាស់ការដាក់ទណ្ឌកម្មលើរាងកាយ ឬផ្លូវចិត្តក្នុងកិច្ចការពារសិទ្ធិរបស់កុមារ ប្រកបដោយប្រសិទ្ធិភាព ។ ច្បាប់ទន់ខ្សោយមិនត្រឹមតែធ្វើឲ្យការកាត់ទោសលើជនល្មើសនៅមានកម្រិតនោះទេ ប៉ុន្តែក៏ មិនមានការដេញដោលចំពោះអាកប្បកិរិយា ឬឥរិយាបទនានា នៅពេលដែលអ្នកថែទាំប្រើប្រាស់ទ័ណ្ឌកម្មលើ រាងកាយ ឬផ្លូវចិត្តមកលើកុមារ ដែលទាំងអស់នេះត្រូវបានគេមើលឃើញជាទូទៅថា ជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការកែតម្រូវឥរិយាបទដែលឆ្គាំឆ្គងនឹងសង្គម។

ក្នុងរយៈកាលប៉ុន្មានឆ្នាំថ្មីៗនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ( CNCC ) បានកែលម្អលើការសម្របសម្រួលគោលនយោបាយ និងបទប្បញ្ញត្តិនានា ហើយប្រព័ន្ធការពារកុមារក៏មានការកែលម្អផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី តួអង្គ និងស្ថាប័ននានាពីថ្នាក់ជាតិ ដល់ថ្នាក់មូលដ្ឋាន បន្តប្រឈមបញ្ហាខ្វះខាតធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុដើម្បីបំពេញតាមគោលបំណងរបស់ខ្លួន។ ឧទាហរណ៍ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ ( CCWC )


@ World Vision

ដែលគួរតែរៀបចំផែនការ គាំទ្រ និងតាមដានលើបញ្ហាកិច្ចការពារកុមារ និងករណីផ្សេងៗនៅថ្នាក់មូលដ្ឋាន មានប្រសិទ្ធភាពតិចតួច ដោយសារតែពួកគេមិនយល់ច្បាស់ពីតួនាទីនឹងការទទួលខុសត្រូវ របស់ខ្លួនសម្រាប់កិច្ចការពារកុមារ ខ្វះជំនាញ សម្រាប់ការកំណត់រក និងឆ្លើយតបចំពោះតម្រូវការរបស់កុមាររងាយរងគ្រោះ និងជួបការលំបាកក្នុងការវិភាជន៍ថវិកាសម្រាប់បញ្ហាកិច្ចការពារកុមារនៅក្នុងផែនការវិនិយោគឃុំ។

ដោយសារយន្តការបង្ការនិង ឆ្លើយតបផ្លូវការនៅមានកម្រិតជារឿយៗ ករណីអំពើហិង្សា និងការរំលោភបំពានកុមារត្រូវបានដោះស្រាយ ដោយមិនបានគិតពីឧត្តមប្រយោជន៍ដល់កុមារជាចម្បងឡើយ។ ឧទាហរណ៍ សហគមន៍ជាច្រើនបន្តប្រើប្រាស់មណ្ឌលថែទាំជាមធ្យោបាយក្នុងការថែទាំកុមាររងាយរងគ្រោះ ប៉ុន្តែអាចបង្កឲ្យមានការរំលោភបំពាននិងមិនអើពើផ្សេងទៀត។ មិនមានទិន្នន័យពិតប្រាកដពីចំនួនសរុបនៃកុមារនៅក្នុងមណ្ឌលថែទាំឡើយ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការកំណត់ទីតាំងកន្លែងថែទាំកុមារធ្វើឡើងដោយ រដ្ឋាភិបាលថ្មីៗនេះ បានរកឃើញមណ្ឌលថែទាំ កុមារចំនួន ៦៣៩ កន្លែងដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយមានក្មេងរស់នៅទីនោះចំនួន ២៦.០០០ នាក់ (រួមទាំងមនុស្សពេញវ័យនៅក្មេងចំនួន ៩.០០០ នាក់ ដែលមានអាយុពី ១៨ – ២៤ ឆ្នាំ ) ។ ការសិក្សាផ្សេងៗទៀតប៉ាន់ប្រមាណថា កុមារជាង ៤៨.០០០ នាក់ ឬស្មើនឹងកុមារ ១ នាក់ក្នុងចំណោមកុមារ ១០០ នាក់នៅកម្ពុជា កំពុងរស់នៅក្នុងមណ្ឌលថែទាំចំនួនជាង ១.៦០០ កន្លែង ហើយការសិក្សាក៏ប៉ាន់ប្រមាណថា ៨០% នៃកុមារអាយុចន្លោះពី ១៣ – ១៧ ឆ្នាំ យ៉ាងហោចណាស់មានឪពុក ឬម្តាយ ដែលកំពុងនៅរស់ ។ នៅក្នុងការកំណត់ទីតាំងនេះ ក៏បានបង្ហាញដែរថា មានភាពខុសគ្នាខ្លាំងពីខេត្តមួយទៅខេត្តមួយនូវតួនាទីរបស់រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានក្នុងការដាក់កុមារឲ្យរស់នៅក្នុងមណ្ឌលបែបនេះ ក៏ដូចជាតម្រូវការឲ្យមានការគ្រប់គ្រង និងតាមដានលើកម្មវិធីសមាហរណកម្មកុមារចូលទៅក្នុងគ្រួសារនិងសហគមន៍។

ថ្វីដ្បិតតែអង្គការសង្គមស៊ីវិលជាច្រើន និងដៃគូអភិវឌ្ឍន៍នានាបានវិភាជន៍ធនធានហិរញ្ញវត្ថុ និងបច្ចេកទេសជាច្រើនដើម្បីដោះស្រាយបញ្ហាទាំងនេះក្តី (រាប់បញ្ចូលទាំងការបង្កើតក្រុម

79 មាត្រា ១០៤៥ នៃក្រមព្រហ្មទ័ណ្ឌចែងថាៈ ““អ្នកកាន់អំណាចជាមេបា អាចដាក់ទ័ណ្ឌកម្មមកលើកុមារក្នុងកម្រិតដែលចាំបាច់” ខណៈដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះអនុញ្ញាតឲ្យអ្នកថែទាំចាត់ “វិធានការសមស្រប” លើកុមារ ( និងប្តី ឬប្រពន្ធ ) ដើម្បីដាក់ទ័ណ្ឌកម្មលើពួកគេ។ “ប្រសិនបើការដាក់ទ័ណ្ឌកម្ម និងការបង្រៀន ត្រូវបានអនុវត្តឡើងក្នុងលក្ខណៈថ្លៃថ្នូរ ( មានចិត្តមេត្តា អាណិតអាសូរ រីករាយ ចំពោះភាពរីករាយរបស់មនុស្សម្នាក់ទៀត និងដោយក្តីស្មោះត្រង់ )”។

80 ការសិក្សាមូលដ្ឋានរបស់គម្រោងដែលអនុវត្តដោយអង្គការ ផ្លែនអន្តរជាតិក្នុងឆ្នាំ ២០១៦ បង្ហាញថា បើទោះបីជាមានសក្តានុពលនៃការផ្លាស់ប្តូរនៅថ្នាក់ជាតិ និងថ្នាក់សហគមន៍ក្តី ប្រព័ន្ធការពារកុមារបច្ចុប្បន្នមិនស្ថិតក្នុងស្ថានភាពមួយដែលអាចផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ដល់កុមារ និងក្រុមគ្រួសារដែលត្រូវការជំនួយគាំទ្រនោះទេ។ នេះក៏ដោយសារតែការខ្វះខាតនូវធនធាន សមត្ថភាព ហើយមិនមានក្រសួងណាមួយដែល

81 Jordanwood, M. ២០១៦: ការពារកុមារកម្ពុជា ? អង្គការ World Vision, អង្គការ Save the Children, អង្គការ Child Fund, Plan, UNICEF.

82 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ២០១៧ៈ ការកំណត់ទីតាំងមណ្ឌលថែទាំកុមារនៅក្នុងរាជធានី និង ២៤ ខេត្តនៃព្រះរាជាណាចក្រកម្ពុជា, ទំព័រ ១០។

83 វិទ្យាស្ថានជាតិស្ថិតិ និងសកលវិទ្យាល័យ Columbia University, ២០១៦: ការប៉ាន់ស្មានថ្នាក់ជាតិស្តីពីកុមារនៅក្នុងមណ្ឌលថែទាំនៅប្រទេសកម្ពុជា។

84 ច្បាប់ និងគោលនយោបាយកម្ពុជា ( ដូចជាប្រកាសស្តីពីនីតិវិធីសម្រាប់អនុវត្តគោលនយោបាយថែទាំជំនួសសម្រាប់កុមារ ) បានបញ្ជាក់យ៉ាងច្បាស់ថា រដ្ឋមានទំនួលខុសត្រូវក្នុងការតាមដានលើអ្នកផ្តល់ការថែទាំជំនួស ចែងពីគោលការណ៍ណែនាំប្រតិបត្តិការ ដើម្បីអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសសម្រាប់កុមារនៅក្នុងសហគមន៍ ហើយគ្រប់គ្រងលើសេវារក្សាទុក និងសមាហរណកម្មឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធភាពរបស់រដ្ឋបាលមូលដ្ឋាន និងអាជ្ញាធរនានានៅ ក្នុងប្រព័ន្ធនេះ នៅតែមានអសង្គតភាព ហើយការកំណត់ទីតាំងពីសំណាក់ក្រសួងសង្គមកិច្ចកាលពីឆ្នាំ ២០១៧ បង្ហាញថា ចំនួនមណ្ឌលខុសគ្នាខ្លាំងពីខេត្តមួយទៅខេត្តមួយ។

85 អង្គការ Terre des Hommes Netherlands និងអង្គការ Save the Children បច្ចុប្បន្នកំពុងតែគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្រាវជ្រាវមួយស្តីពីចរិតលក្ខណៈ និងទំហំនៃការកេងប្រវ័ញ្ចលើផ្លូវភេទកុមារតាមអិនធឺណិតនៅក្នុងប្រទេសកម្ពុជា។

ការងារសង្គមកិច្ចផង ) យ៉ាងណាក៏ដោយក៏បរិបទដែលប្រែប្រួលយ៉ាងលឿនសម្រាប់កុមារនៅក្នុងប្រទេសកម្ពុជាតម្រូវឲ្យមានប្រព័ន្ធការពារកុមារដែលរឹងមាំ និងមានជំនាញជាងមុន ហើយមានតែការវិនិយោគរបស់រដ្ឋាភិបាលប៉ុណ្ណោះដែលអាចទ្រទ្រង់ប្រព័ន្ធនេះឲ្យស្ថិតស្ថេរបាន។

ឧទាហរណ៍ វិធីសាស្ត្រនៃការកេងប្រវ័ញ្ចកុមារកំពុងមានការផ្លាស់ប្តូរ ដោយក្នុងនោះ បច្ចេកវិទ្យាដើរតួនាទីកាន់តែធំជាងមុន។ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ិនធឺណិត ( OSEC ) បាននឹងកំពុងមានការកើនឡើងនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែចរិតលក្ខណៈពេញលេញនៃការកេងប្រវ័ញ្ចបែបនេះនៅពុំទាន់អាចកំណត់បានច្បាស់លាស់នៅឡើយដោយសារតែខ្វះទិន្នន័យ។ ថ្វីដ្បិតតែ ផែនការសកម្មភាព ជាតិដើម្បីដោះស្រាយអំពើហិង្សាលើកុមារ ( ២០១៧ - ២០២១ ) ដែលបានដាក់ចេញនៅក្នុងឆ្នាំ ២០១៧ បានបញ្ជាក់ឡើងវិញអំពីតម្រូវការឲ្យមានកិច្ចអន្តរាគមន៍ទាក់ទងនឹង OSEC នៅសឹងគ្រប់មជ្ឈដ្ឋានក្តី ផែនការនេះខ្វះរូបភាពច្បាស់លាស់ដែលបង្ហាញពីវិសាលភាព និងចរិតលក្ខណៈរបស់ OSEC។ បន្ថែមលើនេះ បើទោះបីជាវិស័យដំណើរកម្សាន្ត និងទេសចរណ៍នៅកម្ពុជានៅតែមានសារៈសំខាន់ខ្លាំងសម្រាប់កំណើនសេដ្ឋកិច្ចក្តី វាក៏បន្តផ្តល់ជាកន្លែងបិទបាំងសម្រាប់ការកេងប្រវ័ញ្ចដោយសម្ងាត់លើផ្លូវភេទរបស់កុមារផងដែរ។ [86]

## តើចាំបាច់ត្រូវធ្វើអ្វីខ្លះ ?

រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងពង្រឹងប្រព័ន្ធការពារកុមារ តាមរយៈគោលនយោបាយថ្មីៗ [87] ហើយតាមរយៈការក្លាយជា "ប្រទេសត្រួសត្រាយផ្លូវ" របស់កម្មវិធី ភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។ ទោះជាយ៉ាងនេះក្តី ការអនុវត្តផែនការសកម្មភាពនានានៅមិនទាន់បានពេញលេញនៅឡើយហើយការបាត់សូចនាករមួយរបស់ចំណុចដៅ SDG ១៦.២នៅក្នុង CSDGs ធ្វើឲ្យគណនេយ្យភាពរបស់រដ្ឋាភិបាលមានភាពទន់ខ្សោយក្នុងធ្វើឲ្យមានភាពប្រសើរឡើង។

ដើម្បីកែប្រែស្ថានភាព កិច្ចការពារកុមារ សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! សូមផ្តល់អនុសាសន៍ដូចខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖

១ ហាមឃាត់ការប្រើប្រាស់ទណ្ឌកម្មរាងកាយ និងផ្លូវចិត្ត ជាបន្ទាន់ និងឲ្យបានច្បាស់លាស់ ដោយកំណត់នៅក្នុងគ្រប់ច្បាប់ទាំងអស់ រាប់បញ្ចូលទាំងការពិនិត្យឡើងវិញលើមាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ឆ្នាំ ២០០៥។

២ បង្កើនការវិភាជន៍ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់ការអនុវត្តនូវគោលនយោបាយ ផែនការ និងច្បាប់ដែលមានស្រាប់ ដូចជា គោលនយោបាយស្តីពីការការពារកុមារនៅសាលារៀន គោលនយោបាយការពារកុមារក្នុងវិស័យកសិកម្ម និង ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ( ជាពិសេសគោលនយោបាយ និងនីតិវិធីយុត្តិធម៌បែបកុមារមេត្រី )។

៣ ពង្រឹងការទប់ស្កាត់ និងប្រព័ន្ធឆ្លើយតបតាមរយៈការធ្វើឲ្យបានច្បាស់លាស់ជាងមុន នូវតួនាទី និងទំនួលខុសត្រូវ ការធ្វើវិភាជន៍ធនធាន និងការវិនិយោគលើសមត្ថភាពរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ ( គ.ក.ន.ក ) ក្នុងនាមជាយន្តការជួរមុខរបស់រដ្ឋាភិបាល (រាប់បញ្ចូលទាំងការដាក់ចេញនូវសៀវភៅណែនាំស្តីពីការការពារកុមារសម្រាប់ គ.ក.ន.កផងដែរ )។

៤ ធានាថា គ្រប់ស្ថាប័នរដ្ឋ ជាកន្លែងមានសុវត្ថិភាពសម្រាប់កុមារ តាមរយៈការរៀបចំ ការអនុម័ត និងការអនុវត្តលើគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារសុវត្ថិភាពនៅតាមស្ថាប័នសាធារណៈ។

៥ ពន្លឿនការអភិវឌ្ឍន៍សេវាការងារសង្គមកិច្ចសម្រាប់គ្រប់ឃុំ តាមរយៈការទទួលស្គាល់ ការគាំទ្រ និងការពង្រីកគំរូ "ភ្នាក់ងារសង្គមកិច្ចសហគមន៍"។

៦ ធ្វើឲ្យសូចនាករវាស់វែង និងរាយការណ៍តាមក្រសួងនានាកាន់តែមានភាពស៊ីសង្វាក់គ្នាខ្លាំងជាងមុន ដើម្បីកែលម្អការប្រមូលទិន្នន័យ ការរាយការណ៍ និងការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ សម្រាប់ការធ្វើវិភាជន៍ថវិការវាងខេត្ត ស្រុក និងឃុំ។

៧ ផ្តល់អាទិភាព និងមូលនិធិសម្រាប់កម្មវិធីដែលកែប្រែអាកប្បកិរិយា ចំពោះអំពើហិង្សាលើកុមារ ( ដូចជាកម្មវិធីភាពជាដៃគូ PROTECT កម្ពុជា ជាដើម )។

៨ បង្កើនការសម្របសម្រួលថ្នាក់តំបន់ ដើម្បីលើកកម្ពស់ការយល់ដឹង និងកែលម្អទិន្នន័យស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ិនធឺណិត និងនៅក្នុងឧស្សាហកម្មដំណើរកម្សាន្ត និងទេសចរណ៍ រាប់បញ្ចូលទាំងការពង្រីកកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋាភិបាលនានា ដើម្បីទប់ស្កាត់ជនរំលោភបំពានលើកុមារដែលបានផ្តន្ទាទោសរួច មិនឲ្យចូលមកក្នុងប្រទេសកម្ពុជា ។ [88]

៩ ពន្លឿនការងារអនុវត្ត និងការពិនិត្យតាមដានលើ យុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ២០១៧ – ២០២១ រាប់បញ្ចូលទាំងការវិនិយោគបន្ថែមទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ លើការបង្កើន និងចម្លងយកចំណេះដឹង និងជំនាញចិញ្ចឹមកូនបែបវិជ្ជមាន។

---

86 ថ្វីដ្បិតតែស្ថិតិស្តីពីចំណុចនេះពិបាកនឹងរកក្តី ប៉ុន្តែ ការស្រាវជ្រាវបានបង្ហាញថា ក្នុងចំណោមប្រជាជន ១០០.០០០ នាក់ ដែលទទួលរងការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេសកម្ពុជា មាន ៣០-៣៥% គឺជាកុមារ ទាំងក្មេងប្រុស និងក្មេងស្រី ( Davy, D, ២០១៧: ការពិនិត្យថ្នាក់តំបន់៖ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅអាស៊ីអាគ្នេយ៍, ECPAT International, ទំព័រ ៤៧ )

87 ដូចជា ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧ – ២០២១, យុទ្ធសាស្ត្រចិញ្ចឹមកូនតាមបែបវិជ្ជមាន ឆ្នាំ ២០១៧ – ២០២១ និងសៀវភៅណែនាំស្តីពីការអនុវត្តសេវាសង្គម ដែលអនុញ្ញាតឲ្យ គ.ក.ន.ក កាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាពសម្រាប់ការងារទទួលខុសត្រូវលើការការពារកុមារ។

88 រហូតមកទល់ពេលនេះ ទំនាក់ទំនងជាមួយនឹងអាជ្ញាធរ និងកងកម្លាំងនគរបាលបរទេស ភាគច្រើនគឺជាមួយនឹងបណ្តាប្រទេសលោកខាងលិច។ ច្បាស់ណាស់ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងកម្រិតប្រហែលគ្នានេះដែរ ជាមួយនឹងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ដូចជា ចិន ជប៉ុន និងកូរ៉េជាដើម នឹងរួមចំណែកដល់ការលើកស្ទួយការងារការពារកុមារនេះ។

# កាត់បន្ថយឲ្យបានច្រើនបំផុតនូវអត្រាកុមារខ្វះអាហារូបត្ថម្ភ

## កត្តាកែប្រែទី ៤

ចំនួនកុមារដែលរងបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជាកំពុងមានការថមថយក្នុងរយៈកាលប៉ុន្មានឆ្នាំមកនេះ។ តែទោះបីជាយ៉ាងនេះក្តី អត្រានៃវឌ្ឍនភាពនៅតែមានភាពយឺតយ៉ាវមិនអាចទទួលយកបាន ហើយបន្តគំរាមកំហែងដល់ការអភិវឌ្ឍន៍ធនធានមនុស្សថែមទៀតផង។

## តើមានអ្វីកំពុងកើតឡើង ?

កុមារ ៣២% មានបញ្ហាក្រិសក្រិន ២៤% មានទម្ងន់ស្រាលក្រោមស្តង់ដា ហើយ ១០% គឺ មានភាពស្គមស្គាំង។ នេះជាប្រវ៉ាឡង់កង្វះអាហារូបត្ថម្ភដែលខ្ពស់ ហើយបង្ហាញឲ្យឃើញពីគម្លាតសមធម៌នៅ ក្នុងប្រទេសកម្ពុជា ដែលក្នុងនោះបញ្ហាក្រិសក្រិនកើតមានច្រើននៅតាមទីជនបទ (៣៤%) ជាងនៅក្នុងទីក្រុង (២៤%) ហើយមិនសូវកើតមានចំពោះកុមារដែលមានម្តាយដែលបានទទួលការអប់រំច្រើននោះទេ [89] ។ កម្រិតនៃបញ្ហាក្រិសក្រិនខុសគ្នា ពីខេត្តមួយទៅខេត្តមួយនៅក្នុងប្រទេសកម្ពុជា ដោយមានកម្រិត ១៨% នៅរាជធានីភ្នំពេញ រហូតដល់ ៤៤% នៅក្នុងខេត្តព្រះវិហារ និងស្ទឹងត្រែង។ ក្រៅពីកត្តាភូមិសាស្ត្រ ភាពក្រីក្រក៏ដើរតួនាទីធំ នៅក្នុងបញ្ហាកង្វះអាហារូបត្ថម្ភដែលប៉ះពាល់មកលើប្រជាជន ដែលក្នុងនោះកុមារមកពីក្រុម គ្រួសារដែលមានទ្រព្យធនទាបបំផុត ងាយនឹងមានបញ្ហាកង្វះអាហារូបត្ថម្ភ ខ្លាំងជាងកុមារដែលមកពីក្រុមគ្រួសារដែលមានទ្រព្យធនច្រើន។ [90]

កត្តាមួយក្នុងចំណោមកត្តារួមចំណែកធំៗចំពោះបញ្ហាកង្វះអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជានេះ គឺបញ្ហារាគរូស ដោយសារតែអនាម័យមិនល្អនៅតាមគ្រួសារ និងសហគមន៍ (ដូចជាសាលាមត្តេយ្យ និងបឋមសិក្សាជាដើម)។

## ព័ត៌មានសង្ខេប

- **មាត្រា UNCRC ដែលពាក់ព័ន្ធបំផុត៖**

  មាត្រា ២, ៣, ៦ និង ២៤.

- **ចំណុចដៅ SDG៖**

  គោលដៅទី ២: បញ្ចប់ការស្រេកឃ្លាន សម្រេចបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រសើរឡើង និងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព។

- **កុមារដែលបាត់ឱកាសជាងគេបំផុត៖**

  កុមារមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប កុមារជនជាតិដើម កុមារគ្មានអ្នកនៅជាមួយ (ដោយសារការចំណាកស្រុក និងកត្តាផ្សេងទៀត កុមាររស់នៅតំបន់ដាច់ស្រយាលឬតំបន់ងាយរងគ្រោះមហន្តរាយ ដោយសារតែបញ្ហាផ្គត់ផ្គង់ទឹក និងអនាម័យ កុមារដែលមានលទ្ធភាពទទួលបានសេវាកិច្ចគាំពារសង្គមឬសេវាផ្សេងៗតិចតួច។

---

89 ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ, ២០១៦: ផែនការសកម្មភាពថ្នាក់ជាតិសម្រាប់ការបំបាត់ភាពស្រេកឃ្លាននៅកម្ពុជា។

90 វិទ្យាស្ថានជាតិស្ថិតិ (NIS), អគ្គនាយកដ្ឋានសុខាភិបាល និង ICF International, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤

នៅពេលដែលកុមារជួបប្រទះនូវបញ្ហារាគរូសដដែលៗ គួបផ្សំជាមួយនឹងចំណីអាហារដែលមានតម្លៃអាហារូបត្ថម្ភទាបផងនោះ ពួកគេអាចមានបញ្ហាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ ហើយភាពងាយរងគ្រោះដោយសារតែជំងឺឆ្លងរឹតតែកើនឡើង។[91]

កុមារជាច្រើនក៏កើតមកជាមួយនឹងបញ្ហាមិនសូវមានអាហារូបត្ថម្ភផងដែរ ដោយសារតែភាគរយខ្ពស់នៃស្ត្រីដែលមានបញ្ហាខ្វះឈាមក្រហម (៥៣%)[92] ដែលនាំទៅរកការឆ្លងទន្លេមុនកាលកំណត់កាន់តែច្រើនជាងមុន និងទារកកើតមកមានទម្ងន់ស្រាល[93]។ ក្នុងលក្ខណៈនេះ បញ្ហាកង្វះអាហារូបត្ថម្ភអាចក្លាយជាបន្ទុកពីមួយជំនាន់ទៅមួយជំនាន់បាន។

## ប្រសិនបើមិនដោះស្រាយ តើមានផលប៉ះពាល់ដូចម្តេច?

បញ្ហាក្រិសក្រិនកំពុងវាយប្រហារមកលើកុមារនៅក្នុងដំណាក់កាលសំខាន់នៃការអភិវឌ្ឍន៍របស់ពួកគេ ដែលក្នុងនោះ ទារកទើបនឹងកើតចំនួន ១៦% មានបញ្ហាក្រិនទៅហើយបើគិតត្រឹមអាយុ ៦ ខែ ហើយអត្រាក្រិននេះបានកើនឡើងរហូតដល់ទៅ ៤០% ក្នុងចំណោមកុមារដែលមានអាយុពី ៣៦ – ៤៧ ខែ។[94] កង្វះអាហារូបត្ថម្ភក្នុងកម្រិតធំធេងដូច្នេះ អាចមានផលប៉ះពាល់អវិជ្ជមានរយៈពេលវែងទៅលើប្រទេស បាន។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០១៤ ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍កសិកម្ម និងជនបទ កម្មវិធីស្បៀងអាហារពិភពលោក និងអង្គការ UNICEF បានប៉ាន់ប្រមាណថា បញ្ហាកង្វះអាហារូបត្ថម្ភធ្វើឲ្យកម្ពុជាខាតបង់ទឹកប្រាក់ប្រមាណ ៤០០ លានដុល្លារសហរដ្ឋអាមេរិករៀងរាល់ឆ្នាំ ដែលស្មើនឹងប្រមាណ ២,៥% នៃ GDP របស់ខ្លួន។[95]

តាមរយៈវិធានការនានា បញ្ហាក្រិសក្រិនមានផលប៉ះពាល់ពេញមួយជីវិត និងមិនអាចកែប្រែវិញបានឡើយ សម្រាប់ការអភិវឌ្ឍន៍ផ្នែករាងកាយ និងប្រាជ្ញារបស់កុមារ ហើយអាចកាត់បន្ថយប្រាក់ចំណូលប្រចាំឆ្នាំនាពេលអនាគតសម្រាប់មនុស្សទាំងប្រុស ទាំងស្រី ក៏ដូចជាបង្កើនការចំណាយលើសេវាសុខភាពថែមទៀតផង។[96] ប្រសិនបើគ្មានយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងការបង្កើនអាហារូបត្ថម្ភជាមួយនឹងវិស័យផ្សេងទៀត រាប់បញ្ចូលទាំងវិស័យអប់រំ ការគាំពារសង្គម ការការពារពលកម្មសម្រាប់ម្តាយជាកម្មករ និងភាពមានតម្លៃសមរម្យនៃអាហារដែលមានជីវជាតិទេនោះ កម្ពុជាអាចនឹងមានការពិបាកក្នុងការអភិវឌ្ឍធនធានមនុស្សដែលចាំបាច់សម្រាប់ការសម្រេចឲ្យបាននូវមហិច្ឆិតាឆ្នាំ ២០៣០ របស់ខ្លួន។[97]

## អ្វីខ្លះជាឧបសគ្គរាំងស្ទះដល់វឌ្ឍនភាព?

ជាញឹកញាប់ បញ្ហាកង្វះអាហារូបត្ថម្ភត្រូវបានយល់ឃើញថា បណ្តាលមកពីមិនមានចំណីអាហារគ្រប់គ្រាន់សម្រាប់ទទួលទាន។ តាមការពិត អាហារូបត្ថម្ភល្អ គឺទាក់ទងនឹងការមានអាហារ ត្រឹមត្រូវ និងគ្រប់គ្រាន់ ក្នុងពេលវេលា ត្រឹមត្រូវ ព្រមជាមួយនឹងការទទួលបានការថែទាំសុខភាពចាំបាច់ និងលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ។ កង្វះអាហារូបត្ថម្ភគឺជា បញ្ហា "ពហុវិស័យ" ហើយការលើកកម្ពស់អាហារូបត្ថម្ភតម្រូវឲ្យមានកិច្ចអន្តរាគមន៍ដែលមាការសម្របសម្រួល និងផ្សារភ្ជាប់ទំនាក់ទំនងបានល្អ ពីសំណាក់តួអង្គជាច្រើន ក្នុងរយៈពេលមួយដែលអនុវត្តឲ្យបានស្ថិតស្ថេរ។ ការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភនឹងមិនអាចសម្រេចទៅបានឡើយ ប្រសិនបើគ្មានការសម្របសម្រួលអន្តរវិស័យឲ្យបានខ្លាំង និងកិច្ចខិតខំប្រឹងប្រែងរួមនៅក្នុងវិស័យកសិកម្ម អប់រំ ទឹកស្អាត និងអនាម័យ និងសុខាភិបាលទេនោះ។

ប្រទេសកម្ពុជាមានយុទ្ធសាស្ត្រពហុវិស័យ ដើម្បីលើកកម្ពស់អាហារូបត្ថម្ភក្នុងចំណោមកុមារ និងស្ត្រីមានផ្ទៃពោះ ប៉ុន្តែ បញ្ហាកង្វះការសម្របសម្រួល អន្តរក្រសួង ដែលជាកិច្ចចាំបាច់ដើម្បីអាចអនុវត្តយុទ្ធសាស្ត្រនេះឲ្យបានជោគជ័យ នៅតែកើតមាននៅឡើយ។ ឧបសគ្គនេះនឹងកាន់តែ មានសភាពធ្ងន់ធ្ងរឡើងៗ នៅពេលដែលស្ថានភាពរបស់កុមារ និងក្រុមគ្រួសារចេះតែវិវត្តទៅមុខ។ ឧទាហរណ៍ ស្ត្រីកាន់តែច្រើនឡើងៗ ដែលមានអាយុបង្កកំណើតកូន កំពុងតែផ្លាស់ទីលំនៅនៅក្នុងប្រទេសដើម្បីស្វែងរកការងារធ្វើ ដែលនាំឲ្យមានលក្ខខណ្ឌតម្រូវខុសៗគ្នាសម្រាប់ទទួលបានសេវាថែទាំមុនពេល និងក្រោយពេលសម្រាលកូន

91 WPrüss-Üstün A, Bos R, Gore F, Bartram J., ២០១៨: ទឹកកាន់តែមានសុវត្ថិភាព សុខភាពកាន់តែប្រសើរ៖ ការចំណាយ អត្ថប្រយោជន៍ និងនិរន្តរភាពនៃកិច្ចអន្តរាគមន៍ដើម្បីការពារ និងលើកកម្ពស់សុខភាព។ អង្គការសុខភាពពិភពលោក។

92 NIS, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤

93 រាប់ទៅមុខឆ្ពោះទៅឆ្នាំ ២០១៥, ២០១៣: គណនេយ្យភាពចំពោះមាតា ទារក និងការរស់រានរបស់កុមារ។

94 USAID, ២០១៨: កម្ពុជា៖ ព័ត៌មានអំពីអាហារូបត្ថម្ភ

95 Bagriansky, et al., ២០១៤: របាយការណ៍វាយតម្លៃលើការខូចបង់៖ ផលវិបាកផ្នែកសេដ្ឋកិច្ចដែលកើតចេញពីកង្វះអាហារូបត្ថម្ភនៅកម្ពុជា ។ កម្មវិធីស្បៀងអាហារពិភពលោក។

96 Flabbi, L. and Gatti, R, ២០១៨: ឯកសារស្រាវជ្រាវគោលនយោបាយ ៨៣០៩; សៀវភៅស្តីពីធនធានមនុស្ស, World Bank Group.

97 World Bank Group, ២០១៩: បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែឧសភា ឆ្នាំ ២០១៩

ហើយជាញឹកញាប់ កូនរបស់ពួកគេត្រូវបានទុកឲ្យសមាជិកផ្សេងទៀតក្នុងគ្រួសារជាអ្នកមើលថែ ដែលមានន័យថា ពួកគេមិនអាចទទួលបានការបំបៅដោះតែមួយមុខឡើយក្នុងរយៈ ពេល ៦ ខែ។ នៅចំពោះមុខនៃការប្រែប្រួលបែបនេះ វិធីសាស្ត្រអន្តរវិស័យ ដែលត្រូវបានសម្របសម្រួលបានល្អ និងទទួលខុសត្រូវដោយក្រសួងនានា គឺជារឿងសំខាន់សម្រាប់ការទ្រទ្រង់ឲ្យបានស្ថិតស្ថេរចំពោះអាហារូបត្ថម្ភសម្រាប់កុមារ។ [98]

វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រល្អៗបំផុតផ្សេងទៀតដើម្បីធានាបាននូវអាហារូបត្ថម្ភសមស្របសម្រាប់ ទារក និងកុមារគឺតាមរយៈទម្លាប់ក្នុងការផ្តល់អាហារសមស្របអំឡុងពេល ១០០០ ថ្ងៃដំបូង (គឺចាប់ពីការបង្កកំណើតរហូតដល់កុមារមានអាយុ ២ ឆ្នាំ)។ រយៈពេលនេះ ត្រូវបានចាត់ទុកថាជាដំណាក់កាលសំខាន់នៃឱកាសទទួលបានសុខភាព អាហារូបត្ថម្ភ និងការអភិវឌ្ឍន៍ផ្នែកប្រាជ្ញារបស់កុមារ ដែលសុទ្ធតែជាគន្លឹះសំខាន់សម្រាប់សុខភាព សុខុមាលភាព និងសក្តានុពលប្រាក់ចំណូលទៅថ្ងៃអនាគតទាំងអស់។

ការបំបៅដោះតែមួយមុខក្នុងរយៈកាល ៦ ខែដំបូងនៃជីវិត ហើយបន្តរហូតដល់អាយុ ២ ឆ្នាំ (ឬលើសពីនេះ) គឺជាជម្រើសអាហារូបត្ថម្ភល្អបំផុតសម្រាប់កុមារ។ [99] ទោះបីជាយ៉ាងនេះក្តី មានកុមារតែ ៦៥% ប៉ុណ្ណោះដែលបាន ទទួលការបំបៅដោះតែមួយមុខចាប់ពីអាយុ ០ – ៥ ខែ។ [100] ឪពុកម្តាយជាច្រើននៅពុំទាន់យល់ច្បាស់អំពីទម្លាប់នៃការផ្តល់អាហារសមស្រប អំឡុងពេលអាយុ ១០០០ ថ្ងៃដំបូងរបស់ទារកខ្លួននៅឡើយ។ បញ្ហានេះមួយផ្នែក កើតឡើងដោយសារតែ ប្រទេសកម្ពុជាបានទទួលសារឡេកឡូ និងច្របូកច្របល់ជាច្រើនស្តីពីវិធីសាស្ត្រល្អបំផុតនៅក្នុងការផ្តល់អាហារដល់ទារកទើបនឹងកើត និងកុមារតូច ដែលក្នុងនោះអ្នកថែទាំជាច្រើនបានជ្រើសរើសយកទម្លាប់ផ្តល់អាហារដែលមិនល្អបំផុតសោះឡើយសម្រាប់កុមារ ដោយឆាប់ប្រើប្រាស់អាហារច្រើនប្រភេទពេកសម្រាប់កុមារទទួលទាន (ដូចជាបបរ ឬសម្ល) ឬចំណាយប្រាក់កាសជាច្រើនទៅលើផលិតផលម្សៅទឹកដោះគោគីមី (ម្សៅទឹកដោះគោសម្រាប់ទារក)។ ការយល់ច្រឡំភាគច្រើនអាចបង្កឡើងដោយសារព័ត៌មានផ្សព្វផ្សាយទីផ្សារដែលបំភាន់ និងការផ្សព្វផ្សាយជំរុញការលក់ ដែលផ្តោតលើអ្នកថែទាំកុមារ។ ការអង្កេតលើផលិតផលជំនួសទឹកដោះម្តាយនៅក្នុងខេត្តចំនួន ៦ ក្នុងឆ្នាំ ២០១៨ បង្ហាញថា ក្នុងចំណោមផលិតផលផ្សេងៗចំនួន ១៦៥ មុខដែលដាក់លក់លើទីផ្សារ គ្មានផលិតផលណាមួយដែលអនុលោមបានពេញលេញទៅតាមច្បាប់របស់កម្ពុជា ឬគោលការណ៍ណែនាំអន្តរជាតិឡើយ ដែលច្បាប់ និងគោលការណ៍ទាំងនេះត្រូវបានបង្កើតឡើងដើម្បីការពារប្រជាពលរដ្ឋពីព័ត៌មានកុហក និងលើកកម្ពស់ទម្លាប់ផ្តល់អាហារូបត្ថម្ភ។ [101]

នៅថ្នាក់មូលដ្ឋាន ប្រទេសកម្ពុជាមានក្រុមអ្នកស្ម័គ្រចិត្តសហគមន៍ដ៏រឹងមាំ ដែលត្រូវបានគេហៅថា ក្រុមគាំទ្រសុខភាពភូមិ (VHSG) ដែលដើរតួនាទីសំខាន់ក្នុងការជួយគាំទ្រដល់ការចូលរួមនៅថ្នាក់សហគមន៍ក្នុងកម្មវិធីនានា ដែលទប់ស្កាត់ និងឆ្លើយតបទៅនឹងបញ្ហាកង្វះអាហារូបត្ថម្ភ។ ទោះបីជាយ៉ាងនេះក្តី VHSGs មិនបានធ្វើសមាហរណកម្មពេញលេញទៅក្នុងប្រព័ន្ធសុខាភិបាលផ្លូវការឡើយ ហើយជាទូទៅពួកគេខ្វះការបណ្តុះបណ្តាល ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងដើម្បីឲ្យពួកគេមានដំណើរការប្រកបដោយប្រសិទ្ធភាពពិតៗ។ ទន្ទឹមនឹងនេះ ពួកគេក៏ប្រហែលជាមិនមានសមត្ថភាពក្នុងការធ្វើឲ្យមានឥទ្ធិពល ឬស្វែងយល់ថា ក្រៅពីមណ្ឌលសុខភាព នៅមានសេវានានាដែលមានឥទ្ធិពលលើបញ្ហាកង្វះអាហារូបត្ថម្ភ។ [102]

បញ្ហាកង្វះអាហារូបត្ថម្ភអាចត្រូវបានកាត់បន្ថយតាមរយៈការកែលម្អការងារសម្របសម្រួលធនធានអន្តរក្រសួង បង្កើនការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេសដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និង VHSGs និងតាមរយៈការធ្វើបច្ចុប្បន្នភាពលើគោលនយោបាយនានាសម្រាប់ការចូលរួមរបស់សហគមន៍ ដែលជួយណែនាំស្តីពីសកម្មភាព និងគណនេយ្យភាពសម្រាប់ VHSGs ផងដែរ។


@ Save the Children

98 World Bank, ២០១៣: លើកកម្ពស់អាហារូបត្ថម្ភតាមរយៈវិធីសាស្ត្រពហុវិស័យ។

99 យោងតាម WHO, ស្ត្រីជាម្តាយស្ទើរតែទាំងអស់ អាចបំពៅដោះដោយជោគជ័យ។ ប៉ុន្តែ ស្ថានភាពសុខភាពមួយចំនួនតិចតួចរបស់ទារក និងម្តាយ អាចជាហេតុផល ដើម្បីផ្តល់អនុសាសន៍ឲ្យម្តាយផ្អាកការបំបៅដោះដោយបណ្តោះអាសន្ន ឬឈប់ជាអចិន្ត្រៃយ៍។ មន្ត្រីសុខាភិបាល គួរពិគ្រោះយោបល់នៅក្នុងការសម្រេចចិត្តឈប់បំបៅដោះ និងអត្ថប្រយោជន៍ធៀបនឹងហានិភ័យពីការបញ្ឈប់ដូច្នេះ។

100 NIS, ២០១៥: អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤។

101 World Vision International and Helen Keller International, ២០១៨: ការផ្សព្វផ្សាយជំរុញការលក់នៅនឹងកន្លែង និងការរំលោភលើការដាក់ស្លាករបស់ម្សៅទឹកដោះគោនៅកម្ពុជា៖ ការសង្កេតការណ៍នៅតាមខេត្តចំនួន ៦, ដំណាក់កាលទីពីរ, ២០១៨

102 World Vision, ២០១៨: បញ្ចប់បញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា ជារឿងអាចធ្វើបាន ២០១៨; សង្ខេបគោលនយោបាយកម្ពុជាស្តីពីអាហារូបត្ថម្ភ

# តើចាំបាច់ត្រូវធ្វើអ្វីខ្លះ ?

ថ្វីដ្បិតតែគេអាចគណនាប៉ាន់ស្មានពីការខាតបង់ផ្នែកសេដ្ឋកិច្ច ដោយសារបញ្ហាកង្វះអាហារូបត្ថម្ភក៏ដោយ ផលប៉ះពាល់ពិតរយៈពេលវែងដែលកើតចេញពីបញ្ហាកង្វះអាហារូបត្ថម្ភលើកុមារម្នាក់ៗ និងសង្គមកម្ពុជាទាំងមូល គឺមិនអាចគណនាបានឡើយ ហើយបង្កជាការគំរាមកំហែងខ្លាំងចំពោះសិទ្ធិកុមារ និងអនាគតរបស់កម្ពុជា។

ដើម្បីកែប្រែស្ថានភាពអាហារូបត្ថម្ភកុមារ  សម្ព័ន្ធ សិទ្ធិកុមារ បច្ចុប្បន្ន! សូមផ្តល់អនុសាសន៍ដូចខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖

១ បន្តពង្រឹងបន្ថែមនូវ យុទ្ធសាស្រ្តពហុវិស័យ របស់កម្ពុជាក្នុងការលើកកម្ពស់អាហារូបត្ថម្ភ តាមរយៈ យុទ្ធសាស្រ្តថ្មីប្រកបដោយមហិច្ឆិតា គឺ យុទ្ធសាស្រ្តជាតិសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ( ២០១៩ - ២០២៣ ) ដែលមានកំណត់ជាក់លាក់នូវចំនួនទឹកប្រាក់ពិតប្រាកដក្នុងការអនុវត្ត ផែនការពិនិត្យតាមដាន និងការប្រមូលទិន្នន័យ ហើយស្របតាម SDG ២។




២ បន្តស្វែងរកភាពជាដៃគូ ដូចជាស្ថាប័ន ដែលកើតចេញពីចលនា Scaling Up Nutrition ដែលពង្រឹងដល់ទម្លាប់ក្នុងការបញ្ចូលសារជាតិចិញ្ចឹមក្នុងអាហារ និងកម្មវិធីនានាភាពនៃរបបអាហារ។

៣ វិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធអនាម័យ និងភាពស្អាត ជាពិសេសនៅតាមឃុំជនបទ ហើយអនុវត្តសេវាកម្មបង្ការ និងព្យាបាលសម្រាប់ជំងឺ រាគរូស ( រាប់បញ្ចូលទាំងការបង្កើនការបន្ថែមជាតិស័ង្កសីក្នុងអាហារ និងសេវាព្យាបាលបង្គ្រប់ជាតិទឹកតាមមាត់ នៅថ្នាក់មូលដ្ឋាន )

៤ ប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ឬបំភាន់ ដែលប៉ះពាល់ជាអវិជ្ជមានទៅលើកុមារ តាមរយៈ ការពង្រឹងក្រុមប្រឹក្សាត្រួតពិនិត្យ និងយន្តការបណ្តឹងសម្រាប់អនុក្រឹតលេខ ១៣៣ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ហើយវិនិយោគលើការផ្សព្វផ្សាយសារជាសាធារណៈ ដើម្បីបន្សាបព័ត៌មានខុស ដែលបានចែករំលែករួចទៅ ហើយនៅតាមហាងលក់ទំនិញ និងកន្លែងលក់ឱសថ ឬមន្ទីរពេទ្យជាដើម។

៥ គាំទ្រយុទ្ធនាការអប់រំសាធារណៈ ដើម្បី លើកកម្ពស់ចំណេះដឹង និងការយល់ដឹង របស់ប្រជាជនកម្ពុជាទាក់ទិននឹងអាហារូបត្ថម្ភ និងទម្លាប់ផ្តល់អាហារសមស្របសម្រាប់កុមារ រាប់បញ្ចូលទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីធានាថា សារទាំងនោះបានផ្សព្វផ្សាយដល់ប្រជាជនទាំងមូល។

៦ អនុម័ត គោលនយោបាយស្តីពីការចូលរួមរបស់សហគមន៍ ដែលបានធ្វើបច្ចុប្បន្នភាពរួច និងគោលនយោបាយថែទាំសុខភាពបឋម និងធ្វើសមាហរណកម្មក្រុមគាំទ្រសុខភាពភូមិ ( VHSGs ) ទៅក្នុងប្រព័ន្ធសុខាភិបាលជាតិជាផ្លូវការ។

៧ បង្កើន ការបណ្តុះបណ្តាល និងការអប់រំដល់ VHSGs និងតួអង្គនៅថ្នាក់មូលដ្ឋានដទៃទៀត ដើម្បីបានស្វែងយល់ពីចរិតលក្ខណៈពហុវិស័យ នៃបញ្ហាអាហារូបត្ថម្ភ និងធានាថា ឃុំនានា ត្រូវបានផ្តល់អំណាចឲ្យធ្វើវិភាជន៍ធនធានមូលដ្ឋាន ( នៅក្នុងផែនការវិនិយោគឃុំ ) ដើម្បីគាំទ្រដល់កម្មវិធីអាហារូបត្ថម្ភនៅមូលដ្ឋាន។

# កែលម្អលទ្ធភាពទទួលបានសេវាទឹកផឹកមូលដ្ឋាន និងអនាម័យ

6 CLEAN WATER AND SANITATION

## កត្តាកែប្រែទី ៥

នៅក្នុងប្រទេសកម្ពុជា គ្រួសារមិនដល់ ៦៥% ទេ ដែលមានលទ្ធភាពមានប្រភពទឹកប្រើប្រាស់ល្អ ហើយមានតែ ៧៦% ប៉ុណ្ណោះដែលទទួលបានសេវាអនាម័យល្អ [103]។ ស្ថិតិនេះ គឺជាកម្រិតមួយក្នុងចំណោមកម្រិតទាបបំផុត ទាក់ទងនឹងលទ្ធភាពមានទឹកស្អាតប្រើប្រាស់នៅក្នុងតំបន់អាស៊ី។ [104]

## តើមានអ្វីកំពុងកើតឡើង ?

បញ្ហាអនាម័យនៅតែជាឧបសគ្គធំចំពោះការអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ដោយកម្ពុជាមានអត្រាបន្ទោរបង់ពាសវាលពាសកាលខ្ពស់បំផុត ធៀបនឹងបណ្តាប្រទេសក្នុងតំបន់ ក្នុងនោះ ប្រជាជន ៦ លាននាក់នៅតែបន្តអនុវត្តដូច្នេះ។ [105] គ្រួសារនៅតាមទីជនបទមានបញ្ហាធ្ងន់ធ្ងរជាងនៅតំបន់ទីក្រុង ក្នុងនោះ ៩៨,៩% នៃគ្រួសារក្នុងរាជធានីភ្នំពេញ មានបង្គន់ចុចទឹកភ្ជាប់ជាមួយនឹងបណ្តាញលូទឹកស្អុយ ធៀបនឹងជនបទ ដែលមានតែ ៧០,៩% នៃគ្រួសារប៉ុណ្ណោះ។ [106]

បើទោះបីជាកន្លែងខ្លះមានបង្គន់ ក៏ប្រភេទ និងស្ថានភាពបង្គន់ទាំងនោះខុសៗគ្នាដែរ ហើយបង្គន់មិនមានគ្រប់គ្រាន់ឡើយនៅតាមទីសាធារណៈ ដែលកុមារ និងប្រជាពលរដ្ឋងាយរងគ្រោះប្រើញឹកញាប់។ ឧទាហរណ៍ សាលាមត្តេយ្យរដ្ឋមិនដល់ ៣០% ទេ ដែលមាន បង្គន់អនាម័យ និងកន្លែងលាងដៃ ហើយសាលាបឋមសិក្សាមិនដល់ ៦០% ទេដែលមានទឹកស្អាត និងកន្លែងលាងដៃ។ [107]

### ព័ត៌មានសង្ខេប

**▶ មាត្រា UNCRC ដែលពាក់ព័ន្ធបំផុត៖**

មាត្រា ២, ៣, ៦ និង ២៤

**▶ ចំណុចដៅ SDG៖**

គោលដៅទី ៦៖ ធានានូវវត្តមាន និងការគ្រប់គ្រងដោយចីរភាពចំពោះទឹក និងអនាម័យសម្រាប់មនុស្សទាំងអស់គ្នា។

**▶ កុមារដែលបាត់ឱកាសជាងគេបំផុត៖**

កុមារមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប កុមារីទៅរៀន និងទៅទទួលសេវាកម្មផ្សេងៗ កុមារជនជាតិដើមភាគតិច កុមាររស់នៅតំបន់ដាច់ស្រយាល ឬតំបន់ដែលងាយរងគ្រោះមហន្តរាយ ដោយពុំសូវមានប្រព័ន្ធផ្គត់ផ្គង់ទឹក និងអនាម័យ និងកុមារពិការ។

103 វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, ២០១៨: ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ២០១៧។
104 FAO, ២០១៨. ទិដ្ឋភាពរួមក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៨. ទំព័រ ៤៨
105 FAO, ២០១៨. ទិដ្ឋភាពរួមក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៨. ទំព័រ ៥២
106 វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, ២០១៨: ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ២០១៧។
107 ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩: ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩-២០២៣, ទំព័រ ២២ & ២៧។

ការវិភាគលើទិន្នន័យគណនេយ្យភាពសង្គមនៅតាមសាលារៀនបង្ហាញថា ២០% នៃបញ្ហាដែលបានលើកឡើងដោយប្រជាពលរដ្ឋស្នើឲ្យអាជ្ញាធរមូលដ្ឋានដោះស្រាយជាអាទិភាព គឺទាក់ទងនឹងទឹកស្អាត និងអនាម័យនៅសាលារៀន។ [108]

ស្រដៀងគ្នានេះដែរ មណ្ឌលសុខភាពជារឿយៗ ត្រូវបានរាយការណ៍ថា ពុំមានទឹក និងសម្ភារៈអនាម័យគ្រប់គ្រាន់ឡើយ ដោយក្នុងនោះ មានតែ ៥០% ប៉ុណ្ណោះ ដែលត្រូវបានវិទ្យាស្ថានជាតិសុខភាពសាធារណៈរាយការណ៍ថា តែងតែមានទឹកគ្រប់គ្រាន់សម្រាប់តម្រូវការប្រើប្រាស់។ សេវាថែទាំសុខភាពមិនអាចឆ្លើយតបឲ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការសុខភាពដោយពុំមានទឹកស្អាតឡើយ។ ជារឿងវិជ្ជមាន ដែលមណ្ឌលសុខភាពបានអនុវត្តល្អប្រសើរជាងមុនទាក់ទងនឹងអនាម័យជាទូទៅ បើទោះបីជាមណ្ឌលសុខភាពទាំងនោះខ្វះបង្គន់អនាម័យដាច់ដោយឡែកពីគ្នាសម្រាប់មនុស្សប្រុស និងមនុស្សស្រីក្តី ក៏ដូច ជាខ្វះសម្ភារៈបំពាក់បន្ថែមជាមូលដ្ឋានសម្រាប់ឲ្យបង្គន់អាចប្រើប្រាស់បានដោយមនុស្សដែលពិបាកក្នុងការបម្លាស់ទី ដែលជាអ្នកទៅមណ្ឌលសុខភាពញឹកញាប់ផងដែរ ( ដូចជាស្ត្រីមានផ្ទៃពោះ ជនពិការ ចាស់ជរា និងទឹកន្លែងអនាម័យសម្រាប់ស្ត្រី និងក្មេងស្រីមានរដូវជាដើម )។

លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកល្អ គឺនៅមានកម្រិតទាប ក្នុងនោះក្រុមគ្រួសារជនបទតែ ៥៨%ប៉ុណ្ណោះ ដែលមានប្រភពទឹកល្អប្រើប្រាស់ ដូច្នេះ ប្រជាជនដែលរស់នៅទីជនបទជាង ១,១លានគ្រួសារ ពុំមានប្រភពទឹកល្អប្រើប្រាស់ឡើយ ។ [109]

## ប្រសិនបើមិនដោះស្រាយ តើមានផលប៉ះពាល់ដូចម្តេច ?

ប្រទេសកម្ពុជាទំនងជាមិនបានសម្រេចតាមចំណុចដៅឆ្នាំ២០៣០របស់ខ្លួន លើការធ្វើឲ្យប្រសើរឡើងក្នុងការ លើកកម្ពស់អនាម័យឡើយ។ [110] លទ្ធភាពទទួលបាន សេវាអនាម័យ និងទឹកទទួលទានមានសុវត្ថិភាព នៅមានកម្រិតទាប ដែលអាចមានផលវិបាកធ្ងន់ធ្ងរសម្រាប់កុមាររាប់បញ្ចូលទាំងអត្រាខ្ពស់នៃជំងឺរាគរូស ជំងឺស្បែក ជំងឺផ្លូវដង្ហើម ( ដូចជារលាកសួត ) ជំងឺពោះវៀន និងជំងឺកើតចេញពីទឹក ក៏ដូចជាជំងឺទាក់ទងនឹងកាកសំណល់បន្ទោរបង់ជាដើម។ ទាំងអស់នោះអាចជះឥទ្ធិពលអាក្រក់មកលើសុខភាពកុមារ ហើយក្នុងករណីជាច្រើនអាចបង្កឲ្យមានការស្លាប់ផងដែរ។ ជំងឺរាគរូស គឺជាបុព្វហេតុធំទីពីរ នៃអត្រាមរណភាពរបស់ទារក និងកុមារអាយុក្រោម ៥ ឆ្នាំ នៅក្នុងប្រទេសកម្ពុជា ដែលជាអត្រាមួយខ្ពស់បំផុតផងដែរនៅក្នុងតំបន់។ កង្វះអនាម័យ ក៏ជាកត្តាធ្វើឲ្យមានផលប៉ះពាល់មកលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជាផងដែរ ជាពិសេស ដោយសារបញ្ហាខ្វះអនាម័យនេះហើយដែលនាំឲ្យមាន កង្វះអាហារូបត្ថម្ភរបស់កុមារ ដែលបង្អាក់ដល់ការងារអភិវឌ្ឍន៍ធនធានមនុស្ស។ [111]

## អ្វីខ្លះជាឧបសគ្គរាំងស្ទះដល់វឌ្ឍនភាព ?

បញ្ហាប្រឈមទាក់ទងនឹងទឹកស្អាត និងអនាម័យបង្ហាញឲ្យឃើញពីវិសមភាពធំរវាងទីក្រុង និងតំបន់ជនបទ នឹងទៅតាមកម្រិតទ្រព្យសម្បត្តិ ដែលភ្ជាប់បញ្ហានេះទៅនឹងបញ្ហាប្រឈមជាមូលដ្ឋានផ្សេងទៀតចំពោះការអភិវឌ្ឍន៍សង្គម។ ប្រជាជនរស់នៅក្នុងទីក្រុង មានពិន្ទុខ្ពស់សម្រាប់សូចនាករទាំងអស់ទាក់ទងនឹងទឹកស្អាត និងអនាម័យ ពោលគឺខ្ពស់ជាងប្រជាជនរស់នៅទីជនបទ ( ឧទាហរណ៍ ការបន្ទោរបង់ពាសវាលពាសកាលនៅតាមទីជនបទកើតមានច្រើនលើសក្នុងទីក្រុងរហូតដល់ទៅ ៥ ដង ) [112] ហើយប្រេវ៉ាឡង់នៃជំងឺរាគរូសមានកម្រិតខ្ពស់បំផុតនៅក្នុងគ្រួសារដែលក្រីក្រ ជាជាងក្នុងចំណោមគ្រួសារដែលមានទ្រព្យសម្បត្តិ។ [113]

---

108 តាមរយៈកម្មវិធី ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម ( ISAF ), មនុស្សប្រមាណជាង ២៥០.០០០ នាក់ ចូលរួមនៅក្នុងការវាយតម្លៃលើសេវាអប់រំនៅក្នុងសាលារៀនបឋមសិក្សាចំនួន ១៤០០ និងមណ្ឌលសុខភាពចំនួន ៤៥០ កន្លែង នៅក្នុងខេត្តក្រុងចំនួន ៦០% នៃប្រទេសកម្ពុជា។ ទិន្នន័យដែលបានលើកឡើងនៅទីនេះ គឺជាការសរុបរួមលើការវាយតម្លៃរបស់ពួកគេ។

109 វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, ២០១៨: ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ២០១៧។

110 WHO & UNICEF, ២០១៧: វឌ្ឍនភាពទឹកផឹក និងអនាម័យ: ការធ្វើបច្ចុប្បន្នភាព ២០១៧ និង ទិន្នន័យដើមគ្រា SDG ទំព័រ ១១។

111 World Bank Group, ២០១៩: បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែឧសភា ២០១៩

112 វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, ២០១៨: ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ២០១៧, សូមមើលផងដែរនូវ FAO, កម្ពុជា - ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

113 វិទ្យាស្ថានជាតិស្ថិតិ, អគ្គនាយកដ្ឋានសុខាភិបាល, ២០១៣: កត្តាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាសុខាភិបាលសម្រាប់ជំងឺរាគរូស និងគ្រុនក្តៅនៅវ័យកុមារ ក្នុងប្រទេសកម្ពុជា

ទម្លាប់អនុវត្តប្រចាំថ្ងៃ ដែលអាចធ្វើបញ្ហានេះចេះតែបន្តអូសបន្លាយនោះ គឺពិបាកនឹងកែប្រែខ្លាំងណាស់។ កុមារជាច្រើនកំពុងប្រឈមហានិភ័យដោយសារតែទម្លាប់ប្រើប្រាស់ទឹកដែលគ្មានសុវត្ថិភាព ក្នុងនោះ ក្រុមគ្រួសារចំនួន ៣១% រាយការណ៍ថា ពួកគេមិនបានធ្វើអ្វីទាល់តែសោះ ដើម្បីធ្វើប្រព្រឹត្តកម្មទឹកមុនពេលដែលទទួលទាន។ [114] បន្ថែមលើនេះ ទឹកអាចងាយនឹងកខ្វក់ដោយសារកាកសំណល់ពីការបន្ទោរបង់កាកសំណល់ឧស្សាហកម្ម ឬសារជាតិពុលដែលកើតឡើងពីធម្មជាតិផ្សេងទៀត។ ភាពកខ្វក់ដោយសារតែកាកសំណល់បន្ទោរបង់ នៅកម្រិតគ្រួសារគឺមានកម្រិតខ្ពស់ (រាប់បញ្ចូលទាំងបាក់តេរី អ៊ីកូលី ផង) ហើយនាំឲ្យកើតមានជំងឺរាគរូស និងជំងឺផ្សេងដែលកើតមានចំពោះកុមារកម្ពុជា។ [115]

បញ្ហាផ្សេងទៀត ដែលមានភាពរសើបផ្នែកវប្បធម៌ ដូចជាការមករដូវជាដើម ក៏បង្កជាបញ្ហាប្រឈមចំពោះវឌ្ឍនភាពនេះដែរ។ ស្ត្រីជាច្រើនមិនហ៊ាននិយាយដោយចំហអំពីប្រធានបទបែបនេះឡើយ ហើយក្មេងស្រីជាច្រើនត្រូវចាកចេញពីសាលារៀនដើម្បីគ្រប់គ្រងលើអនាម័យនៃការមករដូវរបស់ខ្លួន ដោយសារតែសាលារៀនប្រហែលជាមិនបានផ្តល់នូវទីកន្លែងចាំបាច់សម្រាប់ផ្តល់នូវឯកជនភាព ឬអនាម័យនោះទេ (ដូចជាវិធីស្ងាត់ៗ និងងាយៗក្នុងការ បោះចោលសំឡីអនាម័យជាដើម)។ [116] លក្ខខណ្ឌអប្បបរមាឆ្នាំ ២០១៦ សម្រាប់ទឹកស្អាត និងអនាម័យតាមសាលារៀន បង្ហាញពីក្តីរំពឹងថា ក្មេងស្រីនឹងអាចគ្រប់គ្រងលើតម្រូវការអនាម័យរបស់ខ្លួននៅតាមសាលារៀន ដោយសុវត្ថិភាព និងងាយស្រួល។

ដោយសារតែភាពស្មុគស្មាញ និងបញ្ហាដ៏ច្រើនក្នុងការគ្រប់គ្រងអនាម័យនិងទឹកស្អាត ដូច្នេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាប្រឈមតាមរយៈគោលនយោបាយពហុវិស័យ និងក្រុមការងារដែលជួយបំពេញបន្ថែមដល់កម្មវិធីទៅតាមវិស័យមួយៗ។ [117] វិធីសាស្ត្រពហុវិស័យបែបនេះ មានសារៈសំខាន់ដើម្បីធានាថាភាពប្រសើរឡើងនៃអនាម័យនិងទឹកស្អាត នាំឲ្យមានលទ្ធផលល្អផ្សេងទៀតសម្រាប់ការអភិវឌ្ឍន៍កុមារ ជាពិសេសការកាត់បន្ថយកង្វះអាហារូបត្ថម្ភ។ ទោះជាយ៉ាងនេះក្តី ដូចគ្នាទៅនឹងផ្នែកផ្សេងទៀតនៃសិទ្ធិកុមារដែរ ការអនុវត្តវិធីសាស្ត្រនេះបាននឹងកំពុងជួបការលំបាក ដោយក្នុងនោះ អាជ្ញាធរមូលដ្ឋានមិនសូវមានចំណេះដឹង ទាក់ទិននឹងផលប៉ះពាល់ធំធេងពីកង្វះអនាម័យក៏ដូចជាថវិកានៅមានកម្រិតសម្រាប់គាំទ្រដល់កម្មវិធីថ្នាក់មូលដ្ឋាន។

ការរៀបចំផែនការគៀងគរធនធានសម្រាប់អនុវត្តកម្មវិធីថ្នាក់ជាតិ ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ និងអនាម័យដែលជួយដល់បញ្ហាអាហារូបត្ថម្ភ ក៏ជាការងារលំបាកផងដែរ។ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវផែនការសកម្មភាពមួយសម្រាប់ឆ្នាំ ២០១៩ – ២០២៣ ដែលត្រូវបានប៉ាន់ប្រមាណថានឹងត្រូវការទឹកប្រាក់យ៉ាងហោចណាស់ ៨៩៨,៤ លានដុល្លារសហរដ្ឋអាមេរិកដើម្បីសម្រេចឲ្យបានផែនការនោះ [118] ដែលនេះជាទឹកប្រាក់ដ៏ច្រើនក្នុងការវិនិយោគ ប៉ុន្តែចំបាច់ ប្រសិនបើចង់សម្រេចគោលដៅក្នុងផ្នែកនេះ។ ថ្វីដ្បិតតែពុំទាន់មានតួលេខច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលភាគីពាក់ព័ន្ធកំពុងចំណាយក្នុងប្រទេសកម្ពុជាលើវិស័យនេះ ទិន្នន័យនានាបង្ហាញថា ការវិនិយោគនាពេលបច្ចុប្បន្ននៅពុំទាន់គ្រប់គ្រាន់ឡើយ។




114 NIS, ២០១៥: ការអង្កេតប្រជាសាស្ត្រ និងសុខាភិបាលកម្ពុជា ២០១៤. ទំព័រ ៤០។
115 Poirot, E. et al, ២០១៨: គុណភាពទឹកសម្រាប់កុមារនៅកម្ពុជា—ជាតិកខ្វក់ខ្ពស់នៅកម្រិតប្រមូលទុក និងទទួលទាន។
116 Cowley, Sarah, ២០១៨: ពីបម្រាម ទៅជាការផ្តល់អំណាច តាមរយៈការគ្រប់គ្រង និងការអប់រំពីការមករដូវ, UNICEF។ អាចរកបាននៅ៖ https://unicefcambodia.blogspot.com/2018/03/from-taboo-to-empowerment-through.html
117 ឧទាហរណ៍ យុទ្ធសាស្ត្រជាតិសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN ២០១៤-២០១៨) ដែលធ្វើសមាហរណកម្ម កម្មវិធី WASH អាហារូបត្ថម្ភ  កម្មវិធីគាំពារសង្គម និងកសិកម្មទៅថ្នាក់ជាតិ និងថ្នាក់សហគមន៍។
118 បទបង្ហាញ ផែនការសកម្មភាពជាតិ ទី ២ នៅក្នុងកម្មវិធី Watsan Retreat ២០១៩

# តើចាំបាច់ត្រូវធ្វើអ្វីខ្លះ?

គ្រប់ក្រសួងរបស់រដ្ឋាភិបាលមានតួនាទី ក្នុងការលើកកម្ពស់ទឹកស្អាត និងអនាម័យ នៅក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងការកែលម្អផែនការ និងការសម្របសម្រួល ក្នុងចំណោមភាគីពាក់ព័ន្ធ និងតួអង្គដែលនៅបែកខ្ញែកគ្នា (រាប់បញ្ចូលទាំងម្ចាស់ជំនួយ ប្រតិបត្តិករឯកជន និងអង្គការមិនមែនរដ្ឋាភិបាល)។




ដើម្បីកែប្រែស្ថានភាព លទ្ធភាពទទួលបានសេវាទឹកផឹកមូលដ្ឋាន និងអនាម័យ សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! សូមផ្តល់អនុសាសន៍ ដូចខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖

១ ត្រូវរៀបចំឲ្យ យន្តការសម្របសម្រួលពហុវិស័យ និងអន្តរក្រសួង មានគណនេយ្យភាពលើការរៀបចំផែនការរួម ការគ្រប់គ្រងទិន្នន័យ និងការរាយការណ៍ពីវឌ្ឍនភាពធៀបនឹងផែនការសកម្មភាពរបស់រដ្ឋាភិបាល

២ ប្រើប្រាស់ដំណើរការវិមជ្ឈការដើម្បី លើកកម្ពស់សមត្ថភាពស្ថាប័នរបស់ស្ថាប័នរដ្ឋ និងអាជ្ញាធរនានា ជាពិសេសនៅថ្នាក់ក្រោមជាតិ សម្រាប់ការធ្វើផែនការរៀបចំថវិកា និងការរាយការណ៍អំពីសេវាទឹកស្អាតនិង អនាម័យ

៣ បង្កើន តម្លាភាពផ្នែកមូលនិធិ និងថវិកា សម្រាប់សេវាទឹកស្អាតនិង អនាម័យដើម្បីពន្លឿនការអនុវត្តគោលនយោបាយដែលមានស្រាប់ រាប់បញ្ចូលទាំងគោលនយោបាយដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិង អនាម័យនៅជនបទ ឆ្នាំ ២០១៩ – ២០២៣

៤ ធានាថា សេវា និងកម្មវិធីទឹកស្អាតនិង អនាម័យមានសមភាពយ៉េនឌ័រ ដោយចាត់វិធានការល្អិតល្អន់ជាមុន ដោះស្រាយឧបសគ្គនានាដែលយើងបានដឹងថា ក្មេងស្រី និងស្ត្រី កំពុងប្រឈម ជាពិសេសនៅតាមទីជនបទ និងតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។

៥ ធានាថា ភាគីពាក់ព័ន្ធទាំងអស់ដែលទទួលខុសត្រូវលើការអនុវត្តការងារទឹកស្អាតនិង អនាម័យ បានដឹងថាកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ មានសក្តានុពលក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភបានច្រើន និងធានាថា មន្ត្រីរដ្ឋាភិបាលរាយការណ៍ទិន្នន័យដែលមានភាពសុក្រឹត ដែលស្របតាមសូចនាករនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (២០១៩ – ២០២៣)។

៥ ឆ្លើយតបចំពោះទិន្នន័យ ដែលរកឃើញតាមរយៈ ដំណើរការគណនេយ្យភាពសង្គម (ISAF) និងទិន្នន័យវាយតម្លៃផ្សេងទៀត ដោយផ្តល់អាទិភាពលើការកែលម្អទឹកស្អាតនិង អនាម័យ នៅតាមទីសាធារណៈ (ជាពិសេសសាលារៀន និងមណ្ឌលសុខភាព)។

©Nick Ralph, World Vision



# បង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់កុមារក្នុងដំណើរការនៃការសម្រេចចិត្ត

16 PEACE, JUSTICE AND STRONG INSTITUTIONS

## កត្តាកែប្រែទី ៦

កុមារ និងយុវជន គឺជាកម្លាំងចលករស្នូលសម្រាប់អនាគតនៃការអភិវឌ្ឍន៍ និងសេដ្ឋកិច្ចរបស់កម្ពុជា ។ ទោះបីជាយ៉ាងនេះក្តី ការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេនៅមានកម្រិតនៅឡើយនៅក្នុងការរៀបចំគោលនយោបាយ និងការសម្រេចចិត្តផ្សេងៗដែលមានផលប៉ះពាល់មកលើពួកគេ។

## តើមានអ្វីកំពុងកើតឡើង ?

នៅក្នុងប្រទេសកម្ពុជា កុមារ និងយុវជនកំពុងត្រូវបានផ្តល់លទ្ធភាពកាន់តែខ្លាំងឡើងក្នុងការចូលរួមក្នុងវេទិកា និងព្រឹត្តិការណ៍ផ្លូវការនានា មានដូចជាការចូលរួមនៅក្នុងសកម្មភាពរដ្ឋាភិបាល រាប់បញ្ចូលទាំងកម្មវិធីពិគ្រោះយោបល់របស់កុមាររៀបចំដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងសូម្បីក្នុងព្រឹត្តិការណ៍ថ្នាក់ជាតិ ជាមួយនឹងសមាជិករដ្ឋសភាផងដែរ។ ទោះបីជាយ៉ាងនេះក្តី ព្រឹត្តិការណ៍ជាច្រើន ជាព្រឹត្តិការណ៍ចំពោះកិច្ច កើតឡើងតែមួយលើកៗ ឬខ្វះនិរន្តរភាពដើម្បីមានឥទ្ធិពលពិតៗលើសេចក្តីសម្រេចចិត្តដែលប៉ះពាល់មកលើរូបគេ។

កុមារ និងយុវជនជាច្រើនមិនត្រូវបានផ្តល់សិទ្ធិអំណាចឲ្យមានលទ្ធភាពក្នុងការបញ្ចេញទស្សនៈនិងចំណាប់អារម្មណ៍របស់ខ្លួនឡើយ ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ហើយមានលទ្ធភាពតិច តួចក្នុងការទទួលបានព័ត៌មានអំពីដំណើរការនៃការសម្រេចចិត្ត។ ករណីនេះ កើតឡើងជាពិសេសចំពោះកុមារងាយរងគ្រោះ ដូចជាកុមារពិការ កុមារជនជាតិដើមភាគតិច កុមារ LGBTIQ កុមាររស់នៅតំបន់ជនបទដាច់ស្រយាល និងតំបន់ដែលក្មេងស្រីមានការផ្តល់ឱកាសតិចតួចជាងក្មេងប្រុសក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការនៃការសម្រេចចិត្តផ្សេងៗ។ [119] សិទ្ធិទទួលបានការស្តាប់យោបល់ និងឲ្យតម្លៃទាក់ទងនឹងការសម្រេចចិត្តដែលប៉ះពាល់មកលើរូបគេ គឺជាគោលការណ៍ស្នូលរបស់អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

### ព័ត៌មានសង្ខេប

**▶ UNCRC និង SDGs៖**

ការចូលរួមរបស់កុមារគឺជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ស្នូលនានានៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលចែងថា កុមារ និងមនុស្សវ័យក្មេងមានសិទ្ធិបញ្ចេញមតិដោយសេរី និងចូលរួមនៅក្នុងគ្រប់បញ្ហាទាំងអស់ដែលមានផលប៉ះពាល់មកលើខ្លួន - មិនថានៅក្នុងគ្រួសារ សាលារៀន សហគមន៍មូលដ្ឋាន សេវាសាធារណៈ ស្ថាប័ននានា គោលនយោបាយ រដ្ឋាភិបាល និងនីតិវិធីតុលាការនោះទេ។ វាជារឿងចាំបាច់ដែលត្រូវមានផែនការល្អ ការអនុវត្ត និងគណនេយ្យភាពសម្រាប់ចំណុចដៅទាំងអស់របស់ SDG។

**▶ មាត្រា UNCRC ដែលពាក់ព័ន្ធបំផុត៖**

មាត្រា ២, ៣, ៦, ១២, ១៣, ១៤, ១៥, ១៦, & ១៧

**▶ កុមារដែលបាត់ឱកាសជាងគេបំផុត៖**

កុមារមកពីក្រុមគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាប  ក្មេងស្រី កុមារជនជាតិដើមភាគតិច កុមាររស់នៅតំបន់ដាច់ស្រយាលកុមារពិការ។

119 OECD. ២០១៧: បញ្ហាសំខាន់ៗប៉ះពាល់មកលើយុវជននៅកម្ពុជា។

នៅឆ្នាំ ២០១៤ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំ គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់អនុវត្តលើការចូលរួមរបស់កុមារ ដើម្បីជានាឲ្យបាននូវការចូលរួមកាន់តែប្រសើរឡើងរបស់កុមារ (រាប់បញ្ចូលទាំងការពង្រឹងឡើងវិញលើគំនិតផ្តួចផ្តើមដែលមានស្រាប់ពីមុនមក ដូចជាការចូលរួមរបស់កុមារ និងក្រុមប្រឹក្សាកុមារ ដែលត្រូវបានបង្កើតឡើងដោយគោលនយោបាយសាលាកុមារមេត្រី ក្នុងឆ្នាំ២០០៧)។ ទោះបីជាយ៉ាងនេះក្តី ការចូលរួមរបស់កុមារ និងយុវជននៅមានកម្រិតនៅឡើយ ឬមានគុណភាពទាប ដោយសារមន្ត្រីរដ្ឋាភិបាលមួយចំនួនមានបទពិសោធន៍នៅមានកម្រិតក្នុងការសម្របសម្រួលឲ្យកុមារនិងយុវជន ជាពិសេសកុមារដែលបាត់ឱកាសបានចូលរួមប្រកបដោយអត្ថន័យ។ [120] នៅក្នុងការអង្កេតតាមឃុំដាច់ស្រយាលនៅលើ និងជុំវិញទន្លេសាប (ខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់) មានកុមារតែ ១១% ប៉ុណ្ណោះ ដែល បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់រដ្ឋបាលមូលដ្ឋាន កាលពីមួយឆ្នាំមុននោះ ហើយមានកុមារតែ ១៤% ប៉ុណ្ណោះ ដែលដឹងថាមន្ត្រីឃុំជានរណា។ [121]

កង្វះតម្លាភាពរបស់រដ្ឋាភិបាលទាក់ទងនឹងព័ត៌មានដែលត្រូវជូនដំណឹងដល់កុមារនិងយុវជនអំពីការធ្វើការសម្រេចចិត្ត ជាពិសេសព័ត៌មានទាក់ទងនឹងថវិកាសាធារណៈ ក៏បានរឹតត្បិតដល់ឱកាសរបស់កុមារនិងយុវជនសម្រាប់ការចូលរួមនៅក្នុងដំណើរការនៃការសម្រេចចិត្តនេះផងដែរ។ ការអង្កេតក្នុងឆ្នាំ ២០១៧ ទៅលើព័ត៌មានថវិកា បានដាក់ពិន្ទុប្រទេសកម្ពុជា ២០ លើ ១០០ ដែលទាបជាងពិន្ទុមធ្យមនៅកម្រិតសកលលោក ដែលមានកម្រិត ៤២ លើ ១០០។ [122] ការអង្កេតដដែលនោះ បានផ្តល់ពិន្ទុត្រឹមតែ ៤ លើ ១០០ សម្រាប់ការចូលរួមជាសាធារណៈ ហើយកម្រិតនេះគឺទាបជាងពិន្ទុមធ្យមរបស់សកលលោក ដែលមានកម្រិត ១២ លើ ១០០។

## ប្រសិនបើមិនដោះស្រាយ តើមានផលប៉ះពាល់ដូចម្តេច?

ក្នុងនាមជាភាគីពាក់ព័ន្ធសំខាន់ក្នុងការជួយជំរុញការអភិវឌ្ឍន៍ និងសេដ្ឋកិច្ចរបស់កម្ពុជានាពេលអនាគត ការចូលរួមរបស់កុមារ និងយុវជននៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំគោលនយោបាយ ថវិកា និងការពិនិត្យតាមដាន គឺមានសារសំខាន់សម្រាប់ការសម្រេចឲ្យបានពេញលេញនូវសិទ្ធិកុមារ។ ការចូលរួមយ៉ាងខ្លាំងក្លារបស់កុមារនិងប្រជាពលរដ្ឋ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តអាចបង្កើនប្រសិទ្ធភាពរបស់សេវាសាធារណៈនៅមូលដ្ឋាន បង្កើនគណនេយ្យភាពព្រមទាំងកាត់បន្ថយអំពើពុករលួយខ្នាតតូច ក៏ដូចជាផ្តល់ឱកាសដល់រដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងនីត្យានុកូលភាពរបស់រដ្ឋាភិបាលផងដែរ ជាពិសេសភាពអាចជឿជាក់ឬទុកចិត្តបានលើឯកសាររដ្ឋ ដូចជាថវិកាជាដើម តាមរយៈការសន្ទនា និងការស្វែងយល់ដែលបើកចំហជាងមុន។

ប្រសិនបើគ្មានឱកាសបែបនេះទេ កុមារ និងយុវជននឹងមិនអភិវឌ្ឍសមត្ថភាពលើផ្នែកថវិការឬអក្ខរកម្មផ្នែកថវិកា និងសមត្ថភាពក្នុងការស្គាល់សេវាកម្ម និងដំណើរការរដ្ឋាភិបាលឡើយ ដែលកត្តានេះអាចធ្វើឲ្យខូចដល់កម្មវិធីវិមជ្ឈការ និងការសម្រេចបាននូវសិទ្ធិផ្សេងទៀតរបស់កុមារ។ ការចូលរួម និងគណនេយ្យភាព ដូចជាសកម្មភាពដែលទទួលបានការគាំទ្រតាមរយៈ ការអនុវត្តគណនេយ្យភាពសង្គម (ISAF) ជាដើម ត្រូវតែមានការពង្រឹងឡើងវិញតាមរយៈអន្តរកម្មពីរដ្ឋាភិបាលឲ្យបានច្រើនជាមួយនឹងកុមារ និងយុវជន ហើយជំរុញការចូលរួមឲ្យបានខ្លាំងក្លានាពេលអនាគត។

## អ្វីខ្លះជាឧបសគ្គរាំងស្ទះដល់វឌ្ឍនភាព?

គួរឲ្យសោកស្តាយ ដែលការចូលរួមរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា ងាយនឹងផ្សារភ្ជាប់ជាមួយនឹងសកម្មភាពនយោបាយពេក ដូច្នេះហើយ ទើបឪពុកម្តាយមិនបានលើកទឹកចិត្តឲ្យកូនចូលរួម ឬស្ម័គ្រចិត្តនៅក្នុងក្រុមដែលសកម្មលើបញ្ហាសង្គមសំខាន់ៗ រាប់បញ្ចូលទាំងបញ្ហានៃការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈផងដែរ។ នេះជាបញ្ហាដែលជាទូទៅកើតចេញពីបញ្ហានៅកម្រិតគ្រួសារ ដែលនៅក្នុងគ្រួសារ កុមារមិនត្រូវបានហៅឲ្យចូលរួមនៅក្នុងការសម្រេចចិត្តដែលប៉ះពាល់ ឬផ្តល់អត្ថប្រយោជន៍ដល់ពួកគេនោះទេ។ [123] ម្យ៉ាងទៀត ឪពុកម្តាយជាពិសេស ឪពុក តែងតែមិនយល់ពីគុណប្រយោជន៍នៃការឲ្យកូនរបស់ខ្លួនចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ឬមិនយល់ពីរបៀបជួយគាំទ្រឲ្យកូនរបស់ខ្លួនបញ្ចេញគំនិត និងទស្សនៈនៅក្នុងដំណើរការនៃការសម្រេចចិត្តក្នុងគ្រួសារឡើយ។ ប្រហែលជាអាចមានការយល់ច្រឡំថា កុមារមិនមានចំណេះដឹងច្រើន ឬបទពិសោធន៍គ្រប់គ្រាន់ទាក់ទងនឹងប្រធានបទសំខាន់ៗ ដើម្បីរួមចំណែក ឬចូលរួមប្រកបដោយអត្ថន័យក្នុងការសម្រេចចិត្ត។

---

120 យោងតាមការប៉ាន់ស្មានដោយសម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! បង្ហាញថា ក្លឹបកុមារប្រមាណជា ៥០០ កំពុងមានសកម្មភាពនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែ ឱកាសដែលកុមារទាំងនេះអាចជួបជាមួយនឹងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅតែមានកម្រិតទាបនៅឡើយ ហើយប្រតិភូតំណាងឲ្យកុមារពិការ កុមារទុកចោលដោយសារការចំណាកស្រុក កុមារជនជាតិដើម និងកុមារ និងយុវជន LGTBI ក៏មានកម្រិតតិចតួចផងដែរ។

121 អង្គការ Save the Children, ២០១៨: វិភាគស្ថានភាពរបស់កុមារនៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ជាប់នឹងបឹងទន្លេសាប។ ទំព័រ ១៣

122 អង្គការ International Budget Partnership, ២០១៧: ការអង្កេតថវិកាចំហ ឆ្នាំ ២០១៧។ អាចរកបាននៅ៖ https://www.internationalbudget.org/open-budget-survey/.

123 អង្គការ Save the Children , ២០១៨: វិភាគស្ថានភាពរបស់កុមារនៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ជាប់នឹងបឹងទន្លេសាប

ជួនកាល កុមារជួបប្រទះនឹងការរើសអើងនៅក្នុងការចូលរួមដោយសារតែភេទរបស់ខ្លួន។ ការអង្កេតឆ្នាំ ២០១៨ បានបង្ហាញថា ក្មេងស្រីត្រូវបានយល់ថា មិនពូកែក្នុងការធ្វើសេចក្តីសម្រេចចិត្តឡើយ ហើយដូច្នេះ មានការចូលរួមតិចតួចនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា។ ថ្វីដ្បិតតែក្មេងប្រុសភាគច្រើននៅក្នុងក្រុមគោលដៅ មិនយល់ស្របចំពោះការលើកឡើងនេះក្តី ប៉ុន្តែការរកឃើញបានបង្ហាញពីការខ្វែងគំនិតគ្នាយ៉ាងជ្រាលជ្រៅអំពីយេនឌ័រ ដែលកើតមាននៅ ក្នុងសង្គមសព្វថ្ងៃ។[124] ការរើសអើងបែបនេះអាចកើតមានចំពោះអ្នកដែលសម្របសម្រួលការចូលរួមរបស់កុមារ ទាំងដឹង ឬមិនដឹងខ្លួន (រាប់បញ្ចូលទាំងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍ផងដែរ) ហើយអាចរឹតត្បិតលើការកើនឡើងនូវការចូលរួមរបស់ក្មេងស្រី។ ការសម្ភាសន៍នានា ជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងនាយកសាលាដែលមាននៅក្នុងការអង្កេតដដែលនោះ បង្ហាញថា មានអ្នកខ្លះយល់ស្របថា វិធីសាស្ត្របុរាណក្នុងការបង្រៀនមិនបានលើកទឹកចិត្តឲ្យកុមារអភិវឌ្ឍ ឬចែករំលែកមតិយោបល់ឡើយ រាប់បញ្ចូលទាំងការមិនលើកជាសំណួរ នៅពេលមានអ្វីដែលមិន "ត្រូវ" ក្តី។ កត្តានេះអាចបង្អាក់ដល់ភាពច្នៃប្រឌិត ភាពជាអ្នកដឹកនាំ និងសមត្ថភាពពីធម្មជាតិ ក្នុងការដោះស្រាយបញ្ហានៅមូលដ្ឋាន។

## តើចាំបាច់ត្រូវធ្វើអ្វីខ្លះ ?

ការបង្កើនការចូលរួមរបស់កុមារប្រកបដោយអត្ថន័យ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត អាច "ផ្លាស់ប្តូរស្ថានភាព" សម្រាប់សិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជាបាន តាមរយៈការធានាថា សេចក្តីសម្រេច និងគោលនយោបាយនានា ដែលប៉ះពាល់មកលើកុមារ អាចចៀសវាងនូវបញ្ហាប្រឈមក្នុងការអនុវត្ត ហើយមានភាពបរិយាប័ន្នពិតៗ។
ដើម្បីសម្រេចបាននូវគោលបំណងនេះ សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! សូមផ្តល់អនុសាសន៍ខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖

១ ពង្រឹងបន្ថែមដល់ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តសេចក្តីសម្រេចលើគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ ដែលបានបង្កើតឡើងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងឆ្នាំ ២០១៤ ហើយពន្លឿនការបញ្ចប់ការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិសម្រាប់ការអភិវឌ្ឍន៍កុមារ។

២ កំណត់ជាកំហិតថា រាល់យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់រដ្ឋាភិបាលត្រូវបញ្ចូលសកម្មភាពជាក់លាក់ ព្រមទាំងសូចនាករ ស្តី ពីការចូលរួមរបស់កុមារី កុមារពិការ និងកុមារមកពីក្រុមជនជាតិដើមភាគតិច។

៣ ផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាលនៅគម្រប់កម្រិតទាំងអស់ (ថ្នាក់ ជាតិ ថ្នាក់ខេត្ត ស្រុក និងឃុំ) ស្តីពីរបៀប សម្របសម្រួលការចូលរួមរបស់កុមារនៅក្នុងការសម្រេចចិត្ត និងដំណើរការនៃការសម្រេចចិត្ត រាប់បញ្ចូលទាំងការចាត់វិធានការកាត់បន្ថយការរើសអើងនៅក្នុងដំណើរការដែលមានស្រាប់ផងដែរ។

៤ ប្រមូល និងផ្សព្វផ្សាយនូវវិធានការ និងការប្តេជ្ញាផ្សេងៗរបស់ក្រសួងពាក់ព័ន្ធ (ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ច ការនារី) នៅក្នុងផែនការ និងថវិកាប្រតិបត្តិការ ប្រចាំឆ្នាំ ដើម្បីឲ្យកម្មវិធីនានាទាក់ទងនឹងការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្តីសម្រេច ចិត្ត អាចរៀបចំជាផែនការកាន់តែល្អប្រសើរ មានការតាមដានច្បាស់លាស់ ចែករំលែក រៀនសូត្រ ព្រមទាំងទទួលបានការសាទរ។

៥ បង្កើនការវិភាជន៍ធនធាននៅក្នុងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីជួយគាំទ្រ និងផ្តល់អាទិភាពលើការចូលរួមរបស់កុមារ ជាពិសេសកុមារីនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការរបស់កម្ពុជា រាប់បញ្ចូលទាំងការគាំទ្រដល់ក្លឹបកុមារ និងយុវជនដែលមានស្រាប់បច្ចុប្បន្ន ក្រុមឪពុកម្តាយ និងក្រុមមិត្តអប់រំមិត្ត ដែលអាចបណ្តុះបណ្តាលអ្នកដទៃអំពីសិទ្ធិកុមារ និងការចូលរួមប្រកបដោយអត្ថន័យ។

៦ ផ្សព្វផ្សាយបន្ថែមអំពីសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ (ដោយក្រសួងមហាផ្ទៃ) ហើយកំណត់ជាកំហិតឲ្យអាជ្ញាធរមូលដ្ឋានប្រើប្រាស់សៀវភៅណែនាំនេះនៅ ក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ និងផែនការអភិវឌ្ឍន៍ឃុំ។

៧ ពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាកុមារ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅសាលារៀន ជាពិសេសសម្រាប់សិស្សស្រី ហើយធានាថា អនុសាសន៍ និងការឆ្លើយតបពីកុមារ ត្រូវបានចងក្រងជាឯកសារសម្រាប់ការពិនិត្យដោយអ្នកធ្វើសេចក្តីសម្រេចចិត្ត។


@ Childfund cambodia

[124] អង្គការថ្លែនអន្តរជាតិ, ២០១៩: សមភាពយេនឌ័រនៅក្នុងការអនុវត្តរបស់ក្លឹបកុមារ យន្តការការពារកុមារតាមសហគមន៍ និងក្រុមឪពុកម្តាយ/អ្នកថែទាំ។

# តើ សម្ព័ន្ធ សិទ្ធិកុមារបច្ចុប្បន្ន! នៅក្នុងប្រទេសកម្ពុជា ជាអ្វី?

សិទ្ធិកុមារបច្ចុប្បន្ន! គឺជាសម្ព័ន្ធ សកលមួយ ដែលមានអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ និងឈានមុខគេលើការងារកុមារ រួមគ្នាដើម្បីតស៊ូមតិឲ្យមានការប្តេជ្ញាចិត្តជាថ្មីក្នុងការសម្រេចឲ្យបាននូវសិទ្ធិសម្រាប់កុមារទាំងអស់។ យើងតស៊ូមតិឲ្យ រដ្ឋាភិបាលទាំងអស់ បង្ហាញការគាំទ្ររបស់ខ្លួនចំពោះបទដ្ឋានដែលបានព្រមព្រៀងជាអន្តរជាតិសម្រាប់សិទ្ធិរបស់កុមារ ហើយជាពិសេស គាំទ្រដល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC) ស្របពេលដែលមានការត្រៀមអបអរខួប ៣០ ឆ្នាំនៃអនុសញ្ញានេះក្នុងឆ្នាំ ២០១៩។

# អង្គការសមាជិក

| | | |
|---|---|---|
| ChildFund Alliance | **Prashant Verma** | (នាយកប្រចាំប្រទេស)<br>ChildFund Cambodia |
| PLAN INTERNATIONAL | **Gwynneth Wong** | (នាយកប្រចាំប្រទេស)<br>Plan International Cambodia |
| Save the Children | **Elizabeth Pearce** | (នាយកប្រចាំប្រទេស)<br>Save the Children International Cambodia |
| SOS CHILDREN'S VILLAGES CAMBODIA | **សួរ ចាន់កុសុម** | (នាយករងថ្នាក់ជាតិ)<br>SoS Children's Villge |
| Terre des Hommes International Federation | **Eric Van Der Lee** | (ប្រធានតំបន់អាស៊ី)<br>Terre des Hommes Netherlands |
| World Vision | **Daniel Selvanayagam** | នាយកប្រចាំប្រទេស<br>World Vision International Cambodia |

## សារតាអង្គការឆាលហ្វាន កម្ពុជា (Child Fund Alliance)

អង្គការឆាលហ្វាន កម្ពុជា គឺជាការិយាល័យតំណាងរបស់អង្គការឆាលហ្វាន អូស្ត្រាលី ដែលជាអង្គការអភិវឌ្ឍន៍អន្តរជាតិ ឯករាជ្យ បំពេញការងារដើម្បីកាត់បន្ថយភាពក្រីក្រសម្រាប់កុមារនៅក្នុងសហគមន៍កំពុងអភិវឌ្ឍ។ អង្គការឆាលហ្វាន អូស្ត្រាលី គឺជាសមាជិក សម្ពន្ធអង្គការឆាលហ្វាន - ដែលជាបណ្តាញសកលនៃអង្គការចំនួន ១១ ជួយដល់កុមារ និងគ្រួសារ ១៣ លាននាក់ នៅក្នុងប្រទេស ចំនួន ៦០។ អង្គការឆាលហ្វាន អូស្ត្រាលី ដែលជាសមាជិកមួយនៃក្រុមប្រឹក្សាអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ គឺជាអង្គការសប្បុរសធម៌ដែលបានចុះបញ្ជីត្រឹមត្រូវ និងទទួលស្គាល់ដោយនាយកដ្ឋានការបរទេស និងពាណិជ្ជកម្ម ដែលគ្រប់គ្រងកម្មវិធីជំនួយអន្តរជាតិរបស់រដ្ឋាភិបាលអូស្ត្រាលី។ អង្គការឆាលហ្វាន បានចាប់ផ្តើមការងារនៅកម្ពុជា ក្នុងឆ្នាំ ២០០៧ និងបានធ្វើការជាដៃគូជាមួយកុមារ សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើតឲ្យមានការផ្លាស់ប្រែ ប្រកបដោយនិរន្តរភាព ឆ្លើយតបទៅនឹងបញ្ហាមនុស្សធម៌ពេលមានគ្រោះមហន្តរាយ និងលើកកម្ពស់សិទ្ធិកុមារ។

មានគម្រោងអភិវឌ្ឍន៍ជាច្រើន បាន និងកំពុងត្រូវបានអនុវត្តក្នុងតំបន់ជនបទនៃខេត្តស្វាយរៀង ក្រចេះ ព្រៃវែង បាត់ដំបង និងជាយរាជធានីភ្នំពេញ ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ និងងាយរងគ្រោះ។ ជាមួយការផ្តោតលើវិស័យកិច្ចការពារកុមារ និងភាពធន់ គុណភាពនៃការអប់រំ ជីវភាពប្រកបដោយនិរន្តរភាព ការចូលរួមលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន អាហារូបត្ថម្ភកុមារ ទឹកស្អាត និងអនាម័យ និងការពង្រឹងសមត្ថភាពយុវជន អង្គការឆាលហ្វាន កម្ពុជា កំពុងធ្វើការដើម្បីពង្រឹងអំណានថ្នាក់ដំបូង តាមរយៈបច្ចេកវិជ្ជាទំនើប និងពង្រឹងយន្តការជាតិការពារកុមារកម្រិតសហគមន៍។ អង្គការឆាលហ្វាន កម្ពុជា អនុវត្តកម្មវិធីរបស់ខ្លួនដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់ និងជាដៃគូជាមួយក្រសួង និងមន្ទីរពាក់ព័ន្ធនានា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**លោក ឃុន ពិសី មន្ត្រីសម្របសម្រួលផ្នែកទំនាក់ទំនង របស់ឆាលហ្វានកម្ពុជា**
**តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ១២ ៩៦៩ ០០៧ ឬអ៊ីមែល៖ khunpisey@childfund.org.kh។**

## អង្គការភ្លែនអន្តរជាតិ (Plan International)

អង្គការភ្លែនអន្តរជាំតិ គឺជាអង្គការអភិវឌ្ឍន៍ និងមនុស្សធម៌មួយ ដែលព្យាយាមបង្កើតឲ្យបាននូវពិភពលោកដែលមានភាពយុត្តិធម៌ ដែលលើកកម្ពស់ដល់សិទ្ធិកុមារ និងសមភាព សម្រាប់ក្មេងស្រី។ អង្គការ ភ្លែនធ្វើការជាមួយនឹងប្រជាជន និងដៃគូដើម្បី៖ ផ្តល់អំណាចដល់កុមារ មនុស្សវ័យក្មេង និងសហគមន៍ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរសំខាន់ៗ ដែលដោះស្រាយលើបុព្វហេតុឫសគល់នៃការរើសអើងមកលើក្មេងស្រី អបរិយាប័ន្ន និងភាពងាយរងគ្រោះ; ជំរុញឲ្យមានការកែប្រែនៅក្នុងទម្លាប់អនុវត្ត និងគោលនយោបាយនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សកល តាមរយៈវិសាលភាពការងារ បទពិសោធន៍ និងចំណេះដឹងរបស់យើងជុំវិញភាពជាក់ស្តែងដែលកុមារជួបប្រទះ; និងធ្វើការជាមួយនឹងកុមារ និងសហគមន៍ ដើម្បីត្រៀមខ្លួន និងឆ្លើយតបចំពោះវិបត្តិ និងជម្នះលើស្ថានភាពអវិជ្ជមាននានា។ គាំទ្រដល់វឌ្ឍនភាពប្រកបដោយសុវត្ថិភាព និងជោគជ័យរបស់កុមារចាប់ពីកើតរហូតដល់ពេញវ័យ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**លោក គុជ ភារុណ ប្រធានទំនាក់ទំនងយុទ្ធសាស្ត្រ**
**តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ១៧ ៥៦៣ ៥២០ ឬ**
**អ៊ីមែល៖ Phearun.Kuch@plan-international.org។**

## អង្គការ Save the Children

អង្គការ Save the Children គឺជាអង្គការសិទ្ធិកុមារធំជាងគេបំផុតក្នុងពិភពលោក ដោយធ្វើប្រតិបត្តិការនៅក្នុងប្រទេសជាង ១២០។ យើងសង្គ្រោះជីវិតរបស់កុមារ យើងប្រយុទ្ធដើម្បីសិទ្ធិរបស់កុមារ យើងជួយកុមារឲ្យបំពេញសក្តានុពលរបស់ពួកគេ ។ នៅក្នុងប្រទេសកម្ពុជា អង្គការ Save the Children បានធ្វើការតាំងពីឆ្នាំ ១៩៧០ ហើយជាអង្គការមួយក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដំបូងគេបំផុត ដែលជួយគាំទ្រក្នុងប្រទេសកម្ពុជា ក្រោយពេលដួលរលំនៃរបបខ្មែរក្រហម។ ដំបូងឡើយ យើងបានផ្តល់ជាជំនួយសង្គ្រោះដល់ក្រុមគ្រួសារដែលរងគ្រោះធ្ងន់ធ្ងរបំផុត នៅតាមជំរំព្រំដែនថៃ ហើយបានប្តូរគោលដៅបន្តិចម្តងៗទៅរកវិស័យអប់រំ ការគាំពារកុមារ សុខភាព អភិបាលកិច្ចសិទ្ធិកុមារ និងជំនួយគ្រោះមហន្តរាយ។ អង្គការ Save the Children ធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការរស់នៅរបស់កុមារ ជាពិសេស កុមារដែលបាត់ឱកាសរស់នៅតំបន់ដាច់ស្រយ៉ាល និងពិបាកទៅដល់បំផុត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**អ្នកស្រី សាយ សុខភាព ប្រធានផ្នែកទំនាក់ទំនង អង្គការសង្គ្រោះកុមារ**
**តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ១២ ៦៨២ ៧៧០ និងអ៊ីមែល៖ Sokpheap.Say@savethechildren.org ។**

## អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា (SOS Children's Villages Cambodia)

អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា ( SOS Children's Villages Cambodia ) មានវត្តមានក្នុង ១៣៥ ប្រទេសទូទាំងពិភពលោក ដែលផ្តល់វិធីសាស្ត្របែបគ្រួសារ ដើម្បីផ្តល់ការថែទាំរយៈពេលវែងដូចនៅក្នុងក្រុមគ្រួសារ ដល់កុមារកំព្រា កុមារទុគ៌ត និងកុមារដែល គេបោះបង់ចោល។ អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលមួយ បានវិវត្តដោយឈរលើគោលការណ៍ចំនួនបួន ដែលធ្វើឲ្យមនោភាពរបស់ SOS ក្លាយជាការពិត សម្រាប់កុមារ ឪពុកម្តាយ ក្រុមគ្រួសារ និងសហគមន៍។ កម្លាំងជំរុញទឹកចិត្តរបស់អង្គការ គឺត្រូវអភិវឌ្ឍសុខុមាលភាពរាងកាយ អប់រំ ឬផ្តល់នូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កុមារនិងមនុស្សវ័យក្មេងមានសុខភាពល្អ ហើយពិសេសជាងនេះ គឺធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមជាតិ។

អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា SOS Children's Village Cambodia មានការប្តេជ្ញាចិត្តក្នុងការធានាថា កុមារទាំងអស់ទូទាំងពិភពលោក ទទួលបានការថែទាំដែលមានគុណភាព ដែលជាសិទ្ធិរបស់គេ។ នៅក្នុងឆ្នាំ ១៩៤៩ លោក Hermann Gmeiner បានបង្កើត អង្គការ SOS Children's Village ដំបូងគេនៅចំពោះមុខការជំទាស់យ៉ាងខ្លាំងក្លា។ អង្គការរបស់យើងត្រូវបានបង្កើតឡើងដោយមានជំនឿ និងការទទួលស្គាល់ - ដែលបានបដិវត្តទៅហើយនៅពេលនោះ ដែលកុមារងាយរងគ្រោះភាគច្រើន ត្រូវការស្ថិរភាពផ្នែកផ្លូវចិត្ត និងរាងកាយនៅក្នុងបរិយាកាសគ្រួសារ និងសហគមន៍ ដើម្បីអភិវឌ្ឍ សក្តានុពលរបស់ខ្លួន។ អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា SOS Children's Village Cambodia ជឿថា ដើម្បីសម្រេចបាននូវបេសកកម្មរបស់ខ្លួន តម្រូវឲ្យមានការប្តេជ្ញាចិត្តអនុវត្តវិធីសាស្ត្រជាច្រើន ដែលមានន័យថា ត្រូវដោះស្រាយដោយផ្ទាល់ចំពោះតម្រូវការបន្ទាន់របស់កុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់គេក៏ដូចជាធ្វើការ លើការទប់ស្កាត់បុព្វហេតុឫសគល់នៃការបែកបាក់ក្រុមគ្រួសារ។ តាមរយៈការធ្វើដូច្នេះ គឺយើងបន្តគាំទ្រ និងលើកកម្ពស់ដល់ការថែទាំ ដែលមានគុណភាព។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**លោក សួរ ច័ន្ទកុសុម នាយករងថ្នាក់ជាតិ អង្គការ ភូមិកុមារ អេស អូ អេស កម្ពុជា ( SOS Children's Villages Cambodia ) តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ១២ ២៥៣ ៦២១**
**ឬអ៊ីមែល៖ Chankosom.sour@soscvcambodia.org។**

## អង្គការ Terre des Hommes Netherlands

អង្គការ Terre Des Hommes Netherlands (TdH-NL) គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយដែលប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចលើកុមារ។ ចាប់តាំងពីឆ្នាំ ១៩៦៥ អង្គការ TdH-NL បានការពារកុមាររាប់សិបលាននាក់ពីអំពើហិង្សា ពលកម្ម ការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទ កង្វះអាហារូបត្ថម្ភ និងបញ្ហាសុខភាព។ សិទ្ធិកុមាររងការរំលោភបំពានទូទាំងពិភពលោក ។ អង្គការ TdH ព្យាយាមបង្កើតពិភពលោកមួយ ដែលមិនមានការកេងប្រវ័ញ្ចលើកុមារ។ យុទ្ធសាស្ត្រឆ្នាំ ២០២០ របស់យើង ត្រូវបានរៀបចំឡើងដើម្បីបង្ហាញផ្លូវដើរយ៉ាងច្បាស់លាស់ឆ្ពោះទៅរកគោលដៅនេះ។ ដើម្បីសម្រេចបាននូវគោលដៅនេះ យើងចាំបាច់ត្រូវផ្ដោតលើលទ្ធផល និងទិន្នផលដែលអាចវាស់វែងបាន និងលទ្ធផលរបស់អ្នកដទៃ។ ការកេងប្រវ័ញ្ចមកលើកុមារគួរតែជាក្ដីបារម្ភសម្រាប់មនុស្សទាំងអស់ គ្នា។ អង្គការ TdH-NL មានការណែនាំផ្លូវដោយទ្រឹស្ដីពីការផ្លាស់ប្ដូរ ដោយផ្ដោតលើការដោះស្រាយការកេងប្រវ័ញ្ចកុមារតាមរយៈវិធីសាស្ត្រចំនួនបួន៖ ការបង្ការ ការផ្ដល់ជូន ការលើកកម្ពស់ និងការផ្ដន្ទាទោស និងជាមួយភាគីពាក់ព័ន្ធចំនួន ៦៖ កុមារ ក្រុមគ្រួសារ និងសហគមន៍ វិស័យឯកជន រដ្ឋាភិបាល ទីភ្នាក់ងារអនុវត្តច្បាប់ និងអង្គការសង្គមស៊ីវិល។ នៅកម្ពុជា កម្មវិធីរបស់យើងផ្ដោតលើការទប់ស្កាត់ និងការដោះស្រាយការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអ៊ិនធឺណិត (OCSE) ការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមរយៈការធ្វើដំណើរកម្សាន្ត និងទេសចរណ៍ (SECTT) និងការរួមចំណែកដល់ការកាត់បន្ថយប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍កុមារនៅក្នុងខេត្តមណ្ឌលគិរី។ ចុងក្រោយ គម្រោងរបស់យើងគ្របដណ្ដប់លើទូទាំងប្រទេស ជាមួយនឹងការស្រាវជ្រាវ និងការរៀបចំផែនការសកម្មភាពថ្នាក់ជាតិ ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា ដោយពង្រឹងជំនាញបច្ចេកទេស និងសមត្ថភាពរបស់កម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**លោក Eric van der Lee ប្រធានប្រចាំតំបន់អាស៊ី  អង្គការ Terre Des Hommes Netherlands**
**តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ៧៧ ៦៥៤ ៨៤៤ និងអ៊ីមែល៖ c.sawada@tdh.nle.vanderlee@tdh.nl ។**

## អង្គការទស្សនៈពិភពលោក (World Vision) អន្តរជាតិប្រចាំកម្ពុជា

ដោយមានវត្តមានក្នុងជិត ១០០ ប្រទេស និងបុគ្គលិក និងអ្នកស្ម័គ្រចិត្តប្រមាណ ៥០.០០០ នាក់ ទូទាំងពិភពលោក អង្គការទស្សនៈពិភពលោក គឺជាអង្គការមិនមែនរដ្ឋាភិបាលលំដាប់ពិភពលោក ដែលផ្ដោតលើសុខុមាលភាពរបស់កុមារតាមរយៈកម្មវិធីអភិវឌ្ឍន៍ និងមនុស្សធម៌ផ្សេងៗ។ ដំបូងឡើយ អង្គការទស្សនៈពិភពលោកបានចូលមកធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩៧០ ហើយក្រោយពេលដួលរលំរបស់របបខ្មែរក្រហម បានចាប់ផ្ដើមការងាររបស់ខ្លួនសាជាថ្មីនៅក្នុងឆ្នាំ ១៩៨០។ ចាប់តាំងពីពេលនោះមក អង្គការ ទស្សនៈពិភពលោកបានបង្កើនបុគ្គលិករបស់ខ្លួនរហូតដល់ទៅជាង ៨០០ នាក់ដែលបម្រើការនៅក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន ៩ ទូទាំងប្រទេសកម្ពុជា ដែលផ្ដល់អត្ថប្រយោជន៍ដល់កុមារចំនួន ២,៧ លាននាក់ជារៀងរាល់ឆ្នាំ។ កម្មវិធីរបស់អង្គការទស្សនៈពិភពលោក ផ្ដោតលើសុខភាព និងអាហារូបត្ថម្ភ ការអប់រំ និងបំណិនជីវិត ការការពារកុមារ និងគម្រោងយុវជន។ នៅខែវិច្ឆិកា ឆ្នាំ ២០១៧ អង្គការទស្សនៈពិភពលោកនៅកម្ពុជា បានដាក់ចេញនូវយុទ្ធនាការសាកលមួយ ដែលមានឈ្មោះថា It Takes a World to End Violence Against Children។ ព័ត៌មានច្រើនទៀតអំពីយុទ្ធនាការនេះ អាចរកបាននៅត្រង់នេះ៖ https://www.wvi.org/ittakesaworld

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**អ្នកស្រី ឡាយ រតនា ប្រធានប្រតិបត្តិការទំនាក់ទំនង អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំកម្ពុជា**
**តាមរយៈទូរស័ព្ទលេខ៖ +៨៥៥ ១១ ៩១៥ ៩២៥  ឬអ៊ីមែល៖ ratana_lay@wvi.org ។**





@ Childfund cambodia

# សិទ្ធិកុមារបច្ចុប្បន្ន!

# កម្ពុជា

“រួមកម្លាំងគ្នា”

គឺជាការសហការគ្នារវាងអង្គការដូចខាងក្រោម៖

CRC30 YEARS CONVENTION ON THE RIGHTS OF THE CHILD

ChildFund Alliance · PLAN INTERNATIONAL · Save the Children · SOS CHILDREN'S VILLAGES CAMBODIA · Terre des Hommes International Federation · World Vision